**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ: ៣៥៥ សហវ.ពក

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៨

# ប្រកាស
## ស្តីពី
## ការកំណត់តម្លៃគិតពន្ធគយលើទំនិញនាំចូល

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៧០៤/ ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## <u>សម្រេច</u>

## ជំពូកទី ១

## និយមន័យ

**ប្រការ ១.-**

សម្រាប់គោលបំណងនៃប្រកាសនេះ ៖

- កម្រៃជើងសារ គឺជាថ្លៃ ឬជាទឹកប្រាក់ដែលយកដោយជើងសារគយ ឬអន្តរការីដែលជាអ្នកជម្រុញឲ្យមានកិច្ចចម្លងការ និងជារឿយៗមិនចេញមុខច្បាស់លាស់ថាជាតំណាងរបស់ភាគីណាមួយឡើយ ។ កម្រៃជើងសារត្រូវបូកបញ្ចូល តែក្នុងករណីដែលវាជាប់ពាក់ព័ន្ធនឹងការលក់ទំនិញដែលត្រូវកំណត់តម្លៃប៉ុណ្ណោះ ។

-កម្រៃសេវាពីការទិញគឺជាកម្រៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដដោយអ្នកទិញទៅភ្នាក់ងាររបស់ខ្លួន សម្រាប់សេវាតំណាងអ្នកទិញនៅក្រៅប្រទេសដែលទាក់ទងទៅនឹងការទិញទំនិញឲ្យខ្លួន ។

- តម្លៃគណនាគឺជាតម្លៃគិតពន្ធគយដែលកំណត់ស្របតាមបញ្ញត្តិជំពូកទី ៧ នៃប្រកាសនេះ ។

-តម្លៃអនុមានគឺជាតម្លៃគិតពន្ធគយដែលកំណត់ស្របតាមប្បញ្ញត្តិជំពូកទី ៦ នៃប្រកាសនេះ ។

- កម្រៃ គឺជាថ្លៃ បន្ទុក ការទូទាត់ ឬទឹកប្រាក់ដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដចំពោះបំណុល ។

- ចំណាយទូទៅ គឺជាថ្លៃ បន្ទុក និងចំណាយដោយផ្ទាល់ ឬដោយប្រយោលនៃផលិតកម្ម និងការលក់ទំនិញសម្រាប់នាំចេញមកកម្ពុជា ។

- ទំនិញនៃក្រុម ឬប្រភេទដូចគ្នា គឺជាទំនិញនាំចូលដែល ៖

ក- ស្ថិតនៅក្នុងក្រុម ឬជួរជាមួយគ្នានឹងទំនិញនាំចូល ដែលបានផលិតដោយឧស្សាហកម្មជាក់លាក់ណាមួយ ឬក៏ផ្នែកឧស្សាហកម្មមួយ ដោយគិតបញ្ចូលទំនិញដូច ឬ ទំនិញប្រហាក់ប្រហែល ដែលទាក់ទងទៅនឹងទំនិញដែលត្រូវកំណត់តម្លៃគិតពន្ធគយ ។

ខ- បាននាំចេញពីប្រទេសណាមួយ សម្រាប់គោលបំណងនៃបញ្ញត្តិជំពូក

ទី ៦ នៃប្រកាសនេះ និងបានផលិត ហើយបាននាំចេញពីប្រទេសដែលទំនិញ ត្រូវបានកំណត់តម្លៃ ត្រូវបានផលិត និងបាននាំចេញ សម្រាប់គោលបំណងនៃបញ្ញត្តិជំពូកទី ៧ នៃប្រកាសនេះ ។

- ទំនិញដូច គឺជាទំនិញនាំចូលដែល ៖

ក- ដូចគ្នាលើគ្រប់ទិដ្ឋភាព រួមមាន លក្ខណៈរូប គុណភាព និងកេរ្តិ៍ឈ្មោះដូចទំនិញដែលត្រូវបានកំណត់តម្លៃ លើកលែងតែភាពខុសគ្នាបន្តិចបន្តួចផ្នែករូបរាងដែលមិនប៉ះពាល់ដល់តម្លៃទំនិញ។

ខ- ត្រូវបានផលិតនៅក្នុងប្រទេសដែលទំនិញត្រូវកំណត់តម្លៃ ។

គ- ត្រូវបានផលិតដោយ ឬក្នុងនាមនៃបុគ្គលដែលបានផលិតទំនិញ ដែលត្រូវកំណត់តម្លៃ ប៉ុន្តែមិនរាប់បញ្ចូលទំនិញនាំចូលដែលស្នាដៃវិស្វកម្ម ស្នាដៃអភិវឌ្ឍន៍ ស្នាដៃសិល្បៈ ស្នាដៃ គំនូស ប្លង់ និងគំនូសវាស ដែលធ្វើឡើងនៅកម្ពុជា ហើយត្រូវបានផ្តល់ដោយផ្ទាល់ ឬដោយប្រយោលដោយអ្នកទិញទំនិញនាំចូលទាំងនោះ ដោយមិនគិតថ្លៃ ឬដោយបន្ថយថ្លៃ សម្រាប់ការប្រើប្រាស់ពាក់ព័ន្ធទៅនឹងផលិតកម្ម និងការលក់សម្រាប់នាំចេញនៃទំនិញនាំចូលទាំងនោះ ។

- ថ្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដ នៃទំនិញណាមួយ គឺជាទឹកប្រាក់សរុបដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដដោយអ្នកទិញទៅឲ្យ ឬក៏សម្រាប់ជាប្រយោជន៍ដល់អ្នកលក់ទំនិញនោះ ។

- ការផលិត រួមមាន ការដាំដុះ ការចិញ្ចឹម ការផលិត និងការយកចេញពីធរណី ។

- កម្រៃសេវាពីការលក់ គឺជាកម្រៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដដោយអ្នកលក់ទៅឲ្យភ្នាក់ងាររបស់ខ្លួន សម្រាប់សេវាតំណាងអ្នកលក់នៅក្រៅប្រទេសដែលទាក់ទងនឹងការលក់ទំនិញឲ្យខ្លួន ។

- ទំនិញប្រហាក់ប្រហែល គឺជាទំនិញនាំចូលដែល ៖

ក- ស្ទើរតែដូចគ្នានឹងទំនិញដែលត្រូវបានកំណត់តម្លៃ លើសមាសធាតុផ្សំបំណែក និងលក្ខណៈរូប ហើយអាចជំនួសបានតាមមុខងារ និងក្នុងពាណិជ្ជកម្មជាមួយទំនិញដែលត្រូវបានកំណត់តម្លៃទាំងខាងគុណភាព និងកេរ្តិ៍ឈ្មោះ ។

ខ- ត្រូវបានផលិតនៅក្នុងប្រទេសនៃទំនិញដែលត្រូវកំណត់តម្លៃ ។

គ- ត្រូវបានផលិតដោយ ឬក្នុងនាមនៃបុគ្គលដែលផលិតទំនិញដែលត្រូវកំណត់តម្លៃ ប៉ុន្តែមិនរាប់បញ្ចូលទំនិញនាំចូលដែលស្នាដៃវិស្វកម្ម ស្នាដៃអភិវឌ្ឍន៍ ស្នាដៃសិល្បៈ ស្នាដៃគំនូស ប្លង់ ឬក៏គំនូសវាស ដែលធ្វើឡើងនៅប្រទេសកម្ពុជា ត្រូវបានផ្តល់ដោយផ្ទាល់ ឬដោយប្រយោល ដោយអ្នកទិញទំនិញនាំចូលទាំងនោះ ដោយមិនគិតថ្លៃ ឬដោយបន្ថយថ្លៃ សម្រាប់ការប្រើប្រាស់ពាក់ព័ន្ធទៅនឹងផលិតកម្ម និងការលក់សម្រាប់នាំចេញទំនិញនាំចូលទាំងនោះ ។

- ព័ត៌មានគ្រប់គ្រាន់ អំពីការកំណត់នូវទឹកប្រាក់ណាមួយ ភាពខុសគ្នា ឬការកែតម្រូវ មានន័យថា ជាព័ត៌មានអាចកំណត់បរិមាណបានដែលចែងយ៉ាងច្បាស់លាស់ពីភាពត្រឹមត្រូវនៃទឹកប្រាក់ភាពខុសគ្នា ឬការកែតម្រូវ ។

- តម្លៃចម្លងការ គឺជាតម្លៃគិតពន្ធគយដែលកំណត់ស្របតាមបញ្ញត្តិជំពូកទី ២ និងបញ្ញត្តិជំពូកទី ៣ នៃប្រកាសនេះ ។

**ប្រការ ២.-**

សម្រាប់គោលបំណងនៃប្រកាសនេះ បុគ្គលដែលចាត់ថាពាក់ព័ន្ធគ្នាគឺមានតែ ៖

ក- បុគ្គលទាំងឡាយដែលជាបុគ្គលិក ឬជានាយក នៃកន្លែងធុរកិច្ចទាំងសងខាង

ខ- បុគ្គលទាំងឡាយ ដែលត្រូវបានទទួលស្គាល់ដោយស្របច្បាប់ថាជាដៃគូគ្នាក្នុងធុរកិច្ច

គ- បុគ្គលទាំងឡាយជានិយោជក និងនិយោជិក

ឃ- បុគ្គលណាម្នាក់ ដោយផ្ទាល់ ឬដោយប្រយោល ជាម្ចាស់កាន់កាប់ប្រាំភាគរយ ឬលើសនៃភាគហ៊ុន ឬភាគដែលមានសិទ្ធិបោះឆ្នោតទាំងសងខាង

ង- ក្នុងចំណោមនោះមានម្នាក់គ្រប់គ្រងដោយផ្ទាល់ ឬដោយប្រយោលលើបុគ្គលម្ខាងទៀត

ច- បុគ្គលទាំងសងខាងត្រូវបានគ្រប់គ្រងដោយផ្ទាល់ ឬដោយប្រយោលពីតតិយជន

ឆ- បុគ្គលទាំងសងខាងរួមគ្នាគ្រប់គ្រងដោយផ្ទាល់ ឬដោយប្រយោលលើតតិយជន

ជ- បុគ្គលទាំងឡាយជាសមាជិកគ្រួសារតែមួយ ។

**ប្រការ ៣.-**

សម្រាប់គោលបំណងនៃប្រកាសនេះ បន្ទុកការប្រាក់ដែលស្ថិតក្រោមកិច្ចព្រមព្រៀងហិរញ្ញវត្ថុ ដែលត្រូវកត់ត្រាដោយអ្នកទិញ ហើយដែលទាក់ទងទៅនឹងការបញ្ជាទិញទំនិញនាំចូល មិនត្រូវបានចាត់ទុកថាជាផ្នែកនៃតម្លៃគិតពន្ធគយទេ នៅពេលដែល ៖

ក- បន្ទុកការប្រាក់នោះត្រូវបានបែងចែកដាច់ដោយឡែកពីថ្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដលើទំនិញ

ខ- ទំនិញទាំងនេះ ត្រូវបានលក់ពិតប្រាកដទៅតាមថ្លៃដែលបានប្រកាសថាជាថ្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដ

គ- កាលបើមានសំណូមពរ អ្នកទិញអាចបង្ហាញថា ៖

១- កិច្ចព្រមព្រៀងហិរញ្ញវត្ថុត្រូវបានធ្វើជាលាយលក្ខណ៍អក្សរ

២- អត្រាការប្រាក់ដែលបានដាក់ស្នើសុំ មិនត្រូវឲ្យលើសពីកម្រិតនៃកិច្ចចម្លងការដែលមានជាធរមាននៅក្នុងប្រទេស និងតាមពេលវេលាដែលធនធានហិរញ្ញវត្ថុត្រូវបានផ្តល់ ។

## ជំពូកទី ២
## តម្លៃចម្លងការ

**ប្រការ ៤.-**

តម្លៃគិតពន្ធគយលើទំនិញនាំចូល គឺជាតម្លៃចម្លងការ មានន័យថា ជាថ្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដ លើទំនិញដែលបានលក់សម្រាប់នាំចេញមកកម្ពុជា ក្រោយពីបានកែតម្រូវស្របតាមបញ្ញត្តិជំពូកទី ៣ នៃប្រកាសនេះ ប្រសិនបើ ៖

ក- គ្មានការរិតត្បិតស្តីពីការចែកចាយ ឬការប្រើប្រាស់ទំនិញដោយអ្នកទិញ ក្រៅពីការរិតត្បិតដែល ៖

១- តម្រូវដោយច្បាប់ ឬដោយអាជ្ញាធរមានសមត្ថកិច្ចរបស់កម្ពុជា

២- កម្រិតមណ្ឌលភូមិសាស្ត្រដែលទំនិញអាចត្រូវបានលក់បន្ត

៣- មិនបណ្តាលឲ្យប៉ះពាល់ដល់តម្លៃទំនិញ ។

ខ- ការលក់ទំនិញ ឬថ្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដចំពោះទំនិញ មិនមែនជាកម្មវត្ថុនៃល័ក្ខខ័ណ្ឌ ឬកត្តាខ្លះដែលនាំឲ្យតម្លៃគិតពន្ធគយមិនអាចកំណត់បានឡើយ ។

គ- ក្នុងពេលដែលទំនិញត្រូវបានលក់សម្រាប់នាំចេញ អ្នកទិញ និងអ្នកលក់ទំនិញមិនមានការពាក់ព័ន្ធគ្នា ឬប្រសិនបើអ្នកទិញ និងអ្នកលក់មានការពាក់ព័ន្ធគ្នា នៅពេលដែលលក់នោះ ត្រូវបង្ហាញថា ៖

១- ការពាក់ព័ន្ធគ្នានោះមិនមានឥទ្ធិពលទៅលើថ្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដ

២- អ្នកនាំចូលបង្ហាញថា តម្លៃចម្លងការនៃទំនិញ ស្របតាមបញ្ញត្តិដែលបានចែងក្នុងប្រការ ៥ នៃជំពូកនេះ ។

**ប្រការ ៥.-**

ក្នុងការលក់រវាងបុគ្គលពាក់ព័ន្ធគ្នា ដើម្បីបង្ហាញថាទំនាក់ទំនងមិនមានឥទ្ធិពលលើតម្លៃចម្លងការ អ្នកនាំចូលត្រូវបង្ហាញកស្តុតាងថា តម្លៃចម្លងការចំពោះទំនិញដែលត្រូវកំណត់តម្លៃគិតពន្ធគយ គៀកជិតទៅនឹងតម្លៃគិតពន្ធគយរបស់ទំនិញផ្សេងទៀត ដែលបាននាំចេញក្នុងពេលដូចគ្នា ឬពេលប្រហាក់ប្រហែលគ្នាទៅនឹងទំនិញដែលត្រូវបានកំណត់តម្លៃ គឺជា ៖

ក- តម្លៃចម្លងការនៃទំនិញដូចគ្នា ឬទំនិញប្រហាក់ប្រហែលគ្នា ចំពោះការលក់ទំនិញទាំងនោះរវាងអ្នកលក់ និងអ្នកទិញដែលមិនពាក់ព័ន្ធគ្នា នៅពេលលក់ទំនិញនោះសម្រាប់នាំចេញមកកម្ពុជា

ខ- តម្លៃអនុមាននៃទំនិញដូចគ្នា ឬប្រហាក់ប្រហែលគ្នា ដែលបានកំណត់ដោយស្របតាមបញ្ញត្តិជំពូកទី ៦ នៃប្រកាសនេះ

គ- តម្លៃគណនានៃទំនិញដូចគ្នា ឬប្រហាក់ប្រហែលគ្នាដែលបានកំណត់ដោយស្របតាមបញ្ញត្តិជំពូកទី ៧ នៃប្រកាសនេះ ។

**ប្រការ ៦.-**

កាលបើការពាក់ព័ន្ធរវាងអ្នកទិញ និងអ្នកលក់ទំនិញត្រូវបានចាត់ថាមានឥទ្ធិពលលើថ្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដ ប្រសិនបើមានការស្នើសុំ រដ្ឋបាលគយត្រូវផ្ដល់ព័ត៌មានទៅអ្នកនាំចូលអំពីមូលហេតុនេះ ជាលាយលក្ខណ៍អក្សរ និងត្រូវផ្ដល់លទ្ធភាពចំពោះអ្នកនាំចូល ដើម្បីបង្ហាញចំពោះរដ្ឋបាលគយវិញថា ការពាក់ព័ន្ធនេះមិនមានឥទ្ធិពលលើថ្លៃឡើយ ។

**ប្រការ ៧.-**

ក្នុងការអនុវត្តបញ្ញត្តិប្រការ ៤ នៃជំពូកនេះ អ្នកនាំចូលត្រូវផ្ដល់ព័ត៌មានដូចខាងក្រោម ៖

ក- ប្រភេទទំនិញដែលត្រូវកំណត់តម្លៃគិតពន្ធគយ

ខ- ប្រភេទឧស្សាហកម្មដែលបានផលិតទំនិញដែលត្រូវកំណត់តម្លៃគិតពន្ធគយ

គ- រដូវកាលដែលទំនិញត្រូវកំណត់តម្លៃគិតពន្ធគយត្រូវបាននាំចូល

ឃ- តើភាពខុសគ្នានៃតម្លៃតាមលក្ខណៈពាណិជ្ជកម្មមានទំហំធំឬទេ

ង- កម្រិតពាណិជ្ជកម្មដែលការលក់បានកើតមានឡើង

ច- កម្រិតបរិមាណនៃការលក់

ឆ- ទឹកប្រាក់ដែលបានចែងស្របតាមបញ្ញត្តិជំពូកទី ៣ នៃប្រកាសនេះ

ជ- ថ្លៃដើម បន្ទុក ឬការចំណាយដែលបានទូទាត់ដោយអ្នកលក់ នៅពេលដែលអ្នកលក់ លក់ទំនិញទៅឲ្យអ្នកទិញដែលមិនពាក់ព័ន្ធគ្នា ហើយការចំណាយទាំងអស់នេះមិនត្រូវបានទូទាត់នៅពេលដែលអ្នកលក់ លក់ទំនិញទៅអ្នកទិញដែលពាក់ព័ន្ធគ្នា ។

**ប្រការ ៨.-**

ប្រសិនបើតម្លៃគិតពន្ធគយនៃទំនិញនាំចូលពុំអាចកំណត់បានស្របតាមបញ្ញត្តិនៃជំពូកនេះ ឬប្រសិនបើរដ្ឋបាលគយមានមូលហេតុនាំឲ្យមានការសង្ស័យពីភាពពិត ឬភាពត្រឹមត្រូវរបស់តម្លៃគិតពន្ធគយដែលបានប្រកាស និងក្រោយពីបានទទួលការពន្យល់បន្ថែមទៀត ឬភស្តុតាងផ្សេងទៀតហើយ ក៏រដ្ឋបាលគយនៅតែ

យល់ថា មិនទាន់គ្រប់គ្រាន់ដើម្បីកំណត់តម្លៃគិតពន្ធដោយស្របតាមបញ្ញត្តិនៃជំពូកនេះបាន នោះរដ្ឋបាលគយអាចកំណត់តម្លៃគិតពន្ធគយលើទំនិញនាំចូល ផ្អែកតាមបញ្ញត្តិមាត្រា ២១ នៃច្បាប់ស្តីពីគយ ដោយអនុវត្តជាបន្តបន្ទាប់ស្របតាមបញ្ញត្តិជំពូកទី ២ ដល់បញ្ញត្តិជំពូកទី ៨ នៃប្រកាសនេះ ហើយត្រូវយកជំពូកណាមួយដំបូងដែលតម្លៃគិតពន្ធគយអាចកំណត់បាន ។

**ប្រការ ៩.-**

ដោយមានសំណូមពរជាលាយលក្ខណ៍អក្សរពីអ្នកនាំចូល លំដាប់នៃការកំណត់មូលដ្ឋានសម្រាប់កំណត់តម្លៃគិតពន្ធគយ ដូចមានចែងនៅក្នុងបញ្ញត្តិជំពូកទី ៦ និងបញ្ញត្តិជំពូកទី ៧ នៃប្រកាសនេះ អាចធ្វើត្រឡប់បានដោយយោងវាក្យខណ្ឌ ច មាត្រា ២១ នៃច្បាប់ស្តីពីគយ ។

## ជំពូកទី ៣
## ការកែតម្រូវលើថ្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដ

**ប្រការ ១០.-**

ដើម្បីកំណត់តម្លៃចម្លងការទំនិញនាំចូលឲ្យស្របតាមបញ្ញត្តិជំពូកទី ២ នៃប្រកាសនេះ ថ្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដសម្រាប់ទំនិញនឹងត្រូវបានកែតម្រូវដូចខាងក្រោម ៖

ក- ដោយបូកបន្ថែម ចំនួនទឹកប្រាក់ទាំងឡាយណាដែលពុំទាន់បានបូកបញ្ចូលទៅក្នុងថ្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដសម្រាប់ទំនិញនាំចូល និងដែលបានកំណត់ដោយមានមូលដ្ឋានព័ត៌មានគ្រប់គ្រាន់នូវទឹកប្រាក់នៃ ៖

១- កម្រៃសេវា និងកម្រៃជើងសារ លើកលែងតែកម្រៃសេវាពីការទិញដែលបានទូទាត់ដោយអ្នកទិញ ក្រៅពីកម្រៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដដោយអ្នកទិញ ចំពោះភ្នាក់ងាររបស់ខ្លួនសម្រាប់សេវាជាតំណាងឲ្យអ្នកទិញនៅក្រៅប្រទេសចំពោះការទិញទំនិញ

២- ថ្លៃ និងបន្ទុកវេចខ្ចប់ដែលបានទូទាត់ដោយអ្នកទិញចំពោះទំនិញ រួមទាំងថ្លៃសំបក កាតុង កេស និងប្រដាប់សម្រាប់ដាក់ ប្រដាប់បាំងគ្រប់ផ្សេងទៀតដែលរដ្ឋបាលគយចាត់ទុកថាជាផ្នែកនៃទំនិញនាំចូលនោះ និងចំណាយវេចខ្ចប់ផ្សេងៗទៀតក្នុងការទុកដាក់ទំនិញ ក្នុងស្ថានភាពដែលទំនិញនោះត្រូវដឹកជញ្ជូនមកកម្ពុជា ។

៣- តម្លៃទំនិញ និងសេវាណាមួយដែលមានចែងដូចខាងក្រោម ៖

៣.១- សម្ភារៈ ភាគបន្សំ ភាគ និងទំនិញផ្សេងទៀតដែលត្រូវភ្ជាប់ជាមួយទំនិញនាំចូល

៣.២- ឧបករណ៍ ពុម្ព (Dies) ពុម្ពចាក់ និងទំនិញផ្សេងទៀតដែលប្រើប្រាស់ក្នុងការផលិតទំនិញនាំចូល

៣.៣- សម្ភារៈដែលប្រើប្រាស់ក្នុងការផលិតទំនិញនាំចូល

៣.៤- ស្នាដៃវិស្វកម្ម ស្នាដៃអភិវឌ្ឍន៍ ស្នាដៃសិល្បៈ ស្នាដៃគំនូស ប្លង់ និងគំនូសវាស ដែលបានធ្វើនៅក្រៅប្រទេសកម្ពុជា និងដែលត្រូវការចាំបាច់សម្រាប់ការផលិតទំនិញនាំចូល ។

តម្លៃទាំងនេះត្រូវបានកំណត់ស្របតាមបញ្ញត្តិប្រការ ១១ នៃប្រកាសនេះ ហើយទំនិញ និងសេវាទាំងនេះត្រូវបានផ្តល់ដោយផ្ទាល់ ឬដោយប្រយោល ដោយអ្នកទិញ ដោយមិនគិតថ្លៃ ឬដោយបន្ថយថ្លៃ សម្រាប់ការប្រើប្រាស់ទាក់ទងទៅនឹងការផលិត និងការលក់សម្រាប់នាំចេញនូវទំនិញនាំចូលនោះ ព្រមទាំងបានបែងចែកចំពោះទំនិញនាំចូលតាមរបៀបសមហេតុផល និងស្របតាមគោលការណ៍គណនេយ្យទូទៅដែលអាចទទួលយកបាន ។

៤- កម្រៃសួយសារ និងកម្រៃអាជ្ញាប័ណ្ណ រួមទាំងការទូទាត់សម្រាប់ប្រកាសនីយប័ត្រតក្កកម្ម ពាណិជ្ជសញ្ញា និងសិទ្ធិអ្នកនិពន្ធ ចំពោះទំនិញនាំចូលដែលអ្នកទិញត្រូវទូទាត់ដោយផ្ទាល់ ឬដោយប្រយោលតាមល័ក្ខខ័ណ្ឌនៃការលក់ទំនិញនាំចេញមកកម្ពុជា ដោយលើកលែងបន្ទុកសម្រាប់សិទ្ធិផលិតឡើងវិញនៅកម្ពុជានូវទំនិញដែលបាននាំចូល ។

៥- តម្លៃនៃភាគណាមួយនៃផលដែលបានមកពីការលក់បន្ត ការចែកចាយ ការប្រើប្រាស់ទំនិញដោយអ្នកទិញដែលត្រូវ ឬនឹងត្រូវផ្ញើត្រឡប់ដោយផ្ទាល់ ឬដោយប្រយោលទៅអ្នកលក់វិញ ។

៦- ថ្លៃដឹកជញ្ជូននិងធានារ៉ាប់រង ថ្លៃលើកដាក់ ថ្លៃសហត្ថកម្ម ថ្លៃចំណាយផ្សេងៗ និងចំណាយរួមផ្សំជាមួយនឹងការដឹកជញ្ជូនទំនិញនាំចូលរហូតមកដល់កម្ពុជា ។

ខ- ដោយដកចេញនូវទឹកប្រាក់នៃថ្លៃ បន្ទុក ឬចំណាយណាមួយដែលបានបែងដាច់ដោយឡែកពីតម្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដ ៖

១- ថ្លៃ បន្ទុក ឬចំណាយសមហេតុផលសម្រាប់ការសាងសង់ ការផ្គុំតម្លើង ការថែទាំ ឬជំនួយបច្ចេកទេស ដែលបានផ្តល់ចំពោះទំនិញក្រោយការនាំចូល ។

២- ថ្លៃ បន្ទុក ឬចំណាយសមហេតុផលសម្រាប់ការដឹកជញ្ជូន ឬធានារ៉ាប់រងទំនិញនៅកម្ពុជា និងរាល់ថ្លៃ បន្ទុក ឬចំណាយពាក់ព័ន្ធ ។

៣- ពន្ធគយ ឬអាករផ្សេង ៗ ដែលនឹងត្រូវទូទាត់នៅកម្ពុជា ។

**ប្រការ ១១.-**

តម្លៃទំនិញ និងសេវាដែលបានចែងនៅវាក្យខណ្ឌទី ៣ កថាខណ្ឌ ក ប្រការ ១០ នៃប្រកាសនេះត្រូវបានកំណត់ដូចខាងក្រោម ៖

ក- ចំពោះសម្ភារៈ ភាគបន្សំ ភាគ និងទំនិញផ្សេងទៀតដែលត្រូវភ្ជាប់ជាមួយទំនិញនាំចូលដែលត្រូវកំណត់តម្លៃ ឬចំពោះសម្ភារៈដែលបានប្រើប្រាស់ក្នុងការផលិតទំនិញដែលត្រូវកំណត់តម្លៃ ៖

១- ដោយបញ្ជាក់ថា ៖

១.១- ថ្លៃទិញដោយអ្នកទិញពីបុគ្គលដែលមិនពាក់ព័ន្ធជាមួយនឹងអ្នកទិញនៅពេលដែលមានការទិញនោះ ឬ

១.២- ថ្លៃទិញដែលបានទូទាត់ដោយបុគ្គលពាក់ព័ន្ធជាមួយអ្នកទិញដែលទំនិញត្រូវបានទិញដោយអ្នកទិញ ពីបុគ្គលដែលមានការពាក់ព័ន្ធជាមួយអ្នកទិញ ប៉ុន្តែមិនមែនជាអ្នកផលិតទេ នៅពេលទិញនោះ ឬ

១.៣- ថ្លៃដើមនៃការផលិតទំនិញ និងសេវាដែលផលិតដោយអ្នកទិញ ឬដោយបុគ្គលដែលពាក់ព័ន្ធជាមួយអ្នកទិញនៅពេលផលិតទំនិញ ឬសេវានោះ ។

២- ដោយបូកបន្ថែម ៖

២.១- ថ្លៃដឹកជញ្ជូនទំនិញនោះទៅកន្លែងផលិតទំនិញដែលត្រូវកំណត់តម្លៃ

២.២- តម្លៃបន្ថែមលើទំនិញ ដែលបានពីការជួសជុល ឬការកែសម្រួលក្រោយពីបានទិញ ឬបានផលិត ។

ខ- ចំពោះឧបករណ៍ ពុម្ព (Dies) ពុម្ពចាក់ និងទំនិញផ្សេងទៀតដែលបានប្រើប្រាស់នៅក្នុងការផលិតទំនិញដែលត្រូវកំណត់តម្លៃ ៖

១- ដោយបញ្ជាក់ថា ៖

១.១- ថ្លៃទិញដោយអ្នកទិញ ពីបុគ្គលដែលមិនពាក់ព័ន្ធជាមួយនឹងអ្នកទិញ នៅពេលដែលមានការទិញនោះ ។

១.២-ថ្លៃទិញ ដែលបានទូទាត់ដោយបុគ្គលពាក់ព័ន្ធជាមួយអ្នកទិញ ដែលទំនិញត្រូវបានទិញដោយអ្នកទិញពីបុគ្គលដែលមានពាក់ព័ន្ធជាមួយអ្នកទិញ ប៉ុន្តែមិនមែនជាអ្នកផលិតទេ នៅពេលទិញនោះ ។

១.៣- ថ្លៃដើមនៃការផលិតទំនិញ និងសេវាដែលផលិតដោយអ្នកទិញ ឬដោយបុគ្គលដែលពាក់ព័ន្ធជាមួយអ្នកទិញនៅពេលផលិតទំនិញ ឬសេវានោះ ។

២- ដោយបូកបន្ថែម ៖

២.១- ថ្លៃដឹកជញ្ជូនទំនិញនោះទៅដល់កន្លែងផលិតទំនិញដែលត្រូវកំណត់តម្លៃ ។

២.២- តម្លៃបន្ថែមលើទំនិញ ដែលបានចំណាយលើការជួសជុល ឬការកែសម្រួលក្រោយពីបានទិញ ឬបានផលិត ។

៣- ដោយដកចេញនូវទឹកប្រាក់រំលោះនៃការប្រើប្រាស់ទំនិញពីមុនណាមួយក្រោយពេលដែលទំនិញណាមួយត្រូវបានទិញ ឬផលិត ។

គ- ចំពោះស្នាដៃវិស្វកម្ម ស្នាដៃអភិវឌ្ឍន៍ ស្នាដៃសិល្បៈ ស្នាដៃគំនូស ប្លង់ និងគំនូសវាសដែលបានធ្វើនៅក្រៅកម្ពុជា និងដែលត្រូវការចាំបាច់សម្រាប់ការផលិតទំនិញដែលត្រូវកំណត់តម្លៃ ដោយត្រូវបញ្ជាក់ ៖

១- ថ្លៃទិញ ជួល ឬផ្ទេរដោយអ្នកទិញ ជួល ឬផ្ទេរ ពីបុគ្គលដែលមិនពាក់ព័ន្ធនឹងអ្នកទិញ ជួល ឬផ្ទេរ និងមិនមែនសម្រាប់សាធារណជនទូទៅ ។

២- ថ្លៃទិញ ជួល ឬផ្ទេរដែលបានទូទាត់ដោយបុគ្គលដែលពាក់ព័ន្ធជាមួយអ្នកទិញ ជួល ឬផ្ទេរ ដែលទំនិញត្រូវបានទិញ ជួល ឬផ្ទេរ ដែលទំនិញ ឬសេវាខាងលើត្រូវបានទិញ ជួល ឬផ្ទេរដោយអ្នកទិញ ពីបុគ្គលដែលពាក់ព័ន្ធជាមួយអ្នកទិញ ប៉ុន្តែមិនមែនជាអ្នកផលិតទំនិញនោះ និងមិនមែនសម្រាប់សាធារណជនទូទៅ ។

៣- ថ្លៃសម្រាប់សាធារណជន ដើម្បីទទួលបានទំនិញ ឬសេវានោះដែលសម្រាប់សាធារណជនទូទៅ ។

៤- ថ្លៃផលិត កាលបើទំនិញនោះត្រូវបានផលិតដោយអ្នកទិញ ឬដោយបុគ្គលពាក់ព័ន្ធជាមួយអ្នកទិញនាពេលផលិតទំនិញនោះ ។

**ប្រការ ១២.-**

នៅពេលដែលការកែតម្រូវមិនអាចធ្វើបានស្របតាមបញ្ញត្តិជំពូកនេះ ដោយខ្វះព័ត៌មានគ្រប់គ្រាន់នោះ តម្លៃចម្លងការនៃទំនិញដែលត្រូវកំណត់តម្លៃគិតពន្ធគយមិនអាចត្រូវបានកំណត់ស្របតាមបញ្ញត្តិជំពូកទី ២ នៃប្រកាសនេះ ។

## ជំពូកទី ៤
## តម្លៃចម្លងការនៃទំនិញដូចគ្នា

**ប្រការ ១៣.-**

ប្រសិនបើតម្លៃគិតពន្ធគយនៃទំនិញនាំចូលពុំអាចត្រូវបានកំណត់ក្រោមបញ្ញត្តិនានាដែលបានចែងក្នុងជំពូកទី ២ នៃប្រកាសនេះ តម្លៃគិតពន្ធគយនៃទំនិញនាំចូលគឺជាតម្លៃចម្លងការនៃទំនិញដូចគ្នា ដែលបានលក់សម្រាប់នាំចេញមកកម្ពុជា ប្រសិនបើតម្លៃចម្លងការនោះគឺជាតម្លៃគិតពន្ធគយនៃទំនិញដូចគ្នា ហើយទំនិញដូច

គ្នានោះត្រូវបាននាំចេញនៅពេលដូចគ្នា ឬនៅពេលស្មើរតែជាមួយគ្នាទៅនឹងទំនិញដែលត្រូវកំណត់តម្លៃ និងត្រូវបានលក់ក្នុងល័ក្ខខ័ណ្ឌដូចខាងក្រោម ៖

ក-លក់ទៅឲ្យអ្នកទិញទំនិញក្នុងកម្រិតពាណិជ្ជកម្មដូចគ្នា ឬស្មើរតែដូចគ្នាទៅនឹងកម្រិតពាណិជ្ជ កម្ម របស់អ្នកទិញទំនិញដែលត្រូវកំណត់តម្លៃ ។

ខ- មានបរិមាណដូចគ្នាឬស្មើរតែដូចគ្នាទៅនឹងទំនិញដែលត្រូវកំណត់តម្លៃ ។

**ប្រការ ១៤.-**

ប្រសិនបើតម្លៃគិតពន្ធគយនៃទំនិញនាំចូលពុំអាចត្រូវបានកំណត់ក្រោមបញ្ញត្តិប្រការ ១៣ នៃប្រកាសនេះ ដោយមូលហេតុទំនិញដូចគ្នាមិនត្រូវបានលក់ក្រោមល័ក្ខខ័ណ្ឌដូចមានចែងក្នុងកថាខណ្ឌ ក និងកថាខណ្ឌ ខ នៃប្រការ ១៣ នៃប្រកាសនេះ តម្លៃគិតពន្ធគយត្រូវជំនួសដោយតម្លៃនៃទំនិញដូចគ្នា ដែលបានលក់ក្នុងល័ក្ខខ័ណ្ឌណាមួយដូចខាងក្រោម ៖

ក- លក់ទៅឲ្យអ្នកទិញក្នុងកម្រិតពាណិជ្ជកម្មដូចគ្នា ឬស្មើរតែដូចគ្នាទៅនឹងកម្រិតពាណិជ្ជកម្មរបស់អ្នកទិញទំនិញដែលត្រូវកំណត់តម្លៃ ប៉ុន្តែទំនិញមានបរិមាណខុសគ្នាពីបរិមាណនៃទំនិញដែលត្រូវបានលក់ ។

ខ- លក់ឲ្យអ្នកទិញក្នុងកម្រិតពាណិជ្ជកម្មខុសគ្នា ពីកម្រិតពាណិជ្ជកម្មរបស់អ្នកទិញទំនិញដែលត្រូវកំណត់តម្លៃ ប៉ុន្តែមានបរិមាណដូចគ្នា ឬស្មើរតែដូចគ្នាទៅនឹងបរិមាណទំនិញដែលត្រូវបានលក់ ។

គ- លក់ឲ្យអ្នកទិញក្នុងកម្រិតពាណិជ្ជកម្មខុសគ្នា ពីកម្រិតពាណិជ្ជកម្មរបស់អ្នកទិញទំនិញដែលត្រូវកំណត់តម្លៃ និងមានបរិមាណខុសគ្នាពីបរិមាណទំនិញដែលត្រូវបានលក់ ។

**ប្រការ ១៥.-**

សម្រាប់គោលបំណងនៃការកំណត់តម្លៃគិតពន្ធគយ នៃទំនិញនាំចូលក្រោមបញ្ញត្តិប្រការ ១៣ នៃប្រកាសនេះ តម្លៃចម្លងការនៃទំនិញដូចគ្នាត្រូវបានកែតម្រូវដោយបូកបន្ថែម ឬបន្ថយនូវទឹកប្រាក់ដែលបានមកពី ៖

ក- ភាពខុសគ្នាគួរឲ្យកត់សម្គាល់ក្នុងលក្ខណៈពាណិជ្ជកម្មរវាងថ្លៃ បន្ទុក និងចំណាយនានាពាក់ព័ន្ធនឹងបញ្ញត្តិវាក្យខណ្ឌទី ៦ កថាខណ្ឌ ក ប្រការ ១០ នៃប្រកាសនេះ ដែលកើតឡើងចំពោះទំនិញដូចគ្នាទៅនឹងថ្លៃ បន្ទុក និងចំណាយចំពោះទំនិញដែលត្រូវកំណត់តម្លៃ ដោយមកពីភាពខុសគ្នានៃចម្ងាយផ្លូវ និងប្រភេទនៃការដឹកជញ្ជូន ។

ខ- ប្រសិនបើតម្លៃចម្លងការនៃទំនិញដូចគ្នា ត្រូវបានលក់ក្រោមល័ក្ខខ័ណ្ឌដូចបានចែងក្នុងកថាខណ្ឌណាមួយ ពីកថាខណ្ឌ ក ដល់កថាខណ្ឌ គ ប្រការ ១៤ នៃប្រកាសនេះ ភាពខុសគ្នារវាងកម្រិតពាណិជ្ជកម្មរបស់អ្នកទិញទំនិញដូចគ្នា និងកម្រិតពាណិជ្ជកម្មនៃទំនិញត្រូវកំណត់តម្លៃ ឬក៏ភាពខុសគ្នារវាងបរិមាណទំនិញដូចគ្នាជាមួយនឹងបរិមាណនៃទំនិញដែលត្រូវកំណត់តម្លៃត្រូវបានលក់ ឬក៏មានភាពខុសគ្នាទាំងពីរយ៉ាងដូចបានរៀបរាប់ កាលបើទឹកប្រាក់នីមួយៗ អាចកំណត់បានដោយផ្អែកតាមព័ត៌មានគ្រប់គ្រាន់ ។ ប្រសិនបើមានទឹកប្រាក់ណាមួយមិនអាចកំណត់បាន តម្លៃគិតពន្ធគយនៃទំនិញដែលត្រូវកំណត់តម្លៃនឹងមិនត្រូវបានកំណត់តាមតម្លៃចម្លងការ នៃទំនិញដូចគ្នា ដូចបានចែងក្នុងជំពូកនេះទេ ។

**ប្រការ ១៦**.-

ប្រសិនបើមានតម្លៃចម្លងការពីរ ឬច្រើននៃទំនិញដូចគ្នា ដែលទាក់ទងទៅនឹងទំនិញនាំចូលដែលត្រូវកំណត់តម្លៃ ដែលស្របទាំងស្រុងតាមបញ្ញត្តិប្រការ ១៣ និងប្រការ ១៤ នៃប្រកាសនេះ ឬប្រសិនបើគ្មានតម្លៃចម្លងការបែបនេះ ប៉ុន្តែមានតម្លៃចម្លងការពីរ ឬច្រើននៃទំនិញដូចគ្នា ដែលត្រូវបានលក់ក្រោមល័ក្ខខ័ណ្ឌដូចមានចែងក្នុងកថាខណ្ឌណាមួយនៃ កថាខណ្ឌ ក ដល់កថាខណ្ឌ គ ប្រការ ១៤ នៃប្រកាសនេះ ហើយស្របទាំងស្រុងតាមបញ្ញត្តិដែលមានចែងក្នុងជំពូកនេះ ហើយដែលអាចអនុវត្តបានស្របតាមបញ្ញត្តិប្រការ ១៤ នៃប្រកាសនេះ តម្លៃគិតពន្ធគយនៃទំនិញដែលត្រូវកំណត់តម្លៃ ត្រូវកំណត់ដោយផ្អែកតាមតម្លៃទាបបំផុតនៃតម្លៃចម្លងការនៃទំនិញដូចគ្នា ។

## ជំពូកទី ៥
## តម្លៃចម្លងការនៃទំនិញប្រហាក់ប្រហែលគ្នា

**ប្រការ ១៧.-**

ប្រសិនបើតម្លៃគិតពន្ធគយនៃទំនិញនាំចូលមិនអាចកំណត់បានតាមបញ្ញត្តិប្រការ ១៤ ដល់ប្រការ ១៦ ជំពូកទី ៤ និងប្រការ ១៨ ជំពូកទី ៥ នៃប្រកាសនេះ តម្លៃគិតពន្ធគយ គឺជាតម្លៃចម្លងការនៃទំនិញប្រហាក់ប្រហែលគ្នា ដែលបានលក់សម្រាប់នាំចេញមកកម្ពុជា ប្រសិនបើតម្លៃចម្លងការគឺជាតម្លៃគិតពន្ធគយនៃទំនិញប្រហាក់ប្រហែលគ្នា ហើយទំនិញប្រហាក់ប្រហែលគ្នានេះត្រូវបាននាំចេញនៅពេលដូចគ្នា ឬនៅពេលស្ទើរតែជាមួយគ្នាទៅនឹងទំនិញដែលត្រូវកំណត់តម្លៃ និងត្រូវបានលក់ក្នុងល័ក្ខខ័ណ្ឌដូចខាងក្រោម ៖

ក- លក់ទៅឲ្យអ្នកទិញទំនិញក្នុងកម្រិតពាណិជ្ជកម្មដូចគ្នា ឬស្ទើរតែដូចគ្នាទៅនឹងកម្រិតពាណិជ្ជកម្មរបស់អ្នកទិញទំនិញដែលត្រូវកំណត់តម្លៃ ។

ខ-មានបរិមាណដូចគ្នាឬស្ទើរតែដូចគ្នាទៅនឹងទំនិញដែលត្រូវកំណត់តម្លៃ។

**ប្រការ ១៨.-**

បញ្ញត្តិប្រការ ១៤ ដល់ប្រការ ១៦ ជំពូកទី ៤ នៃប្រកាសនេះ ត្រូវអនុវត្តផងដែរនៅក្នុងជំពូកនេះ ចំពោះទំនិញប្រហាក់ប្រហែលគ្នា ដោយរាល់ការចែងក្នុងប្រការទាំងនោះអំពី "ទំនិញដូចគ្នា" គឺជាការយោងសម្រាប់ទំនិញ "ប្រហាក់ប្រហែលគ្នា" ។

## ជំពូកទី ៦
## តម្លៃអនុមាន

**ប្រការ ១៩.-**

ប្រសិនបើតម្លៃគិតពន្ធគយមិនអាចកំណត់បានស្របតាមបញ្ញត្តិជំពូកទី ៥ នៃប្រកាសនេះ តម្លៃគិតពន្ធគយនៃទំនិញនាំចូលគឺជា តម្លៃអនុមាន ។

**ប្រការ ២០.-**

ប្រសិនបើទំនិញដែលត្រូវកំណត់តម្លៃគិតពន្ធគយ ឬទំនិញដូចគ្នា ឬទំនិញប្រហាក់ប្រហែលគ្នា ត្រូវបានលក់នៅកម្ពុជាក្នុងសភាពដែលបាននាំចូលនៅពេលដូចគ្នា ឬស្ទើរតែដូចគ្នាទៅនឹងពេលនៃការនាំចូលទំនិញដែលត្រូវកំណត់តម្លៃ តម្លៃអនុមាននៃទំនិញដែលត្រូវកំណត់តម្លៃ គឺជាថ្លៃឯកតានៃការលក់ដូចបានចែងក្នុងបញ្ញត្តិប្រការ ២៣ នៃប្រកាសនេះ ដែលបានកំណត់ស្របតាមប្រការនោះ និងត្រូវបានកែតម្រូវស្របតាមបញ្ញត្តិប្រការ ២៤ នៃប្រកាសនេះ ដោយយកចំនួនច្រើនបំផុតនៃឯកតាទំនិញដែលត្រូវកំណត់តម្លៃ ឬទំនិញដូចគ្នា ឬទំនិញប្រហាក់ប្រហែលគ្នា ដែលបានលក់ក្នុងសភាពដូចគ្នា ។

**ប្រការ ២១.-**

ប្រសិនបើទំនិញដែលត្រូវកំណត់តម្លៃគិតពន្ធគយ ឬទំនិញដូចគ្នា ឬទំនិញប្រហាក់ប្រហែលគ្នា ត្រូវបានលក់ក្នុងប្រទេសកម្ពុជាក្នុងសភាពដែលត្រូវបាននាំចូលមុនផុតសុពលភាព ៩០ ថ្ងៃបន្ទាប់ពីការនាំចូលទំនិញដែលត្រូវកំណត់តម្លៃ ប៉ុន្តែមិនបានលក់នៅពេលជាមួយគ្នានៃការនាំចូលនោះទេ តម្លៃអនុមាននៃទំនិញដែលត្រូវកំណត់តម្លៃគឺជាថ្លៃឯកតានៃការលក់ ដូចបានចែងក្នុងបញ្ញត្តិប្រការ ២៣ នៃប្រកាសនេះ ហើយដែលត្រូវបានកំណត់ស្របទៅតាមប្រការនោះ និងត្រូវបានកែតម្រូវស្របតាមបញ្ញត្តិប្រការ ២៤ នៃប្រកាសនេះ និងដែលមានចំនួនឯកតាទំនិញច្រើនបំផុតនៃទំនិញដែលត្រូវកំណត់តម្លៃ ឬក៏ទំនិញដូចគ្នា ឬទំនិញប្រហាក់ប្រហែលគ្នា ត្រូវបានលក់នៅថ្ងៃដំបូងបំផុតបន្ទាប់ពីការនាំចូលនៃទំនិញដែលត្រូវកំណត់តម្លៃ ។

**ប្រការ ២២.-**

ប្រសិនបើទំនិញដែលត្រូវកំណត់តម្លៃគិតពន្ធគយ ឬទំនិញដូចគ្នា ឬទំនិញប្រហាក់ប្រហែលគ្នា មិនត្រូវបានលក់នៅក្នុងប្រទេសកម្ពុជា ក្នុងស្ថានភាពដូចមានចែងក្នុងបញ្ញត្តិប្រការ ២០ ឬ បញ្ញត្តិ ប្រការ ២១ នៃប្រកាសនេះទេ ប៉ុន្តែបន្ទាប់ពីការវេចខ្ចប់ជាបន្តបន្ទាប់ ឬបានកែច្នៃបន្ថែមនៅក្នុងប្រទេសកម្ពុជា ទំនិញដែលត្រូវកំណត់តម្លៃត្រូវបានលក់ក្នុងប្រទេសកម្ពុជានៅមុនផុតសុពលភាព ៩០ ថ្ងៃបន្ទាប់ពី

ការនាំចូល ហើយអ្នកនាំចូលទំនិញដែលត្រូវកំណត់តម្លៃគិតពន្ធគយបានស្នើឲ្យអនុវត្តតាមប្រការនេះក្នុងការកំណត់តម្លៃគិតពន្ធគយនៃទំនិញនោះ តម្លៃអនុមាននៃទំនិញដែលត្រូវកំណត់តម្លៃគឺជាថ្លៃឯកតា ដោយផ្អែកទៅលើការលក់ដែលបានចែងក្នុងបញ្ញត្តិប្រការ ២៣ នៃប្រកាសនេះ ដែលត្រូវបានកំណត់ស្របទៅតាមប្រការនោះ និងកែតម្រូវស្របតាមបញ្ញត្តិប្រការ ២៤ នៃប្រកាសនេះ ដែលតាមនេះចំនួនដ៏ច្រើនបំផុតនៃឯកតាទំនិញដែលត្រូវកំណត់តម្លៃ ត្រូវបានលក់ក្នុងសភាពដូចគ្នា ។

**ប្រការ ២៣.-**

សម្រាប់គោលបំណងបញ្ញត្តិប្រការ ២០ បញ្ញត្តិប្រការ ២១ និងបញ្ញត្តិប្រការ ២២ នៃប្រកាសនេះ ថ្លៃឯកតានៃទំនិញណាមួយដែលត្រូវកំណត់តម្លៃ ឬទំនិញដូចគ្នា ឬទំនិញប្រហាក់ប្រហែលគ្នាត្រូវបានកំណត់ដោយបញ្ជាក់ថ្លៃឯកតានៃការលក់ទំនិញនៅក្នុងកម្រិតពាណិជ្ជកម្មដំបូងបង្អស់ បន្ទាប់ពីការនាំចូលចំពោះបុគ្គលដែល ៖

ក-មិនពាក់ព័ន្ធនឹងបុគ្គលដែលលក់ទំនិញនៅពេលដែលទំនិញត្រូវបានលក់

ខ- មិនបានផ្គត់ផ្គង់ទំនិញ ឬសេវាកម្មណាមួយដែលមានចែងនៅវាក្យខណ្ឌទី ៣ កថាខណ្ឌ ក ប្រការ ១០ នៃប្រកាសនេះដោយផ្ទាល់ ឬដោយប្រយោល ដោយមិនគិតថ្លៃ ឬបញ្ចុះថ្លៃ សម្រាប់ប្រើប្រាស់ក្នុងការផលិត និងការលក់ទំនិញសម្រាប់នាំចេញ ។

ខ្លឹមសារដូចបានចែងក្នុងកថាខណ្ឌ ក និងកថាខណ្ឌ ខ នៃប្រការនេះត្រូវបានធ្វើឡើងតាមចំនួនឯកតាទំនិញច្រើនបំផុតដែលត្រូវបានលក់ ក្នុងករណីដែលការលក់នេះមានចំនួនគ្រប់គ្រាន់ អាចអនុញ្ញាតឲ្យកំណត់ថ្លៃឯកតារបស់ទំនិញបាន ។

**មាត្រា ២៤.-**

សម្រាប់គោលបំណងបញ្ញត្តិប្រការ ២០ បញ្ញត្តិប្រការ ២១ និង បញ្ញត្តិប្រការ ២២ នៃប្រកាស នេះថ្លៃឯកតានៃទំនិញដែលត្រូវកំណត់តម្លៃ ឬទំនិញដូចគ្នា

ឬទំនិញប្រហាក់ប្រហែលគ្នាត្រូវបានកែតម្រូវ ដោយដកចេញនូវចំនួនទឹកប្រាក់ស្មើនឹងផលបូកនៃ ៖

ក- ចំនួនទឹកប្រាក់ដែលកំណត់តាមបញ្ញត្តិប្រការ ២៥ នៃប្រកាសនេះ សម្រាប់ការលក់ទំនិញស្ថិតក្នុងក្រុម ឬប្រភេទដូចគ្នានៅកម្ពុជា ដែលស្មើនឹង ៖

១- ទឹកប្រាក់កម្រៃជើងសារដែលជាទូទៅទទួលបានលើមូលដ្ឋានមួយឯកតា

២- ទឹកប្រាក់ចំណេញ និងចំណាយទូទៅ ដោយរួមទាំងថ្លៃស្វែងរកទីផ្សារ ដែលត្រូវសរុបបញ្ចូលតែមួយ ហើយជាទូទៅផ្អែកលើមូលដ្ឋានមួយឯកតា ។

ខ- ថ្លៃ បន្ទុក និងចំណាយសមស្របនានា ដែលបានបង់សម្រាប់ការដឹកជញ្ជូន និងការធានារ៉ាប់រងទំនិញនៅកម្ពុជា និងទឹកប្រាក់ដែលមិនទាន់បានដកពីចំណាយទូទៅដែលមានចែងក្នុងកថាខណ្ឌ ក នៃប្រការនេះ ។

គ- ពន្ធគយ និងអាករផ្សេង ៗ ដែលត្រូវបង់នៅកម្ពុជា ប្រសិនបើទឹកប្រាក់នេះមិនទាន់បានដកពីចំណាយទូទៅដែលមានចែងក្នុងកថាខណ្ឌ ក នៃប្រការនេះទេ ។

ឃ- ទឹកប្រាក់ចំណាយលើការតម្លើង ការវេចខ្ចប់ ឬការកែច្នៃបន្ថែមនៅកម្ពុជានៃទំនិញដូចមានចែងក្នុងបញ្ញត្តិប្រការ ២២ នៃប្រកាសនេះ ប្រសិនបើទឹកប្រាក់នោះត្រូវបានកំណត់ដោយមានមូលដ្ឋានព័ត៌មានគ្រប់គ្រាន់ ។

**ប្រការ ២៥.-**

ទឹកប្រាក់ដែលចាត់ទុកថាស្មើនឹងទឹកប្រាក់កម្រៃសេវា ឬប្រាក់ចំណេញ និងចំណាយទូទៅ ដោយស្របតាមកថាខណ្ឌ ក ប្រការ ២៤ នៃប្រកាសនេះ ត្រូវគណនាលើមូលដ្ឋានជាភាគរយ និងត្រូវកំណត់ដោយផ្អែកលើមូលដ្ឋានព័ត៌មានដែលបានរៀបចំ ស្របជាមួយនឹងគោលការណ៍គណនេយ្យទូទៅដែលអាចទទួលយកបាន ដែលផ្តល់ឲ្យដោយ ឬក្នុងនាមអ្នកនាំចូលទំនិញដែលត្រូវកំណត់តម្លៃ ឬប្រសិនបើព័ត៌មានដែលផ្តល់មកនោះមិនគ្រប់គ្រាន់ ការពិនិត្យចំពោះការលក់នៅកម្ពុជានៃក្រុមទំនិញដែលនៅជិតគ្នាបំផុតនៃទំនិញដែលស្ថិតនៅក្នុងចំណាត់ថ្នាក់ ឬប្រភេទដូចគ្នាទៅនឹងទំនិញដែលត្រូវបានកំណត់តម្លៃ ហើយដែលមានព័ត៌មានគ្រប់

គ្រាន់ពាក់ព័ន្ធនឹងទឹកប្រាក់កម្រៃសេវា ឬទឹកប្រាក់ចំណេញ និងចំណាយទូទៅ ស្រប តាមកថាខណ្ឌ ក ប្រការ ២៤ នៃប្រកាសនេះជាការចាំបាច់ ។

**ប្រការ ២៦**.-

ប្រសិនបើទឹកប្រាក់ដូចមានចែងនៅក្នុងកថាខណ្ឌ ឃ ប្រការ ២៤ នៃ ប្រកាសនេះ នៃទំនិញដែលត្រូវកំណត់តម្លៃ មិនអាចកំណត់បាន ដោយផ្អែកលើ មូលដ្ឋានព័ត៌មានគ្រប់គ្រាន់ តម្លៃគិតពន្ធគយនៃទំនិញមិនត្រូវកំណត់លើមូលដ្ឋាន នៃវិធីសាស្ត្រអនុមានក្រោមបញ្ញត្តិប្រការ ២២ នៃប្រកាសនេះទេ ។

## ជំពូកទី ៧

## តម្លៃគណនា

**ប្រការ ២៧**.-

ប្រសិនបើតម្លៃគិតពន្ធគយនៃទំនិញនាំចូលពុំអាចត្រូវបានកំណត់ក្រោម បញ្ញត្តិជំពូកទី ៦ នៃប្រកាសនេះ តម្លៃគិតពន្ធគយនៃទំនិញនាំចូលគឺជាតម្លៃ គណនានៃទំនិញទាំងនោះ ។

**ប្រការ ២៨** .-

តម្លៃគណនានៃទំនិញដែលត្រូវបានកំណត់តម្លៃ គឺជាផលបូកនៃទឹក ប្រាក់ ៖

ក- ថ្លៃ បន្ទុក និងចំណាយដែលកើតមានឡើង ឬតម្លៃនៃ ៖

១- វត្ថុធាតុដែលប្រើដើម្បីផលិតទំនិញដែលត្រូវកំណត់តម្លៃ

២- ថ្លៃផលិត ឬការកែច្នៃផ្សេងទៀតនៃទំនិញដែលត្រូវកំណត់តម្លៃ ដែល កំណត់ដោយផ្អែកលើមូលដ្ឋាននៃគណនីពាណិជ្ជកម្មរបស់ផលិតករ ឬព័ត៌មាន គ្រប់គ្រាន់ដទៃទៀត ដែលទាក់ទងទៅនឹងការផលិតទំនិញដែលត្រូវកំណត់តម្លៃ ដែលបានផ្តល់ដោយ ឬក្នុងនាមអ្នកផលិតទំនិញដែលស្របជាមួយនឹងគោលការណ៍ គណនេយ្យទូទៅដែលអាចទទួលយកបាននៃប្រទេសផលិតទំនិញដែលត្រូវកំណត់

តម្លៃ ដោយមិនរាប់បញ្ចូលនូវចំណាយដូចមានចែងនៅវាក្យខ័ណ្ឌទី ៣ វាក្យខ័ណ្ឌទី ៤ និងវាក្យខ័ណ្ឌទី ៥ កឋាខ័ណ្ឌ ក នៃប្រការ នេះ ។

៣- ថ្លៃ បន្ទុក និងចំណាយដូចដែលមានចែងក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌ ក ប្រការ ១០ នៃ ប្រកាសនេះ ។

៤- តម្លៃនៃទំនិញ និងសេវាណាមួយ ដែលមានចែងក្នុងវាក្យខណ្ឌ ៣ កថាខណ្ឌ ក ប្រការ ១០ នៃប្រកាសនេះ ដែលត្រូវបានកំណត់តាមសមមាត្រនៃទំនិញដែលត្រូវកំណត់តម្លៃ ដូចដែលមានចែងនៅក្នុងជំពូកទី ៣ ទោះជាទំនិញ និងសេវានោះត្រូវបានផ្គត់ផ្គង់ដោយមិនគិតថ្លៃ ឬដោយបន្ថយថ្លៃក៏ដោយ ។

៥- ថ្លៃ បន្ទុក និងចំណាយដែលបានទូទាត់ដោយផលិតករ សម្រាប់ស្នាដៃវិស្វកម្ម ស្នាដៃអភិវឌ្ឍន៍ ស្នាដៃសិល្បៈ ស្នាដៃគំនូស ប្លង់ ឬគំនូសវាស ដែលធ្វើឡើងនៅកម្ពុជា ហើយត្រូវបានផ្គត់ផ្គង់ដោយផ្ទាល់ ឬដោយប្រយោលដោយអ្នកទិញ នូវទំនិញដែលត្រូវកំណត់តម្លៃ ដើម្បីផលិត និងលក់សម្រាប់នាំចេញទំនិញទាំងនោះ ហើយដែលត្រូវបានបង់ដោយផលិតករទំនិញ តាមសមមាត្រនៃទំនិញដែលត្រូវកំណត់តម្លៃដូចដែលមានចែងក្នុងវាក្យខណ្ឌទី ៣ កថាខណ្ឌ ក ប្រការ ១០ នៃប្រកាសនេះ ។

ខ- ទឹកប្រាក់ចំណេញ និងចំណាយទូទៅដែលត្រូវបានកំណត់ស្របតាមបញ្ញត្តិប្រការ២៩នៃប្រកាសនេះ ជាទូទៅឆ្លុះបញ្ចាំងនៅក្នុងការលក់សម្រាប់នាំចេញមកកម្ពុជានូវទំនិញដែលស្ថិតនៅក្នុងចំណាត់ថ្នាក់ និងប្រភេទដូចគ្នានឹងទំនិញដែលត្រូវកំណត់តម្លៃ ហើយដែលផលិតករបានលក់ទំនិញឲ្យអ្នកទិញនៅកម្ពុជាដែលមិនពាក់ព័ន្ធទៅនឹងផលិតករ នៅពេលលក់ទំនិញនោះ ។

**ប្រការ ២៩.-**

ទឹកប្រាក់ចំណេញ និងចំណាយទូទៅ ដូចមានចែងនៅក្នុងកថាខណ្ឌ ខ ប្រការ ២៨ នៃប្រកាសនេះ ត្រូវគណនាលើមូលដ្ឋានជាភាគរយ និងត្រូវកំណត់ដោយផ្អែកលើមូលដ្ឋានព័ត៌មាន ដែលស្របជាមួយនឹងគោលការណ៍គណនេយ្យទូទៅដែលអាចទទួលយកបាននៃប្រទេសផលិតទំនិញដែលត្រូវកំណត់តម្លៃ និងដែលបានផ្តល់ឲ្យដោយ ឬក្នុងនាមផលិតករទំនិញដែលត្រូវកំណត់តម្លៃ ឬប្រសិន

បើព័ត៌មានដែលផ្តល់មកនោះមិនគ្រប់គ្រាន់ ការពិនិត្យចំពោះការលក់សម្រាប់នាំចេញមកកម្ពុជា នៃក្រុមទំនិញដែលនៅជិតគ្នាបំផុត នៃក្រុមទំនិញដែលស្ថិតក្នុងចំណាត់ថ្នាក់ ឬប្រភេទដូចគ្នាទៅនឹងទំនិញដែលត្រូវកំណត់តម្លៃ ហើយដែលមានព័ត៌មានគ្រប់គ្រាន់ជាការចាំបាច់ ។

## ជំពូកទី ៨
## វិធីសាស្ត្រចុងក្រោយ

**ប្រការ ៣០.-**

ប្រសិនបើតម្លៃគិតពន្ធគយនៃទំនិញនាំចូលពុំអាចត្រូវបានកំណត់ក្រោមបញ្ញត្តិជំពូកទី ៧ នៃប្រកាសនេះ តម្លៃគិតពន្ធគយត្រូវកំណត់ដោយផ្អែកលើព័ត៌មានដែលអាចរកបាននៅកម្ពុជា លើមូលដ្ឋាននៃតម្លៃមួយដែលបានមកពីវិធីសាស្ត្រនៃការកំណត់តម្លៃដែលមានចែងនៅក្នុងជំពូកទី ២ ដល់ជំពូកទី ៧ នៃប្រកាសនេះ ដោយបកស្រាយទៅតាមវិធីទន់ភ្លន់ និងដោយមានការកែតម្រូវ សមស្របដែលចាំបាច់ដើម្បីឈានទៅសម្រេចបាននូវតម្លៃគិតពន្ធគយនៃទំនិញ ។

**ប្រការ ៣១.-**

តម្លៃគិតពន្ធគយមិនត្រូវបានកំណត់ដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម៖

ក- ថ្លៃលក់ទំនិញនៅកម្ពុជានៃទំនិញដែលបានផលិតនៅកម្ពុជា

ខ- ប្រព័ន្ធ ដែលផ្តល់ដើម្បីបានការយល់ព្រមពីគយ នៃតម្លៃខ្ពស់ជាង ក្នុងចំណោមតម្លៃពីរដែលអាចមាន

គ- ថ្លៃទំនិញនៅទីផ្សារក្នុងស្រុកនៃប្រទេសនាំចេញ

ឃ- ថ្លៃផលិតកម្ម ក្រៅពីតម្លៃគណនាដែលបានកំណត់លើទំនិញដូចគ្នា ឬទំនិញប្រហាក់ប្រហែលគ្នាស្របតាមបញ្ញត្តិជំពូកទី ៧ នៃប្រកាសនេះ

ង- ថ្លៃទំនិញសម្រាប់នាំចេញទៅប្រទេសទាំងឡាយផ្សេងពីកម្ពុជា លើកលែងតែទំនិញត្រូវបាននាំចូលមកកម្ពុជា

ច- តម្លៃគិតពន្ធគយអប្បបរមា

ឆ- តម្លៃមជ្ឈត្តកៈ ។

## ជំពូកទី ៩
## អន្តរប្បញ្ញត្តិ

**ប្រការ ៣២.-**

ដោយអនុលោមតាមបញ្ញត្តិមាត្រា ៧៨ នៃច្បាប់ស្តីពីគយ កិច្ចព្រមព្រៀងស្តីពីការអនុវត្តមាត្រា ៧ នៃកិច្ចព្រមព្រៀងទូទៅស្តីពីតារាងពន្ធគយ និងពាណិជ្ជកម្មឆ្នាំ ១៩៩៤ និងកំណត់ពន្យល់នៃកិច្ចព្រមព្រៀង ដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ ទីចាត់ការគយ និងរដ្ឋាករអាចស្នើសុំការសម្រេចពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពន្យារពេលជាបណ្តោះអាសន្ននូវការអនុវត្តតាមបញ្ញត្តិនានានៃប្រកាសនេះ ទាំងស្រុង ឬភាគខ្លះ លើមុខទំនិញមួយចំនួនដែលទីចាត់ការគយ និងរដ្ឋាករយល់ថា មានវេទយិតភាព ឬហានិភ័យខ្ពស់ ។

## ជំពូកទី ១០
## អវសានប្បញ្ញត្តិ

**ប្រការ ៣៣.-**

បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣៤.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និង រដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និង អង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ទីចាត់ការគយ និងរដ្ឋាករ
- ដូចប្រការ ៣៤
  សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ

នៃប្រកាសលេខៈ ៣៩៧សហវ.គរ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៨

ស្តីពី ការកំណត់តម្លៃគិតពន្ធគយលើទំនិញនាំចូល

## កិច្ចព្រមព្រៀងស្តីពីការអនុវត្តមាត្រា VII នៃ កិច្ចព្រមព្រៀងទូទៅ

## ស្តីពីតារាងពន្ធគយ និង ពាណិជ្ជកម្មឆ្នាំ ១៩៩៤

## និងកំណត់ពន្យល់

# ឧបសម្ព័ន្ធ

នៃប្រកាសលេខៈ៣៤៧សហវ.គរ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៨

## កិច្ចព្រមព្រៀងស្តីពីការអនុវត្តមាត្រា VII នៃ កិច្ចព្រមព្រៀងទូទៅស្តីពីតារាងពន្ធគយ និងពាណិជ្ជកម្មឆ្នាំ ១៩៩៤ និងកំណត់ពន្យល់

## សេចក្តីអធិប្បាយទូទៅដំបូង

១. មូលដ្ឋានជាបឋមនៃការគណនាតម្លៃគិតពន្ធគយនៅក្នុងកិច្ចព្រមព្រៀងនេះ គឺ " តម្លៃចម្លងការ " ដូចដែលបានចែងនៅក្នុងមាត្រា ១ ។ មាត្រា ១ ត្រូវបានអានជាមួយមាត្រា ៨ ដែលចែងអំពីការកែតម្រូវទៅលើថ្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដ នៅក្នុងករណីដែលមានកត្តាជាក់លាក់ផ្សេងៗត្រូវបានគេយកមកពិចារណា ដើម្បីបង្កើតជាផ្នែកមួយក្នុងការកំណត់តម្លៃទៅតាមគោលបំណងរបស់គយ ហើយដែលត្រូវទូទាត់ដោយអ្នកទិញ ប៉ុន្តែមិនទាន់បានបូកបញ្ចូលទៅក្នុងថ្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដនាពេលនាំចូល ។ មាត្រា ៨ បានចែងផងដែរពីការបូកបញ្ចូលទៅក្នុងតម្លៃចម្លងការនូវការចំណាយមួយចំនួនដែលត្រូវបានទូទាត់ដោយអ្នកទិញទៅអ្នកលក់តាមរូបភាពជាទំនិញ ឬជាសេវាដែលមិនមែនជាទឹកប្រាក់ ។ ពីមាត្រា ២ ដល់មាត្រា ៧ រៀបរាប់អំពីវិធីសាស្ត្រនៃការកំណត់តម្លៃគិតពន្ធគយ នៅពេលដែលគេមិនអាចកំណត់បាន ដោយយោងតាមបញ្ញត្តិនៃមាត្រា ១ ។

២ - នៅពេលដែលតម្លៃគិតពន្ធគយមិនអាចកំណត់បានស្របតាមបញ្ញត្តិមាត្រា ១ ទេ រដ្ឋបាលគយ និងអ្នកនាំចូលត្រូវពិគ្រោះជាមួយគ្នាជាដំណើរការធម្មតាដើម្បីកំណត់មូលដ្ឋានតម្លៃដោយផ្អែកលើបញ្ញត្តិនៃមាត្រា ២ និងមាត្រា ៣ ។ ករណីនេះអាចកើតមានឡើងដូចជា អ្នកនាំចូលមានព័ត៌មានអំពីតម្លៃគិតពន្ធគយនៃទំនិញដូចគ្នា ឬទំនិញប្រហាក់ប្រហែលគ្នា ដែលការិយាល័យគយនៅមាត់ច្រកចូលមិនទាន់មាន ។ ផ្ទុយទៅវិញ រដ្ឋបាលគយអាចមានព័ត៌មានស្តីពីតម្លៃគិតពន្ធគយលើទំនិញដូចគ្នា ឬប្រហាក់ប្រហែលគ្នា ដែលអ្នកនាំចូលមិនមាន ។ កិច្ចពិភាក្សារវាងភាគីទាំងពីរនឹងអាចផ្លាស់ប្តូរព័ត៌មានគ្នាដោយផ្អែកលើការរក្សាការសម្ងាត់ខាងពាណិជ្ជកម្ម ដើម្បីទទួលបាននូវការកំណត់តម្លៃសម្រាប់គិតពន្ធគយឱ្យបានដ៏ត្រឹមត្រូវ ។

៣ - មាត្រា ៥ និងមាត្រា ៦ បានចែងដោយឈរលើគោលការណ៍ពីរយ៉ាងក្នុងការកំណត់តម្លៃគិតពន្ធគយ កាលបើវាមិនអាចកំណត់បានដោយផ្អែកលើមូលដ្ឋានតម្លៃចម្លងការ នៃទំនិញនាំចូល ឬទំនិញនាំចូលដូចគ្នា ឬទំនិញនាំចូលប្រហាក់ប្រហែលគ្នា ។ ក្នុងកថាខណ្ឌ ១ នៃមាត្រា ៥ តម្លៃគិតពន្ធគយត្រូវបានកំណត់ដោយផ្អែកលើមូលដ្ឋាននៃតម្លៃដែលទំនិញត្រូវបានលក់ក្នុងល័ក្ខខ័ណ្ឌដែលការនាំចូលនេះមិនពាក់ព័ន្ធជាមួយអ្នកទិញក្នុងប្រទេសនាំចូល ។ អ្នកនាំចូលក៏មានសិទ្ធិឲ្យគេធ្វើការកំណត់តម្លៃគិតពន្ធគយលើទំនិញរបស់ខ្លួនដែលត្រូវកែច្នៃបន្ថែមក្រោយការនាំចូល តាមបញ្ញត្តិនៃមាត្រា ៥ ប្រសិនបើអ្នកនាំចូលស្នើសុំដូច្នេះ ។ នៅក្នុងមាត្រា ៦ តម្លៃគិតពន្ធ គយត្រូវបានកំណត់ដោយឈរនៅលើមូលដ្ឋាននៃតម្លៃគណនា ។ វិធីសាស្ត្រទាំងពីរនេះមានការលំបាកមួយចំនួន ហេតុដូច្នេះហើយទើបគេផ្តល់សិទ្ធិដល់អ្នកនាំចូល ដូចមានចែងនៅក្នុងបញ្ញត្តិនៃមាត្រា ៤ ឲ្យធ្វើការជ្រើសរើសលំដាប់ក្នុងការអនុវត្តវិធីសាស្ត្រទាំងពីរនេះ ដោយអនុវត្តវិធីសាស្ត្រណាមុនក៏បាន។

៤ - មាត្រា ៧ ចែងអំពីវិធីនៃការកំណត់តម្លៃគិតពន្ធគយក្នុងករណីដែលគេពុំអាចកំណត់បានតាមបញ្ញត្តិនៅក្នុងមាត្រាណាមួយនៃមាត្រាខាងលើ ។

ប្រទេសជាសមាជិក ៖

- ដោយគោរពទៅតាមកិច្ចពិភាក្សាពហុភាគីផ្នែកពាណិជ្ជកម្ម

- ដោយមានបំណងនាពេលខាងមុខអំពីកម្មវត្ថុរបស់ GATT ឆ្នាំ ១៩៩៤ និងការធានានូវប្រយោជន៍ជាបន្ថែមទៀតពីការធ្វើពាណិជ្ជកម្មអន្តរជាតិរបស់ប្រទេសកំពុងអភិវឌ្ឍ

- ដោយទទួលស្គាល់អំពីសារៈសំខាន់នៃបញ្ញត្តិមាត្រា VII របស់ GATT ឆ្នាំ ១៩៩៤ និងដើម្បីបង្កើតវិធានអនុវត្តនៅក្នុងរបៀបរបបឯកភាពខ្ពស់ និងភាពច្បាស់លាស់

- ដោយទទួលស្គាល់អំពីតម្រូវការនូវប្រព័ន្ធស្មើភាពគ្នា ឯកភាពគ្នា និងអព្យាក្រឹត លើការកំណត់តម្លៃគិតពន្ធគយនៃទំនិញនាំចូល និងបំបាត់ចោលនូវតម្លៃគិតពន្ធគយដែល ប្រឌិតស្រេចតែចិត្ត

- ដោយយល់ឃើញថា ការកំណត់តម្លៃគិតពន្ធគយនៃទំនិញនាំចូល ត្រូវស្របទៅតាមគ្រប់វិធានដែលអាចអនុវត្តបាន គឺជាតម្លៃចម្លងការនៃទំនិញដែលត្រូវកំណត់តម្លៃ

- ដោយទទួលស្គាល់ថា តម្លៃគិតពន្ធគយត្រូវបានកំណត់ដោយផ្អែកតាមលក្ខណៈសមញ្ញ និងមានសមភាព ដែលស្របតាមការអនុវត្តពាណិជ្ជកម្ម ហើយថានីតិវិធីកំណត់តម្លៃត្រូវអនុវត្តទូទៅដោយគ្មានការបែងចែកអំពីប្រភពផ្គត់ផ្គង់

- ដោយទទួលស្គាល់ថា នីតិវិធីកំណត់តម្លៃគិតពន្ធគយមិនត្រូវបានយកមកប្រើប្រាស់សម្រាប់ជារបាំងពាណិជ្ជកម្ម

បានយល់ព្រមដូចតទៅ ៖

## កំណត់សំគាល់ទូទៅ
## ការអនុវត្តតាមលំដាប់ជាបន្តបន្ទាប់នៃវិធីសាស្ត្រកំណត់តម្លៃគិតពន្ធគយ

១- ពីមាត្រា ១ ដល់មាត្រា ៧ បញ្ជាក់ពីរបៀបដែលតម្លៃគិតពន្ធគយនៃទំនិញនាំចូលត្រូវបានកំណត់ស្របតាមបញ្ញត្តិនានានៃកិច្ចព្រមព្រៀងនេះ ។ វិធីកំណត់តម្លៃត្រូវបានកំណត់ទៅតាមលំដាប់ដែលអាចអនុវត្តបាន ។ វិធីចម្បងក្នុងការកំណត់តម្លៃគិតពន្ធគយមានបញ្ជាក់ក្នុងមាត្រា ១ ដែលទំនិញនាំចូលត្រូវបានកំណត់តម្លៃស្របទៅតាមខ្លឹមសារនៃមាត្រានេះនៅពេលដែលល័ក្ខខ័ណ្ឌនានាត្រូវបានបំពេញ ។

២- កាលបើតម្លៃគិតពន្ធគយមិនអាចកំណត់បានស្របតាមបញ្ញត្តិនៃមាត្រា ១ គេត្រូវឈានទៅអនុវត្តមាត្រាបន្តបន្ទាប់រហូតដល់មាត្រាណាមួយអាចកំណត់បាន ។ មាត្រា ២ ចែងថា លុះត្រាតែតម្លៃគិតពន្ធគយមិនអាចកំណត់បានតាមបញ្ញត្តិនៃមាត្រាណាមួយ ទើបអាចយកបញ្ញត្តិនៃមាត្រាបន្ទាប់ត្រូវមកអនុវត្តបាន ។

៣- កាលបើអ្នកនាំចូលមិនមានសំណូមពរឲ្យអនុវត្តត្រឡប់នៃមាត្រា ៥ និងមាត្រា ៦ ទេ ការអនុវត្តជាធម្មតានៃមាត្រានីមួយៗនិងត្រូវគេប្រើជាបន្តបន្ទាប់គ្នា ។ ប្រសិនបើអ្នកនាំចូលស្នើសុំ ប៉ុន្តែគេមិនអាចកំណត់តម្លៃបានតាមមាត្រា ៦ នោះតម្លៃគិតពន្ធគយត្រូវកំណត់ដោយអនុវត្តតាមបញ្ញត្តិនៃមាត្រា ៥ ប្រសិនបើអាចធ្វើបាន ។

៤- នៅពេលដែលតម្លៃគិតពន្ធគយមិនអាចកំណត់បានដោយអនុវត្តតាមបញ្ញត្តិនៃមាត្រា ១ ដល់មាត្រា ៦ នោះ វានឹងត្រូវកំណត់ក្នុងបញ្ញត្តិនៃមាត្រា ៧ ។

## ការអនុវត្តគោលការណ៍គណនេយ្យទូទៅដែលអាចទទួលយកបាន

១- " គោលការណ៍គណនេយ្យទូទៅ " គឺជាគោលការណ៍ដែលជាកម្មវត្ថុនៃការស្រុះស្រួលគ្នានៅក្នុងប្រទេស ក្នុងពេលកំណត់ណាមួយ ដែលធនធានសេដ្ឋកិច្ច និងកាតព្វកិច្ចត្រូវបានគេកត់ត្រាជាទ្រព្យសកម្ម និងបំណុល ដែលការផ្លាស់ប្តូរនេះត្រូវបានគេ

កត់ត្រាទុក ។ តើទ្រព្យសកម្ម និងបំណុលព្រមទាំងការផ្លាស់ប្តូររបស់វាត្រូវវាស់វែងដោយរបៀបណា ? តើរបាយការណ៍ហិរញ្ញវត្ថុត្រូវរៀបចំយ៉ាងដូចម្តេច ? បទដ្ឋាននេះអាចមានទិសដៅធំ ៗ សម្រាប់អនុវត្តទូទៅក៏ដូចជាប្រតិបត្តិ និងនីតិវិធីលំអិតផងដែរ ។

២- គោលបំណងនៃកិច្ចព្រមព្រៀងនេះគឺ រដ្ឋបាលគយនីមួយៗនឹងប្រើប្រាស់ព័ត៌មានដែលបានរៀបចំក្នុងលក្ខណៈសមស្របទៅនឹងគោលការណ៍គណនេយ្យទូទៅដែលមាននៅក្នុងប្រទេសហើយស្របទៅនឹងខ្លឹមសារនៃមាត្រានោះ ។ ជាឧទាហរណ៍ ការកំណត់ប្រាក់ចំណេញ និងការចំណាយជាទូទៅនៅក្នុងបញ្ញត្តិនៃមាត្រា ៥ នឹងត្រូវកំណត់ដោយប្រើប្រាស់ព័ត៌មានដែលរៀបចំហើយ ដោយស្របទៅនឹងគោលការណ៍គណនេយ្យទូទៅរបស់ប្រទេសនាំចូល ។ ម្យ៉ាងទៀត ការកំណត់ប្រាក់ចំណេញនិងការចំណាយទូទៅក្នុងមាត្រា ៦ នឹងត្រូវអនុវត្តការប្រើប្រាស់ព័ត៌មាន ដែលបានរៀបចំហើយក្នុងលក្ខណៈសមស្របជាមួយនឹងការទទួលយកនូវគោលការណ៍គណនេយ្យទូទៅ ដែលមានក្នុងប្រទេសផលិត ។ ឧទាហរណ៍បន្ថែមពីការកំណត់នូវកត្តានីមួយៗដែលចែងក្នុងកថាខណ្ឌទី ១ (ខ) (ii) នៃមាត្រា ៨ ដែលប្រព្រឹត្តទៅក្នុងប្រទេសនាំចូល និងត្រូវប្រើប្រាស់ព័ត៌មានក្នុងលក្ខណៈសមស្របជាមួយនឹងការទទួលយកនូវគោលការណ៍គណនេយ្យទូទៅរបស់ប្រទេសនោះ ។

## វិធានស្តីពីតម្លៃគិតពន្ធគយ

**មាត្រា ១.-**

១- តម្លៃគិតពន្ធគយលើទំនិញនាំចូលគឺជាតម្លៃចម្លងការ មានន័យថា ជាថ្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដ លើទំនិញដែលបានលក់សម្រាប់នាំចេញទៅកាន់ប្រទេសនាំចូល ក្រោយពីបានកែតម្រូវ ស្របទៅនឹងបញ្ញត្តិមាត្រា ៨ នៃកិច្ចព្រមព្រៀងនេះ ប្រសិនបើ ៖

ក - គ្មានការរិតត្បិតស្តីពីការផ្តល់ ឬការប្រើប្រាស់ទំនិញដោយអ្នកទិញ ក្រៅពីការរិតត្បិតដែល ៖

(I)- កំណត់ ឬតម្រូវ ឬតាមសំណូមពរផ្លូវច្បាប់ ឬដោយអាជ្ញាធរសាធារណៈក្នុងប្រទេសនាំចូល ។

(II)- កម្រិតមណ្ឌលភូមិសាស្ត្រ ដែលទំនិញត្រូវបានលក់បន្ត ឬ

(III)- មិនបណ្ដាលឲ្យប៉ះពាល់ដល់តម្លៃទំនិញ ។

ខ- ការលក់ទំនិញ ឬថ្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដចំពោះទំនិញ មិនមែនជាកម្មវត្ថុនៃល័ក្ខខ័ណ្ឌ ឬកត្តាខ្វះដែលនាំឲ្យតម្លៃគិតពន្ធគយមិនអាចកំណត់បាន ។

គ- មិនមានផ្នែកណាមួយនៃប្រាក់ចំណូលដែលបានពីការលក់បន្ត ការចែកចាយ ឬការប្រើប្រាស់ទំនិញ ដោយអ្នកទិញ នឹងកើតឡើងដោយផ្ទាល់ ឬដោយប្រយោលដល់អ្នកលក់ លើកលែងតែការកែតម្រូវ ត្រូវបានធ្វើឡើងស្របទៅតាមបញ្ញត្តិនៃមាត្រា ៨ ។

ឃ- អ្នកទិញ និងអ្នកលក់មិនពាក់ព័ន្ធគ្នា ឬប្រសិនបើពាក់ព័ន្ធគ្នា នោះតម្លៃចម្លងការក៏អាចទទួលយកបាន តាមគោលបំណងរបស់គយក្នុងបញ្ញត្តិនៃកថាខណ្ឌទី ២ ។

២. (ក)- ក្នុងការកំណត់ថាតើតម្លៃចម្លងការអាចទទួលយកបានឬទេតាមបំណងនៃកថាខណ្ឌទី ១ ករណីដែលអ្នកទិញ និងអ្នកលក់ពាក់ព័ន្ធគ្នាតាមខ្លឹមសារនៃមាត្រា ១៥ មិនបង្កើតបានជាមូលហេតុគ្រប់គ្រាន់ដើម្បីកំណត់ថាតម្លៃចម្លងការនោះមិនអាចទទួលយកបានទេ ។ ក្នុងករណីនេះ ត្រូវពិនិត្យមើលអំពីកាលៈទេសៈ នៃការលក់នោះ ហើយត្រូវទទួលយកតម្លៃចម្លងការនេះ បើសម្ព័ន្ធភាពនោះមិនមានឥទ្ធិពលលើតម្លៃគិតពន្ធគយទេ ។ ប្រសិនជា ព័ត៌មានបានទទួលពីអ្នកនាំចូល ឬពីប្រភពផ្សេងទៀត ដែលនាំឲ្យអាជ្ញាធរគយមានមូលដ្ឋានគ្រប់គ្រាន់ថាសម្ព័ន្ធភាពនេះមានឥទ្ធិពលលើថ្លៃទំនិញ គយអាចប្រាប់ពីមូលហេតុទៅអ្នកនាំចូល និងផ្ដល់ឱកាស និងលទ្ធភាពដល់អ្នកនាំចូលដើម្បីឆ្លើយតបវិញ ។ ប្រសិនបើអ្នកនាំចូលមានសំណូមពរពីបណ្ដាមូលហេតុទាំងនេះ គយត្រូវសរសេរជាលាយលក្ខណ៍អក្សរ ។

(ខ)- ក្នុងការលក់រវាងបុគ្គលពាក់ព័ន្ធគ្នា តម្លៃចម្លងការត្រូវបានយល់ព្រម ឯទំនិញត្រូវបានកំណត់តម្លៃទៅតាមកថាខណ្ឌទី ១ កាលបើអ្នកនាំចូលបង្ហាញថា តម្លៃនោះវាកៀកជិតទៅនឹងចំណុចណាមួយដូចខាងក្រោម ហើយដែលវាស្ថិតនៅក្នុងពេលដូចគ្នា ឬពេលប្រហាក់ប្រហែលគ្នា ៖

(១). តម្លៃចម្លងការក្នុងពេលលក់ទៅឲ្យអ្នកទិញដែលមិនពាក់ព័ន្ធនឹងអ្នកលក់នូវទំនិញដូចគ្នា ឬប្រហាក់ប្រហែលគ្នា ដើម្បីនាំចេញទៅកាន់ប្រទេសនាំចូលដូចគ្នា ។

(២). តម្លៃគិតពន្ធគយនៃទំនិញដូចគ្នា ឬប្រហាក់ប្រហែលគ្នាដែលត្រូវបានកំណត់ទៅតាមបញ្ញត្តិនៃមាត្រា ៥ ។

(៣). តម្លៃគិតពន្ធគយនៃទំនិញដូចគ្នា ឬប្រហាក់ប្រហែលគ្នាដែលត្រូវបានកំណត់ទៅតាមបញ្ញត្តិនៃមាត្រា ៦ ។

ក្នុងការអនុវត្តកត្តាខាងលើ គេត្រូវគិតពីភាពខុសគ្នានៃកម្រិតពាណិជ្ជកម្ម ចំនួន និងកត្តាដែលបានរៀបរាប់ក្នុងមាត្រា ៨ និងថ្លៃដែលត្រូវចំណាយដោយអ្នកលក់នៅពេលលក់ ដែលអ្នកទិញនិង អ្នកលក់មិនពាក់ព័ន្ធគ្នាហើយអ្នកលក់មិនទទួលបន្ទុកបង់នាពេលលក់ ។

(គ)- បណ្តាកត្តាដែលមានចែងក្នុងកថាខណ្ឌ ២ (ខ) ត្រូវបានប្រើប្រាស់តាមគំនិតផ្តួចផ្តើមរបស់អ្នកនាំចូល និងសម្រាប់តែគោលបំណងប្រៀបធៀបតែប៉ុណ្ណោះ ។ តម្លៃជំនួសមិនអាចបង្កើតឡើងដោយយោងបញ្ញត្តិ នៃកថាខណ្ឌ ២ (ខ) ទេ ។

## **កំណត់សំគាល់មាត្រា ១**
## **ថ្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដ**

១- តម្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដ គឺជាការទូទាត់សរុបដែលធ្វើឡើងដោយអ្នកទិញចំពោះអ្នកលក់ ឬជាផលប្រយោជន៍សម្រាប់អ្នកលក់លើទំនិញនាំចូល ។ ការទូទាត់នេះមិនសំដៅចំពោះតែការផ្ទេរសាច់ប្រាក់នោះទេ វាក៏អាចតាមរយៈឥណទាន ឬរបស់អ្វីផ្សេងដែលអាចលក់ដូរបាន ។ ការទូទាត់ប្រាក់ អាចធ្វើដោយផ្ទាល់ ឬដោយប្រយោល ។ ឧទាហរណ៍អំពីការទូទាត់ប្រាក់ដោយប្រយោល ដូចជាការទូទាត់តាមរយៈការសងបំណុលទាំងស្រុង ឬដោយផ្នែក ដោយអ្នកទិញទៅឲ្យអ្នកលក់ ។

២- សកម្មភាពនានាដែលទទួលរ៉ាប់រងដោយអ្នកទិញសម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួនរបស់គាត់ ក្រៅពីសកម្មភាពដែលតម្រូវឲ្យកែតម្រូវដោយយោងមាត្រា ៨ មិនត្រូវបានចាត់ទុកថាជាការទូទាត់ដោយប្រយោលទៅអ្នកលក់ទេ ទោះបីជាគេចាត់ទុកថាអ្នកលក់បានទទួលប្រយោជន៍ក៏ដោយ ។ ដូច្នេះដើម្បីកំណត់តម្លៃគិតពន្ធគយ ថ្លៃដែលចំណាយលើសកម្មភាពទាំងនេះមិនត្រូវបូកបន្ថែមទៅលើថ្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដនោះទេ ។

៣- តម្លៃគិតពន្ធគយមិនបូកបញ្ចូលនូវការចំណាយ ឬថ្លៃខាងក្រោមនេះក្នុងករណីដែលវាត្រូវបានញែកចេញដោយឡែកពីថ្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដនៃទំនិញនាំចូល ។

(ក)- ការចំណាយសម្រាប់សាងសង់ ការផ្គុំតម្លើង ការជួសជុល ឬជំនួយបច្ចេកទេស ដែលកើតឡើងក្រោយការនាំចូលនូវទំនិញដូចជា ៖ រោងចក្រឧស្សាហកម្ម គ្រឿងម៉ាស៊ីន ឬបរិក្ខា ។

(ខ)- ថ្លៃដឹកជញ្ជូនក្រោយការនាំចូល ។

(គ)- ប្រាក់ពន្ធ និងអាករនៃប្រទេសនាំចូល ។

៤- ថ្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដ គឺជាតម្លៃនៃទំនិញនាំចូល ។ ដូច្នេះចលនានៃប្រាក់ភាគហ៊ុន ឬការចំណាយដទៃទៀតពីអ្នកទិញទៅអ្នកលក់ ដែលមិនទាក់ទងទៅនឹងទំនិញនាំចូលមិនមែនជាចំណែកនៃតម្លៃគិតពន្ធគយទេ ។

## កថាខណ្ឌ ១ (ក) (iii)

ក្នុងចំណោមការរឹតត្បិតដែលមិនបណ្តាលឲ្យថ្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដមិនអាចទទួលយកបាន គឺការរឹតត្បិតដែលមិនប៉ះពាល់ដល់ថ្លៃទំនិញ ។ ឧទាហរណ៍មួយចំពោះការរឹតត្បិតនេះគឺករណីដែលអ្នកលក់សំណូមពរឲ្យអ្នកទិញរថយន្តមិនទាន់ដាក់លក់ ឬតាំងបង្ហាញនូវរថយន្តនោះ មុនពេលកំណត់ចាប់ផ្តើមតាំងពិព័រណ៍ ដែលជាកាលបរិច្ឆេទនៃគម្រូឆ្នាំផលិតរថយន្ត ។

## កថាខណ្ឌ ១ (ខ)

១- ប្រសិនបើការលក់ ឬថ្លៃស្ថិតនៅក្រោមល័ក្ខខ័ណ្ឌ ឬការពិចារណាដែលតម្លៃមិនអាចកំណត់បាន ចំពោះទំនិញដែលត្រូវកំណត់តម្លៃនោះ តម្លៃគិតពន្ធគយមិនអាចកំណត់បានតាមតម្លៃចម្លងការទេ ។

ឧទាហរណ៍មួយចំនួនមានដូចខាងក្រោម ៖

(ក)- អ្នកលក់បង្កើតតម្លៃទំនិញនាំចូលដោយស្ថិតក្រោមល័ក្ខខ័ណ្ឌដែលអ្នកទិញត្រូវទិញទំនិញដទៃទៀតតាមបរិមាណកំណត់ ។

(ខ)-ថ្លៃទំនិញនាំចូលផ្អែកទៅលើថ្លៃ ដែលអ្នកទិញទំនិញនាំចូលលក់ទំនិញដទៃផ្សេងទៀតទៅឲ្យអ្នកលក់ទំនិញនាំចូលនោះ ។

(គ)- ថ្លៃត្រូវបានបង្កើតឡើងតាមរូបភាពនៃការទូទាត់ ដែលមិនទាក់ទងនឹងទំនិញនាំចូល កាលបើទំនិញនាំចូលជាផលិតផលពាក់កណ្តាលសំរេច ដែលអ្នកលក់បានដាក់ល័ក្ខខ័ណ្ឌឲ្យអ្នកទិញត្រូវផ្តល់វិញតាមបរិមាណជាកំណត់នូវផលិតផលសំរេច ។

២- ផ្ទុយទៅវិញល័ក្ខខ័ណ្ឌ ឬក៏ការពិចារណាដែលទាក់ទងទៅនឹងផលិតកម្ម ឬការផ្សព្វផ្សាយរកទីផ្សារនៃទំនិញនាំចូល មិនមែនជាកត្តានៃការបដិសេធតម្លៃចម្លងការនោះទេ ។ ឧទាហរណ៍ការពិតដែលអ្នកទិញផ្គត់ផ្គង់ដល់អ្នកលក់នូវស្នាដៃវិស្វកម្ម និងគម្រោងការផ្សេងៗ ដែលបានបង្កើតឡើងនៅក្នុងប្រទេសនាំចូលមិនមែនជាមូលដ្ឋាននៃការបដិសេធតម្លៃចម្លងការដូចមានចែងក្នុងមាត្រា ១ ទេ ។ ដូចគ្នានេះដែរ ប្រសិនបើអ្នកទិញធ្វើសកម្មភាពដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ទោះជាមានកិច្ចព្រមព្រៀងជាមួយអ្នកលក់នូវសកម្មភាពទាក់ទងទៅនឹងការរកទីផ្សារនៃទំនិញនាំចូលក៏ដោយ ក៏ការចំណាយលើសកម្មភាពទាំងនេះមិនមែនជាផ្នែកនៃតម្លៃគិតពន្ធគយទេ ហើយក៏មិនមែនជាមូលដ្ឋានដើម្បីបដិសេធនូវតម្លៃចម្លងការនោះដែរ ។

## កថាខណ្ឌទី ២

១- កថាខណ្ឌ ២ (ក) និងកថាខណ្ឌ ២(ខ) ចែងពីអត្ថន័យផ្សេងៗគ្នានៃការទទួលយកនូវតម្លៃចម្លងការ ។

២- កថាខណ្ឌ ២ (ក) ចែងថានៅពេលដែលអ្នកទិញនិងអ្នកលក់ពាក់ព័ន្ធគ្នា កាលៈទេសៈនៃការលក់នឹងត្រូវយកមកពិនិត្យ ហើយតម្លៃចម្លងការនឹងត្រូវចាត់ទុកជាជាតម្លៃគិតពន្ធគយ ប្រសិនបើការពាក់ព័ន្ធគ្នានេះមិនមានឥទ្ធិពលលើថ្លៃទំនិញទេ ។ វាមិនមានបំណងធ្វើការត្រួតពិនិត្យគ្រប់ករណីទាំងអស់នៅពេលដែលអ្នកទិញ និងអ្នកលក់មានការពាក់ព័ន្ធគ្នានោះទេ ។ ការត្រួតពិនិត្យបែបនេះ តម្រូវតែនៅពេលណាដែលមានការសង្ស័យអំពីការទទួលយកថ្លៃទំនិញ ។ នៅពេលដែលរដ្ឋបាលគយគ្មានការសង្ស័យអំពីការទទួលយកថ្លៃទំនិញ រដ្ឋបាលគយត្រូវតែទទួលយកដោយគ្មានសំណួរអ្វីបន្ថែម ទៀតចំពោះអ្នកនាំចូលឡើយ ។ ឧទាហរណ៍ រដ្ឋបាលគយអាចមានការត្រួតពិនិត្យលើកមុនៗនូវ

ទំនាក់ទំនង ឬក៏អាចមានព័ត៌មានលំអិតដែលពាក់ពន្ធ័រវាងអ្នកលក់ និងអ្នកទិញ ហើយក៏អាចបញ្ជាក់ពីការត្រួតពិនិត្យទាំងនោះ ឬក៏ព័ត៌មានស្តីពីទំនាក់ទំនងដែលពុំមានឥទ្ធិពលលើថ្លៃទំនិញ ។

៣- នៅពេលដែលរដ្ឋបាលគយមិនអាចទទួលយកបាននូវតម្លៃចម្លងការ ដោយពុំមានព័ត៌មានគ្រប់គ្រាន់នោះ រដ្ឋបាលគយត្រូវផ្តល់ឱកាសដល់អ្នកនាំចូលឲ្យផ្តល់នូវព័ត៌មានលំអិតបន្ថែមទៀត ដែលអាចជាការចាំបាច់ដល់ការត្រួតពិនិត្យលើកាលៈទេសៈជុំវិញការលក់ ។ ក្នុងបរិបទនេះ រដ្ឋបាលគយត្រូវរៀបចំការត្រួតពិនិត្យទិដ្ឋភាពពាក់ព័ន្ធទាំងឡាយទៅនឹងកិច្ចចម្លងការនេះ ដោយរួមបញ្ចូលនូវរបៀបដែលអ្នកទិញ និងអ្នកលក់រៀបចំ នូវទំនាក់ទំនងពាណិជ្ជកម្មរបស់ពួកគេ និងរបៀបគណនាតម្លៃទំនិញនោះដើម្បីកំណត់ថាតើទំនាក់ទំនងនោះមានឥទ្ធិពលលើថ្លៃទំនិញឬទេ ។ នៅពេលដែលគេអាចបង្ហាញថា អ្នកទិញនិងអ្នកលក់ ទោះបីមានការពាក់ព័ន្ធគ្នាក៏ដោយ ប៉ុន្តែគេលក់ដូរក្នុងតម្លៃដូចជាគ្មានការពាក់ព័ន្ធគ្នា នោះបញ្ជាក់ថា ថ្លៃមិនទទួលរងឥទ្ធិពលពីសម្ព័ន្ធភាពទេ ។ ឧទាហរណ៍ ប្រសិនបើថ្លៃត្រូវបានទូទាត់ក្នុងលក្ខណៈស្របជាមួយនឹងថ្លៃលក់ដូរជាធម្មតា ឬដូចគ្នានឹងតម្លៃដែលអ្នកលក់កំណត់ថ្លៃចំពោះអ្នកទិញដទៃទៀតដែលគ្មានការពាក់ព័ន្ធគ្នា នេះបង្ហាញថាថ្លៃមិនទទួលរងឥទ្ធិពលពីការពាក់ព័ន្ធគ្នានោះទេ ។ មានឧទាហរណ៍ផ្សេងទៀតពេលដែលវាបានបង្ហាញថា ថ្លៃលក់ល្មមគ្រប់គ្រាន់សម្រាប់ទូទាត់ថ្លៃដើម បូកលើប្រាក់ចំណេញដែលជាចំណែកនៃប្រាក់ចំណេញសរុបរបស់សហគ្រាសក្នុងរយៈពេលណាមួយកំណត់ (ឧទាហរណ៍ប្រាក់ចំណេញប្រចាំឆ្នាំ ) ក្នុងការលក់ទំនិញប្រភេទដូចគ្នា បង្ហាញឲ្យឃើញថាថ្លៃពុំមានទទួលរងឥទ្ធិពលនោះទេ ។

៤- កថាខណ្ឌ ២ (ខ) ផ្តល់ឱកាសដល់អ្នកនាំចូលដើម្បីបញ្ជាក់ថាតម្លៃចម្លងការកៀកជិតនឹងតម្លៃសាកល្បង ដែលរដ្ឋបាលគយបានយល់ព្រមលើកមុន និងដូចមានចែងនៅក្នុងបញ្ញត្តិនៃមាត្រា ១ ។ នៅពេលដែលតម្លៃសាកល្បងបានឆ្លើយតបនឹងកថាខណ្ឌ ២ (ខ) វាមិនចាំបាច់ត្រួតពិនិត្យលើបញ្ហាដែលទទួលរងឥទ្ធិពលក្នុងកថាខណ្ឌ ២ (ក)ទេ ។ ប្រសិនបើរដ្ឋបាលគយមានព័ត៌មានគ្រប់គ្រាន់នោះ ដោយមិនចាំបាច់សាកសួរព័ត៌មានលំអិតបន្ថែមទៀតនោះទេ មានន័យថាតម្លៃសាកល្បង ដែលបានចែងក្នុងកថាខណ្ឌ ២ (ខ) ត្រូវបានឆ្លើយតប ហើយគ្មានហេតុផលណាដើម្បីទាមទារឲ្យអ្នកនាំចូលបង្ហាញថាតម្លៃ

សាកល្បងនោះអាចទទួលយកបានទេ ។ ក្នុងកថាខណ្ឌ ២ (ខ) ពាក្យ "អ្នកទិញដែលមិនជាប់ពាក់ព័ន្ធ" ( Unrelated Buyer) មានន័យថាអ្នកទិញគ្មានការពាក់ព័ន្ធជាមួយអ្នកលក់ក្នុងគ្រប់ករណី ។

## កថាខណ្ឌ ២ (ខ)

មានកត្តាជាច្រើនត្រូវយកមកពិចារណាក្នុងការកំណត់ថាតើតម្លៃមួយដែល " នៅកៀកជិតបំផុត " (Closely Approximates) ទៅនឹងតម្លៃមួយទៀតឬទេ ។ កត្តាទាំងនេះរួមមាន លក្ខណៈទំនិញនាំចូល (Nature of the goods), លក្ខណៈឧស្សាហកម្មនៃទំនិញនោះ (Nature of the Industry), រដូវកាលដែលទំនិញត្រូវបាននាំចូល និងភាពខុសគ្នានៃតម្លៃក្នុងលក្ខណៈពាណិជ្ជកម្មនោះ ។ ដោយហេតុថាកត្តាទាំងនេះខុសគ្នាពីករណីមួយទៅករណីមួយ គេមិនអាចបង្កើតនូវគំរូស្តង់ដារមួយឯកភាពសម្រាប់គ្រប់ករណីបានទេ ដូចជាការកំណត់ភាគរយជាដើម ។ ឧទាហរណ៍ ៖ ភាពខុសគ្នាបន្តិចបន្តួចនៃតម្លៃចំពោះករណីប្រភេទទំនិញមួយអាចនឹងមិនទទួលយកបាន ប៉ុន្តែមានភាពខុសគ្នាខ្លាំងនៃតម្លៃរបស់ទំនិញប្រភេទផ្សេងទៀតបែរជាអាចទទួលយកបានទៅវិញក្នុងការកំណត់ថា តម្លៃចម្លងការនោះវានៅកៀកជិតទៅនឹងតម្លៃសាកល្បង ដូចមានចែងក្នុងកថាខណ្ឌ ២ (ខ) នៃមាត្រា ១ ឬទេ ។

**មាត្រា ២.-**

១ (ក)- ប្រសិនបើតម្លៃគិតពន្ធគយនៃទំនិញនាំចូលមិនអាចកំណត់បានក្នុងបញ្ញត្តិនៃមាត្រា ១ តម្លៃគិតពន្ធគយគឺជាតម្លៃចម្លងការចំពោះទំនិញដូចគ្នាលក់សម្រាប់នាំចេញទៅកាន់ប្រទេសនាំចូលដូចគ្នា ហើយបាននាំចេញនៅពេលជាមួយ ឬប្រហាក់ប្រហែលគ្នាទៅនឹងទំនិញដែលត្រូវកំណត់តម្លៃ ។

(ខ) ក្នុងការអនុវត្តមាត្រានេះ តម្លៃចម្លងការនៃទំនិញដូចគ្នា ដែលបានលក់ក្នុងកម្រិតពាណិជ្ជកម្មដូចគ្នា និងបរិមាណប្រហាក់ប្រហែលគ្នាបំផុតទៅនឹងទំនិញដែលត្រូវកំណត់តម្លៃ ត្រូវយកមកប្រើប្រាស់ដើម្បីកំណត់តម្លៃគិតពន្ធគយ ។ នៅពេលគ្មានការលក់បែបនេះ តម្លៃចម្លងការនៃទំនិញដូចគ្នា ដែលបានលក់ក្នុងកម្រិតពាណិជ្ជកម្មផ្សេងគ្នា និង/ឬក្នុងបរិមាណផ្សេងគ្នា អាចយកមកប្រើបាន ប្រសិនបើការកែតម្រូវដោយគិតពីភាពខុស

គ្នាពីកម្រិតពាណិជ្ជកម្ម និង/ឬបរិមាណ អាចធ្វើទៅបានដោយឈរលើមូលដ្ឋានភស្តុតាងច្បាស់លាស់ ដែលអាចបង្កើតឡើងនូវភាពសមហេតុផល និងភាពត្រឹមត្រូវនៃការកែតម្រូវនោះ ទោះជាការកែតម្រូវនោះនាំឲ្យកើន ឬថយតម្លៃក៏ដោយ ។

២- នៅពេលដែលថ្លៃ និងការចំណាយនានាយោងកថាខណ្ឌ ២ នៃមាត្រា ៨ បានបូកបញ្ចូលទៅក្នុងតម្លៃចម្លងការ គេត្រូវធ្វើការកែតម្រូវដោយពិចារណាពីភាពខុសគ្នានៃថ្លៃ និងការចំណាយផ្សេងៗរវាងទំនិញនាំចូល និងទំនិញដូចគ្នានោះ ដែលកើតឡើងដោយសារចម្ងាយផ្លូវ និងប្រភេទមធ្យោបាយដឹកជញ្ជូនជាដើម ។

៣- ក្នុងការអនុវត្តមាត្រានេះ ប្រសិនបើតម្លៃចម្លងការនៃទំនិញដូចគ្នាមានច្រើនលើសពីមួយ គេត្រូវយកតម្លៃចម្លងការណាដែលទាបជាងគេ ដើម្បីកំណត់តម្លៃគិតពន្ធគយចំពោះទំនិញនាំចូល ។

## កំណត់សំគាល់មាត្រា ២

១- ក្នុងការអនុវត្តមាត្រា ២ ប្រសិនជាអាចធ្វើទៅបាន រដ្ឋបាលគយត្រូវប្រើប្រាស់ការលក់នៃទំនិញដូចគ្នាក្នុងកម្រិតពាណិជ្ជកម្ម និងកម្រិតបរិមាណប្រហាក់ប្រហែលគ្នាបំផុតទៅនឹងទំនិញដែលត្រូវកំណត់តម្លៃ ។ បើសិនជាគ្មានការលក់បែបនេះទេ គេអាចប្រើការលក់ទំនិញដូចគ្នាក្នុងល័ក្ខខ័ណ្ឌណាមួយនៃល័ក្ខខ័ណ្ឌទាំងបីដូចខាងក្រោម ៖

ក- ការលក់ក្នុងកម្រិតពាណិជ្ជកម្មដូចគ្នា ប៉ុន្តែបរិមាណផ្សេងគ្នា

ខ- ការលក់ក្នុងកម្រិតពាណិជ្ជកម្មផ្សេងគ្នា ប៉ុន្តែបរិមាណដូចគ្នា ឬ

គ- ការលក់ក្នុងកម្រិតពាណិជ្ជកម្មផ្សេងគ្នា នឹងបរិមាណផ្សេងគ្នា ។

២- នៅពេលរកឃើញការលក់ក្នុងល័ក្ខខ័ណ្ឌណាមួយនៃល័ក្ខខ័ណ្ឌទាំងបីខាងលើ ការកែតម្រូវ នឹងត្រូវធ្វើឡើងតាមករណីដូចខាងក្រោមនេះ ៖

ក- កត្តាបរិមាណ

ខ- កត្តាកម្រិតពាណិជ្ជកម្ម ឬ

គ- កត្តាទាំងពីរនៃកម្រិតពាណិជ្ជកម្ម និងបរិមាណ

៣- ពាក្យ (និង/ឬ ) ផ្តល់នូវលទ្ធភាពក្នុងការប្រើប្រាស់ការលក់ និងធ្វើការកែតម្រូវជាចាំបាច់ក្នុងស្ថានភាពណាមួយនៃស្ថានភាពទាំងបីដូចបានចែងខាងលើ ។

៤- គោលបំណងនៃមាត្រា ២ តម្លៃចម្លងការនៃទំនិញដូចគ្នាមានន័យថាជាតម្លៃគិតពន្ធគយដោយបានកែតម្រូវ ដូចមានចែងក្នុងកថាខណ្ឌ ១ (ខ) និងកថាខណ្ឌ ២ ដែលបានទទួលយល់ព្រមស្របតាមបញ្ញត្តិនៃ មាត្រា ១ ។

៥- ល័ក្ខខ័ណ្ឌនៃការកែតម្រូវដោយភាពខុសគ្នានៃកម្រិតពាណិជ្ជកម្ម ឬកម្រិតបរិមាណគឺថា ការកែតម្រូវនេះទោះជាបណ្តាលឲ្យមានការកើនឡើង ឬថយតម្លៃក៏ដោយ ត្រូវធ្វើឡើងតែក្នុងករណីមានភស្តុតាងច្បាស់លាស់ ដែលបង្កើតឡើងនូវភាពសមហេតុផល និងភាពត្រឹមត្រូវនៃការកែតម្រូវ ។ ឧទាហរណ៍ ៖ តារាងតម្លៃដែលអាចយកជាការបាន (Valid Prices List) ដែលមានតម្លៃយោងទៅលើកម្រិតពាណិជ្ជកម្ម ឬកម្រិតបរិមាណផ្សេងគ្នា ។ ជាឧទាហរណ៍ចំពោះករណីនេះ ប្រសិនបើទំនិញនាំចូលដែលត្រូវកំណត់តម្លៃរួមមានការដឹកជញ្ជូនចំនួន ១០ ឯកតា ហើយទំនិញដូចគ្នានេះបាននាំចូល ដែលមានតម្លៃចម្លងការ ពាក់ព័ន្ធនឹងការលក់ចំនួន ៥០០ ឯកតា ហើយគេបានដឹងថាអ្នកលក់បានផ្តល់ការលក់បញ្ចុះថ្លៃតាមបរិមាណ ការកែតម្រូវត្រូវធ្វើឡើងតាមតារាងបញ្ចុះតម្លៃរបស់អ្នកលក់ ហើយត្រូវយកតម្លៃដែលត្រូវលក់តាមបរិមាណ ១០ ឯកតា ។ កិច្ចប្រតិបត្តិនេះមិនបានតម្រូវថា ការលក់ត្រូវធ្វើឡើងក្នុងបរិមាណ ១០ ឯកតានោះទេ ដរាបណាមានតារាងតម្លៃពិតប្រាកដ តាមរយៈការលក់ក្នុងបរិមាណផ្សេងទៀត ។ ប៉ុន្តែក្នុងករណីពុំមានវិធានដែលអាចវាស់វែងបានបែបនេះទេ ការកំណត់តម្លៃគិតពន្ធគយតាមបញ្ញត្តិមាត្រា ២ គឺមិនអាចធ្វើឡើងបានទេ ។

**មាត្រា ៣.-**

១.(ក)- ប្រសិនបើតម្លៃគិតពន្ធគយនៃទំនិញនាំចូលមិនអាចកំណត់បានក្នុងបញ្ញត្តិនៃមាត្រា ១ និងបញ្ញត្តិនៃមាត្រា ២ តម្លៃគិតពន្ធគយគឺជាតម្លៃចម្លងការនៃទំនិញប្រហាក់ប្រហែលគ្នាលក់សម្រាប់នាំចេញទៅកាន់ប្រទេសនាំចូលដូចគ្នា ហើយបាននាំចេញនៅពេលដូចគ្នា ឬពេលប្រហាក់ប្រហែលគ្នាទៅនឹងទំនិញដែលត្រូវកំណត់តម្លៃ ។

(ខ)- ក្នុងការអនុវត្តមាត្រានេះ តម្លៃចម្លងការនៃទំនិញប្រហាក់ប្រហែលគ្នាដែលលក់ក្នុងកម្រិតពាណិជ្ជកម្ម និងកម្រិតបរិមាណដូចគ្នាទៅនឹងទំនិញដែលបានកំណត់តម្លៃត្រូវបានយកមកប្រើសម្រាប់កំណត់តម្លៃគិតពន្ធគយ ។ កាលបើគ្មានការលក់បែបនេះ តម្លៃ

ចម្លងការនៃទំនិញប្រហាក់ប្រហែលគ្នា ដែលលក់ក្នុងកម្រិតពាណិជ្ជកម្មផ្សេងគ្នា និង/ឬ បរិមាណផ្សេងគ្នា ការកែតម្រូវនឹងត្រូវយកមកពិចារណាទៅតាមភាពខុសគ្នានៃកម្រិតពាណិជ្ជកម្ម និង/ឬកម្រិតបរិមាណនោះ ។ ការកែតម្រូវបែបនេះអាចធ្វើឡើង ដរាបណាមានភស្តុតាងច្បាស់លាស់ដែលបង្កើតឡើងនូវភាពសមហេតុផល និងភាពត្រឹមត្រូវ ទោះជាការកែតម្រូវនេះនាំឲ្យមានការកើនឡើង ឬក៏ថយចុះក៏ដោយ ។

២- នៅពេលដែលថ្លៃ និងការចំណាយផ្សេងៗយោងទៅលើកថាខណ្ឌ ២ នៃមាត្រា ៨ ត្រូវបានគេបូកបញ្ចូលនៅក្នុងតម្លៃចម្លងការ ការកែតម្រូវត្រូវធ្វើឡើងដោយពិចារណាលើភាពខុសគ្នានៃថ្លៃ និងការចំណាយរវាងទំនិញនាំចូល និងទំនិញប្រហាក់ប្រហែលគ្នាកើតឡើងពីភាពខុសគ្នានៃចម្ងាយផ្លូវ និងប្រភេទមធ្យោបាយដឹកជញ្ជូន ។

៣- ក្នុងការអនុវត្តមាត្រានេះ ប្រសិនបើតម្លៃចម្លងការនៃទំនិញប្រហាក់ប្រហែលគ្នាមានច្រើនលើសពីមួយ តម្លៃដែលទាបបំផុតនឹងត្រូវគេយកមកប្រើដើម្បីកំណត់តម្លៃគិតពន្ធគយនៃទំនិញនាំចូល ។

## កំណត់សំគាល់មាត្រា ៣

១- ក្នុងការអនុវត្តមាត្រា ៣ ប្រសិនជាអាចធ្វើទៅបាន រដ្ឋបាលគយត្រូវប្រើប្រាស់ការលក់នៃទំនិញប្រហាក់ ប្រហែលគ្នា ក្នុងកម្រិតពាណិជ្ជកម្ម និងកម្រិតបរិមាណច្រើនដូចគ្នាទៅនឹងទំនិញដែលត្រូវកំណត់តម្លៃ ។ នៅពេលដែលគ្មានការលក់បែបនេះ គេអាចប្រើការលក់ទំនិញប្រហាក់ប្រហែលគ្នា ក្នុងល័ក្ខខ័ណ្ឌណាមួយនៃល័ក្ខខ័ណ្ឌទាំងបីខាងក្រោម ៖

(ក)- ការលក់ក្នុងកម្រិតពាណិជ្ជកម្មដូចគ្នា ប៉ុន្តែក្នុងកម្រិតបរិមាណផ្សេងគ្នា ។

(ខ)- ការលក់ក្នុងកម្រិតពាណិជ្ជកម្មខុសគ្នា ប៉ុន្តែបរិមាណដូចគ្នា ។

(គ)- ការលក់ក្នុងកម្រិតពាណិជ្ជកម្មខុសគ្នា និង ក្នុងកម្រិតបរិមាណខុសគ្នា ។

២- នៅពេលរកឃើញការលក់ក្នុងល័ក្ខខ័ណ្ឌណាមួយនៃល័ក្ខខ័ណ្ឌខាងលើ ការកែតម្រូវនឹងត្រូវធ្វើឡើងតាមករណីដូចខាងក្រោម ៖

(ក)- កត្តាបរិមាណ

(ខ)- កត្តាកម្រិតពាណិជ្ជកម្ម ឬ

(គ)- កត្តាកម្រិតពាណិជ្ជកម្ម និងកម្រិតបរិមាណ ។

៣- ពាក្យ (និង/ឬ) ផ្តល់លទ្ធភាពក្នុងការប្រើប្រាស់ការលក់ និងធ្វើការកែតម្រូវជាចាំបាច់ក្នុងស្ថានភាពណាមួយនៃស្ថានភាពទាំងបីដូចបានចែងខាងលើ ។

៤- ក្នុងគោលបំណងនៃមាត្រា ៣ តម្លៃចម្លងការនៃទំនិញនាំចូលប្រហាក់ប្រហែលគ្នា គឺជាតម្លៃគិតពន្ធគយ ដោយបានកែតម្រូវដូចមានចែងក្នុងកថាខណ្ឌ ១ (ខ) និងកថាខណ្ឌ ២ នៃមាត្រា ១ ។

៥- ល័ក្ខខ័ណ្ឌនៃការកែតម្រូវ ដោយសារកម្រិតពាណិជ្ជកម្ម ឬកម្រិតបរិមាណផ្សេងគ្នាគឺថា ទោះជាការកែតម្រូវនោះ ធ្វើឲ្យមានការកើនឡើងឬថយចុះនូវតម្លៃក៏ដោយ វាអាចធ្វើឡើងបានតែក្នុងករណីមានភស្តុតាងច្បាស់លាស់ ដែលបង្កើតឡើងនូវភាពសមហេតុផល និងភាពត្រឹមត្រូវនៃការកែតម្រូវនោះ ។ ឧទាហរណ៍ ៖ តារាងតម្លៃដែលអាចយកជាការបាន ដោយយោងតាមកម្រិតពាណិជ្ជកម្ម ឬបរិមាណផ្សេងៗគ្នា ។ ឧទាហរណ៍ ប្រសិនបើទំនិញនាំចូលដែលត្រូវកំណត់តម្លៃមានចំនួន ១០ ឯកតា រីឯទំនិញនាំចូលប្រហាក់ប្រហែលគ្នាមានតម្លៃចម្លងការពាក់ព័ន្ធនឹងការលក់ចំនួន ៥០០ ឯកតានោះ ហើយដោយដឹងថាអ្នកលក់បានផ្តល់ការបញ្ចុះថ្លៃតាមបរិមាណទិញ ការកែតម្រូវអាចធ្វើឡើងបានដោយផ្អែកទៅលើតារាងតម្លៃរបស់អ្នកលក់ ដោយយកតម្លៃចំពោះការលក់ ១០ ឯកតា ។ កិច្ចចម្លងការនេះមិនតម្រូវថា ការលក់ត្រូវធ្វើឡើងក្នុងបរិមាណ ១០ ឯកតានោះទេ ដរាបណាមានតារាងតម្លៃពិតប្រាកដតាមរយៈការលក់ក្នុងបរិមាណផ្សេងទៀត ។ ប៉ុន្តែប្រសិនបើពុំមានវិធានដែលអាចវាស់វែងបានបែបនេះទេ ការកំណត់តម្លៃគិតពន្ធគយក្នុងបញ្ញត្តិនៃមាត្រា ៣ គឺមិនអាចធ្វើឡើងបានទេ ។

**មាត្រា ៤.-**

ប្រសិនបើតម្លៃគិតពន្ធគយនៃទំនិញនាំចូលមិនអាចកំណត់បានក្នុងតាមបញ្ញត្តិនៃមាត្រា ១ មាត្រា ២ និងមាត្រា ៣ តម្លៃគិតពន្ធគយត្រូវកំណត់តាមបញ្ញត្តិនៃមាត្រា ៥ ឬបញ្ញត្តិនៃមាត្រា ៦ ប្រសិនបើមាត្រា ៥ មិនអាចអនុវត្តបាន ។ ក្នុងករណីនេះ មាត្រា ៥ និង

មាត្រា ៦ អាចអនុវត្តត្រឡប់បាន ដែលមានន័យថា គេអាចប្រើមាត្រា ៦ មុនមាត្រា ៥ បាន នៅពេលដែលមានការស្នើសុំពីអ្នកនាំចូល ។

**មាត្រា ៥.-**

១.(ក)- ប្រសិនបើទំនិញនាំចូល ឬទំនិញនាំចូលដូចគ្នា ឬទំនិញនាំចូលប្រហាក់ប្រហែលគ្នា ត្រូវបានលក់ទៅប្រទេសនាំចូលតាមល័ក្ខខ័ណ្ឌនៃការនាំចូល តម្លៃគិតពន្ធគយនៃទំនិញនាំចូលនោះតាមបញ្ញត្តិនៃមាត្រានេះ ត្រូវផ្អែកលើតម្លៃឯកតានៃទំនិញនាំចូល ឬទំនិញដូចគ្នា ឬទំនិញប្រហាក់ប្រហែលគ្នាដែលត្រូវបានលក់ក្នុងបរិមាណច្រើនបំផុតនៅពេលដូចគ្នា ឬពេលប្រហាក់ប្រហែលគ្នាទៅនឹងពេលនាំចូលទំនិញដែលត្រូវកំណត់តម្លៃទៅឲ្យបុគ្គលដែលមិនមានការពាក់ព័ន្ធគ្នានឹងអ្នកទិញ ដោយដកចេញនូវការចំណាយដូចខាងក្រោម ៖

(i). កម្រៃសេវាដែលជាធម្មតាត្រូវទូទាត់ ឬនឹងត្រូវទូទាត់ ឬក៏ការបន្ថែមសម្រាប់ប្រាក់ចំណេញ និងការចំណាយទូទៅក្នុងការលក់នៅក្នុងប្រទេសនាំចូលនូវទំនិញនាំចូលប្រភេទដូចគ្នា ។

(ii). ថ្លៃដឹកជញ្ជូន និងថ្លៃធានារ៉ាប់រង និងថ្លៃរួមផ្សំផ្សេងៗទៀត ដែលបានចំណាយក្នុងប្រទេសនាំចូល ។

(iii). នៅពេលដែលសមរម្យអាចធ្វើទៅបាន ថ្លៃ និងការចំណាយនានាចែងក្នុងកថាខណ្ឌ ២ នៃមាត្រា ៨ ។

(iv). ពន្ធ និងអាករគយ និងពន្ធក្នុងប្រទេសផ្សេងទៀត ដែលត្រូវបង់ក្នុងប្រទេសនាំចូលដោយហេតុផលនៃការនាំចូល ឬលក់ទំនិញនោះ ។

(ខ)- ប្រសិនបើគ្មានទំនិញនាំចូល ឬទំនិញដូចគ្នា ឬទំនិញប្រហាក់ប្រហែលគ្នាត្រូវបានលក់នៅពេលដូចគ្នា ឬ ពេលប្រហាក់ប្រហែលនៃការនាំចូលទំនិញដែលត្រូវកំណត់តម្លៃទេ តម្លៃគិតពន្ធគយតាមបញ្ញត្តិនៃកថាខណ្ឌ ១ (ក) ត្រូវផ្អែកលើតម្លៃឯកតានៃទំនិញនាំចូល ឬទំនិញដូចគ្នា ឬទំនិញប្រហាក់ប្រហែលគ្នាត្រូវបានលក់នៅក្នុងប្រទេសនាំចូលក្នុងល័ក្ខខ័ណ្ឌជាទំនិញនាំចូលក្នុងកាលបរិច្ឆេទថ្មីបំផុត បន្ទាប់ពីការនាំចូលទំនិញដែលត្រូវកំណត់តម្លៃ ប៉ុន្តែមិនលើសពីសុពលភាព ៩០ ថ្ងៃបន្ទាប់ពីការនាំចូលនេះ ។

២- ប្រសិនបើគ្មានទំនិញនាំចូល ឬទំនិញដូចគ្នា ឬទំនិញប្រហាក់ប្រហែលគ្នាត្រូវបានលក់ក្នុងប្រទេសនាំចូលទៅតាមល័ក្ខខ័ណ្ឌដូចការនាំចូលនោះ ហើយប្រសិនបើមានការស្នើសុំពីអ្នកនាំចូល តម្លៃគិតពន្ធគយត្រូវផ្អែកលើតម្លៃឯកតានៃទំនិញនាំចូល ដែលបន្ទាប់ពីបានធ្វើការកែច្នៃបន្ថែម ត្រូវបានលក់ក្នុងបរិមាណច្រើនបំផុតទៅឲ្យបុគ្គលនៅក្នុងប្រទេសនាំចូល ដែលគ្មានការពាក់ព័ន្ធនឹងគ្នា ដោយដកចេញនូវតម្លៃបន្ថែមលើការកែច្នៃ និងចំណាយផ្សេងៗ ចែងក្នុងកថាខណ្ឌ ១ (ក) ។

## កំណត់សំគាល់មាត្រា ៥

១- ពាក្យ " តម្លៃឯកតានៅពេលដែលទំនិញត្រូវបានលក់ក្នុងបរិមាណច្រើនបំផុត" មានន័យថា តម្លៃឯកតានៃទំនិញដែលមានចំនួនច្រើនបំផុតត្រូវបានលក់ទៅឲ្យបុគ្គលដែលគ្មានការពាក់ព័ន្ធគ្នា ក្នុងកម្រិតពាណិជ្ជកម្មដំបូង បន្ទាប់ពីការនាំចូលនៃទំនិញត្រូវកំណត់តម្លៃ ។

២- ឧទាហរណ៍ ៖ ទំនិញត្រូវបានលក់តាមតម្លៃដែលផ្ដល់ឲ្យនូវការអនុគ្រោះចំពោះការបញ្ជាទិញក្នុងបរិមាណដ៏ច្រើន ។

| បរិមាណលក់ | តម្លៃឯកតា | ចំនួនលក់ | បរិមាណសរុបលក់ក្នុងតម្លៃនីមួយៗ |
|---|---|---|---|
| ១ - ១០ ឯកតា | ១០០ | លក់ ១០ ដង នៃ ៥ ឯកតា | ៦៥ |
| | | លក់ ៥ ដង នៃ ៣ ឯកតា | |
| ១១- ២៥ ឯកតា | ៩៥ | លក់ ៥ ដង នៃ ១១ ឯកតា | ៥៥ |
| លើស ២៥ ឯកតា | ៩០ | លក់ ១ ដង នៃ ៣០ឯកតា | ៨០ |
| | | លក់ ១ ដង នៃ ៥០ ឯកតា៨០ | |

ចំនួនឯកតាច្រើនបំផុតលក់ក្នុងតម្លៃនីមួយៗគឺ ៨០ ដូច្នេះតម្លៃឯកតានៃការលក់ក្នុងបរិមាណច្រើនបំផុតនោះគឺ ៩០ ។

៣- ឧទាហរណ៍ផ្សេងទៀត មានការលក់ ២ បានកើតឡើង ។ នៅក្នុងការលក់លើកទី ១ ចំនួន ៥០០ ឯកតា ត្រូវបានលក់ក្នុងតម្លៃនីមួយៗ ៩៥ ឯកតារូបិយប័ណ្ណ ។

ការលក់លើកទី ២ ចំនួន ២០០ ឯកតា ត្រូវបានលក់ក្នុងតម្លៃទីមួយៗ ៩០ ឯកតារូបិយប័ណ្ណ ។ នៅក្នុងឧទាហរណ៍នេះបរិមាណលក់ច្រើនជាងគេគឺ ៥០០ ដូច្នេះតម្លៃឯកតានៃការលក់ក្នុងបរិមាណច្រើនបំផុតនោះគឺ ៩៥ ។

៤- ឧទាហរណ៍ទី ៣ មានស្ថានភាពដូចខាងក្រោម នៅពេលដែលមានបរិមាណផ្សេងៗគ្នាត្រូវបានលក់ក្នុងតម្លៃផ្សេងៗគ្នា ។

(ក)- ការលក់

| បរិមាណលក់ | តម្លៃឯកតា |
|---|---|
| ៤០ ឯកតា | ១០០ |
| ៣០ ឯកតា | ៩០ |
| ១៥ ឯកតា | ១០០ |
| ៥០ ឯកតា | ៩៥ |
| ២៥ ឯកតា | ១០៥ |
| ៣៥ ឯកតា | ៩០ |
| ៥ ឯកតា | ១០០ |

(ខ)- ចំនួនសរុប

| បរិមាណលក់សរុប | តម្លៃឯកតា |
|---|---|
| ៦៥ | ៩០ |
| ៥០ | ៩៥ |
| ៦០ | ១០០ |
| ២៥ | ១០៥ |

នៅក្នុងឧទាហរណ៍នេះ ចំនួនច្រើនជាងគេនៃឯកតាត្រូវបានលក់គឺ ៦៥ ។ ដូច្នេះ តម្លៃឯកតាក្នុងបរិមាណដ៏ច្រើននោះគឺ ៩០ ។

៥- ការលក់ណាមួយនៅក្នុងប្រទេសនាំចូល ដូចដែលបានពណ៌នាក្នុងកថាខណ្ឌ ១ ខាងលើទៅបុគ្គលដែលផ្គត់ផ្គង់ដោយផ្ទាល់ ឬដោយប្រយោល ដោយមិនគិតប្រាក់ ឬបន្ថយតម្លៃសម្រាប់ការប្រើប្រាស់ក្នុងការផលិត ឬការលក់សម្រាប់នាំចេញនៃទំនិញនាំចូល

ការចំណាយផ្សេងៗដែលមានចែងក្នុងកថាខណ្ឌ ១ (ក) មាត្រា ៨ មិនត្រូវយកមកធ្វើជាថ្លៃឯកតាជាមូលដ្ឋាននៃការកំណត់តម្លៃ គិតពន្ធគយនៃមាត្រា ៥ នេះទេ ។

៦- គួរកត់សំគាល់ថា យោងកថាខណ្ឌ ១ នៃមាត្រា ៥ " ផលចំណេញ និងការចំណាយទូទៅ " ត្រូវគេយកមកប្រើជារួម ។ តួលេខសម្រាប់គោលបំណងនៃការដកចេញនេះត្រូវបានកំណត់ដោយឈរលើមូលដ្ឋាននៃព័ត៌មានដែលបានផ្តល់ឲ្យ ដោយអ្នកនាំចូល ឬតំណាង បើសិនជាតួលេខរបស់អ្នកនាំចូលស្របគ្នាជាមួយនឹងតួលេខលក់នៅក្នុងប្រទេសនាំចូលនៃទំនិញនាំចូលដែលមានប្រភេទដូចគ្នានោះ ។ នៅពេលដែលតួលេខរបស់អ្នកនាំចូលមិនស្របគ្នាជាមួយតួលេខទាំងនេះ ពេលនោះចំនួនប្រាក់ចំណេញ និង ការចំណាយទូទៅអាចឈរលើព័ត៌មានដែលពាក់ព័ន្ធពីប្រភពផ្សេង ជាជាងព័ត៌មានដែលបានផ្តល់ដោយអ្នកនាំចូល ។

៧- " ការចំណាយទូទៅ " រួមមានថ្លៃចំណាយដោយផ្ទាល់ ឬដោយប្រយោល ក្នុងការលក់ទំនិញនោះ ។

៨- ពន្ធក្នុងប្រទេសដែលនឹងត្រូវបង់ដោយហេតុផលនៃការលក់ទំនិញ ហើយដែលការដកចេញនេះមិនត្រូវបានធ្វើឡើងតាមបញ្ញត្តិនៃកថាខណ្ឌ ១(ក) (iv) នៃមាត្រា ៥ ទេ វានឹងត្រូវដកចេញដោយយោងបញ្ញត្តិនៃកថាខណ្ឌ ១ (ក) (i) នៃមាត្រា៥ ។

៩- ការកំណត់កម្រៃសេវា ឬប្រាក់ចំណេញធម្មតា និងការចំណាយទូទៅណាមួយតាមបញ្ញត្តិនៃកថាខណ្ឌ ១ នៃមាត្រា ៥ ករណីដែលថា តើទំនិញនោះជា "ទំនិញដែលមានកម្រិត ឬប្រភេទដូចគ្នា" ឬទេ ត្រូវកំណត់ឡើងដោយឈរលើមូលដ្ឋានមួយករណីម្តងៗ តាមកាលៈទេសៈជាក់ស្តែង ។ ត្រូវធ្វើការត្រួតពិនិត្យលើការលក់នៅក្នុងប្រទេសនាំចូលនៃក្រុមទំនិញនាំចូល ដែលមានកម្រិត ឬប្រភេទដូចគ្នារួមទាំងទំនិញដែលត្រូវកំណត់តម្លៃ ហើយដែលព័ត៌មានសំខាន់ៗពាក់ព័ន្ធអាចត្រូវបានផ្តល់ឲ្យ ។ ក្នុងគោលបំណងនៃមាត្រា ៥ "ទំនិញដែលមានកម្រិត ឬប្រភេទដូចគ្នា" រួមមានទំនិញនាំចូលមកពីប្រទេសតែមួយដូចគ្នានឹងទំនិញដែលត្រូវកំណត់តម្លៃ ព្រមទាំងទំនិញដែលនាំចូលមកពីប្រទេសដទៃ ។

១០- តាមគោលបំណងនៃកថាខណ្ឌ ១ (ខ) នៃមាត្រា ៥ "កាលបរិច្ឆេទដំបូងបំផុត" គឺជាកាលបរិច្ឆេទនៃការលក់ទំនិញនាំចូល ឬទំនិញដូចគ្នា ឬទំនិញប្រហាក់ប្រហែលគ្នាត្រូវបានធ្វើឡើងក្នុងបរិមាណគ្រប់គ្រាន់ ដើម្បីបង្កើតបានជាថ្លៃឯកតា ។

១១- នៅពេលដែលវិធីសាស្ត្រក្នុងកថាខណ្ឌ ២ នៃមាត្រា ៥ ត្រូវបានគេយកមកប្រើ ការដកចេញនានាត្រូវបានគេធ្វើឡើងសម្រាប់តម្លៃបន្ថែមក្នុងការកែច្នៃបន្ថែមទៀត ដោយផ្អែកលើទិន្នន័យដែលអាចវាស់វែងបានទាក់ទងនឹងថ្លៃនៃការងារនេះ ។ រូបមន្តឧស្សាហកម្មនានាដែលគេទទួលស្គាល់ ក្បួនខ្នាត វិធីសាស្ត្រសាងសង់ និងកិច្ចប្រតិបត្តិឧស្សាហកម្មផ្សេងទៀត បង្កើតបានជាទម្រង់ជាមូលដ្ឋានសម្រាប់ការគណនា ។

១២- គេទទួលស្គាល់ថា វិធីសាស្ត្រកំណត់តម្លៃគិតពន្ធគយ ដូចមានចែងក្នុងកថាខ័ណ្ឌ ២ នៃមាត្រា ៥ ជាធម្មតាមិនត្រូវបានគេយកមកប្រើប្រាស់ទេ នៅពេលដែលទំនិញនាំចូលនោះបានបាត់បង់អត្តសញ្ញាណបន្ទាប់ពីការកែច្នៃបន្ថែម ។ ប៉ុន្តែវាអាចមានករណីខ្លះ បើទោះបីជាអត្តសញ្ញាណរបស់ទំនិញនាំចូលត្រូវបាត់បង់ក៏ដោយ គេនៅតែអាចកំណត់បានត្រឹមត្រូវនូវតម្លៃបន្ថែមនៃការកែច្នៃដោយពុំមានការលំបាក ។ ម្យ៉ាងវិញទៀត វាក៏អាចមានករណីខ្លះទៀតដែលទំនិញនាំចូលនោះរក្សាបាននូវអត្តសញ្ញាណរបស់វា ប៉ុន្តែវាបង្កើតឡើងនូវកត្តាបន្ទាប់បន្សំមួយនៃទំនិញត្រូវបានលក់ក្នុងប្រទេសនាំចូល ដែលធ្វើឲ្យការប្រើប្រាស់នីតិវិធីកំណត់តម្លៃគិតពន្ធគយនៃមាត្រា ៥ នេះ ធ្វើឡើងមិនបានត្រឹមត្រូវ ។ ក្នុងទស្សនៈខាងលើ ស្ថានភាពនីមួយៗនៃវិធីសាស្ត្រនេះ ត្រូវពិចារណាមួយករណីម្តងៗ ។

**មាត្រា ៦.-**

១- តម្លៃគិតពន្ធគយនៃទំនិញនាំចូលក្នុងបញ្ញត្តិនៃមាត្រានេះគឺផ្អែកលើតម្លៃគណនា (Computed Value) ។ តម្លៃគណនាគឺជាផលបូកនៃទឹកប្រាក់ ៖

(ក)- ថ្លៃ ឬតម្លៃនៃវត្ថុធាតុដើម និងការផលិត ឬដំណើរការកែច្នៃផ្សេងទៀត ដែលបានប្រើប្រាស់ក្នុងការផលិតទំនិញនាំចូល ។

(ខ)- ចំនួនប្រាក់ចំណេញ និងការចំណាយទូទៅ ដែលឆ្លុះបញ្ចាំងពីការលក់ទំនិញជាធម្មតាដែលមានកម្រិត ឬប្រភេទដូចគ្នាទៅនឹងទំនិញដែលត្រូវកំណត់តម្លៃ ហើយដែលផលិតដោយអ្នកផលិតនៅក្នុងប្រទេសនាំចេញសម្រាប់នាំចេញទៅកាន់ប្រទេសនាំចូល ។

(គ)- ថ្លៃ ឬតម្លៃនៃការចំណាយចាំបាច់ផ្សេងទៀតនានា ឆ្លុះបញ្ចាំងពីជម្រើសក្នុងការកំណត់ តម្លៃដោយប្រទេសជាសមាជិក ចែងក្នុងកថាខណ្ឌ ២ នៃមាត្រា ៨ ។

២- គ្មានប្រទេសជាសមាជិកណាមួយអាចទាមទារ ឬបង្ខំទៅបុគ្គលណាម្នាក់ ដែលគ្មានទីលំនៅក្នុងទឹកដីរបស់ខ្លួន ឲ្យបង្កើតឡើង ឬក៏អនុញ្ញាតឲ្យចូលមើលនូវបញ្ជីគណនេយ្យ ឬកំណត់ត្រាផ្សេងទៀតនានាសម្រាប់គោលបំណងនៃការកំណត់តម្លៃគណនានោះទេ ។ ទោះជាយ៉ាងណាក៏ដោយ ព័ត៌មានដែលបានផ្ដល់ឱ្យដោយអ្នកផលិតទំនិញ សម្រាប់គោលបំណងនៃការកំណត់តម្លៃគិតពន្ធគយក្នុងបញ្ញត្តិនៃមាត្រានេះអាចត្រូវបានបញ្ជាក់ផ្ទៀងផ្ទាត់នៅក្នុងប្រទេសផ្សេងៗទៀត ដោយអាជ្ញាធរនៃប្រទេសនាំចូល ដោយមានការយល់ព្រមពីអ្នកផលិត ហើយប្រសិនបើគេអាចផ្ដល់ដំណឹងជាមុនទាន់ពេលទៅឲ្យរដ្ឋាភិបាលនៃប្រទេសនេះ ហើយដែលប្រទេសនោះមិនមែនជាកម្មវត្ថុនៃការស៊ើបអង្កេតនោះទេ ។

## កំណត់សំគាល់មាត្រា ៦

១- ជាទូទៅ តម្លៃគិតពន្ធគយត្រូវកំណត់តាមកិច្ចព្រមព្រៀងនេះ ដោយផ្អែកលើព័ត៌មានដែលទទួលបានក្នុងប្រទេសនាំចូល ។ ប៉ុន្តែ ដើម្បីកំណត់តម្លៃតាមវិធីសាស្ត្រតម្លៃគណនាបាន វាជាការចាំបាច់ដើម្បីពិនិត្យមើលពីថ្លៃចំណាយនានាក្នុងការផលិតទំនិញដែលត្រូវកំណត់តម្លៃ និងព័ត៌មានផ្សេងទៀតដែលត្រូវប្រមូលពីខាងក្រៅប្រទេសនាំចូល ។ ជាងនេះទៀតមានករណីជាច្រើន ដែលអ្នកផលិតទំនិញស្ថិតនៅក្រៅពីយុត្តាធិការនៃអាជ្ញាធរប្រទេសនាំចូល ។ វិធីសាស្ត្រតម្លៃគណនា ជាទូទៅមិនត្រូវប្រើប្រាស់ទេ នៅពេលដែលអ្នកទិញ និងអ្នកលក់មានទំនាក់ទំនងគ្នា ហើយអ្នកផលិតទំនិញត្រូវរៀបចំផ្ដល់ដល់អាជ្ញាធររបស់ប្រទេសនាំចូលនូវថ្លៃចំណាយក្នុងការផលិតចាំបាច់នានា និងផ្ដល់នូវការសម្របសម្រួលសម្រាប់ការផ្ទៀងផ្ទាត់ជាបន្តបន្ទាប់ទៀត ក្នុងករណីចាំបាច់ ។

២- យោងកថាខណ្ឌ ១ (ក) នៃមាត្រា ៦ " ថ្លៃដើម ឬតម្លៃ (Cost or Value) " ត្រូវកំណត់ដោយផ្អែកលើព័ត៌មានដែលមានទំនាក់ទំនងទៅនឹងការផលិតទំនិញ ដែលត្រូវកំណត់តម្លៃ ដែលផ្ដល់ដោយអ្នកផលិត ឬអ្នកតំណាង ។ គេត្រូវផ្អែកលើមូលដ្ឋាននៃគណនីពាណិជ្ជកម្ម ( Commercial Accounts ) របស់អ្នកផលិត ប្រសិនបើគណនីនោះ ស្របទៅនឹងគោលការណ៍គណនេយ្យទូទៅដែលអាចទទួលយកបាន (GAAP) ហើយត្រូវបានប្រើប្រាស់នៅក្នុងប្រទេសផលិតទំនិញ ។

៣- " ថ្លៃដើម ឬតម្លៃ " ត្រូវបូកបញ្ចូលនូវថ្លៃនៃធាតុនានាដែលមានចែងក្នុងកថាខណ្ឌ ១ (ក) (ii) និង (ក) (iii) នៃមាត្រា ៨ ។ គេក៏ត្រូវបញ្ចូលផងដែរនូវធាតុមួយចំនួនផ្សេងទៀតដែលមានចែងក្នុងកថាខណ្ឌ ១ (ខ) នៃមាត្រា ៨ ដែលធាតុទាំងនេះ ត្រូវបែងចែកតាមគោលការណ៍សមាមាត្រ (apportion) ស្របតាមបញ្ញត្តិក្នុងកំណត់សម្គាល់ពាក់ព័ន្ធនៃមាត្រា ៨ ហើយដែលព័ត៌មានទាំងនេះបានផ្តល់ដោយផ្ទាល់ ឬដោយប្រយោលពីអ្នកទិញសម្រាប់ប្រើប្រាស់ដែលទាក់ទិនជាមួយការផលិតទំនិញនាំចូល ។ តម្លៃនៃធាតុកំណត់ដែលបានបញ្ជាក់នៅក្នុងកថាខណ្ឌ ១ (ខ) (iv) នៃមាត្រា ៨ ដែលប្រព្រឹត្តទៅនៅក្នុងប្រទេស នាំចូលនឹងត្រូវបញ្ចូលតែក្នុងករណី ដែលធាតុទាំងនេះត្រូវទទួលបន្ទុកចំណាយដោយអ្នកផលិតប៉ុណ្ណោះ ។ យើងត្រូវយល់ថា ពុំមានថ្លៃ ឬតម្លៃនៃធាតុនានាដែលបានចែងក្នុងកថាខណ្ឌនេះនឹងត្រូវបានបូកបញ្ចូលពីរដងក្នុងការកំណត់តម្លៃគិតពន្ធគយ តាមវិធីសាស្ត្រនៃតម្លៃគណនាឡើយ ។

៤- យោងកថាខណ្ឌ ១ (ខ) នៃមាត្រា ៦ " ចំនួនប្រាក់ចំណេញ និងការចំណាយទូទៅ " ត្រូវកំណត់ដោយផ្អែកលើព័ត៌មានដែលផ្តល់ដោយអ្នកផលិត ឬអ្នកតំណាង បើសិនជាតួលេខរបស់អ្នកផលិតស្របទៅនឹងព័ត៌មាន ដែលឆ្លុះបញ្ចាំងក្នុងការលក់ទំនិញប្រភេទដូចគ្នាទៅនឹងទំនិញដែលត្រូវកំណត់តម្លៃ ហើយដែលធ្វើឡើងដោយអ្នកផលិតក្នុងប្រទេសនាំចេញសម្រាប់នាំចេញទៅប្រទេសនាំចូល ។

៥- នៅក្នុងបរិបទនេះគួរកត់សំគាល់ថា " ចំនួនប្រាក់ចំណេញ និងការចំណាយទូទៅ " ត្រូវគិតជារួម ។ ប្រសិនបើក្នុងករណីខ្លះតួលេខប្រាក់ចំណេញរបស់អ្នកផលិតទាប និងការចំណាយទូទៅខ្ពស់ តែប្រាក់ចំណេញ និងការចំណាយរបស់អ្នកផលិតដែលគិតរួមគ្នា ស្របទៅនឹងការឆ្លុះបញ្ចាំងក្នុងការលក់ទំនិញជាធម្មតា ដែលមានកម្រិត ឬប្រភេទដូចគ្នា ។ ស្ថានភាពបែបនេះអាចនឹងកើតមានឡើង ឧទាហរណ៍ ប្រសិនបើផលិតផលត្រូវបានចាប់ដាក់ឲ្យដំណើរការនៅក្នុងប្រទេសនាំចូល ហើយផលិតករសុខចិត្តមិនទទួលយកប្រាក់ចំណេញ ឬទទួលយកប្រាក់ចំណេញតិចតួចគ្រាន់តែដើម្បីទូទាត់នឹងការចំណាយទូទៅខ្ពស់ក្នុងការដាក់ឲ្យដំណើរការផលិតផលនោះ ។ នៅពេលដែលផលិតករអាចបង្ហាញថា ប្រាក់ចំណេញទាបពីការលក់ទំនិញនាំចូលពីព្រោះតែមានស្ថានភាពពាណិជ្ជកម្មពិសេសណាមួយនោះ តួលេខប្រាក់ចំណេញពិតប្រាកដរបស់ផលិតករនឹងត្រូវយកមក

ពិចារណា ប្រសិនបើផលិតករមានហេតុផលពាណិជ្ជកម្មសមស្របដើម្បីបញ្ជាក់ ហើយនយោបាយកំណត់ថ្លៃរបស់អ្នកលក់ ឆ្លុះបញ្ចាំងពីនយោបាយកំណត់ថ្លៃជាធម្មតារបស់សាខាឧស្សាហកម្មដែលពាក់ព័ន្ធ ។ ស្ថានភាពទាំងនេះអាចកើតមានឡើង ឧទាហរណ៍ដូចជានៅពេលណាដែលផលិតករត្រូវបានបង្ខំចិត្តបញ្ចុះតម្លៃទំនិញ ជាបណ្ដោះអាសន្នដោយសារតែតម្រូវការធ្លាក់ចុះដោយមិនបានព្រៀងទុកជាមុន ឬនៅពេលណាដែលពួកគេលក់ផលិតផលនេះដើម្បីបំពេញបន្ថែមទំនិញផ្សេងទៀតដែលកំពុងផលិតនៅក្នុងប្រទេសនាំចូលហើយទទួលយកប្រាក់ចំណេញទាប ដើម្បីរក្សានូវការប្រកួតប្រជែង ។ ប្រសិនបើតួលេខប្រាក់ចំណេញផ្ទាល់ខ្លួនរបស់ផលិតករ និងការចំណាយទូទៅមិនស្របគ្នាជាមួយនឹងការឆ្លុះបញ្ចាំងនៅក្នុងការលក់ទំនិញដែលមានកម្រិត ឬប្រភេទដូចគ្នាទៅនឹងទំនិញដែលត្រូវកំណត់តម្លៃ ផលិតឡើងដោយផលិតករនៅឯបរទេស នាំចេញទៅកាន់ប្រទេសនាំចូលនោះទេ ប្រាក់ចំណេញសរុប និងការចំណាយទូទៅនឹងត្រូវគណនាដោយផ្អែកលើព័ត៌មាន ដែលពាក់ព័ន្ធជាជាងព័ត៌មានដែលផ្ដល់ដោយផលិតករ ឬតំណាង ។

៦- កាលបើព័ត៌មានក្រៅពីព័ត៌មានដែលបានផ្ដល់ដោយអ្នកផលិតត្រូវបានប្រើសម្រាប់គោលបំណងកំណត់តម្លៃតាមវិធីសាស្ត្រគណនានោះ អាជ្ញាធរនៃប្រទេសនាំចូលត្រូវផ្ដល់ព័ត៌មានទៅអ្នកនាំចូល ប្រសិនបើមានការស្នើសុំនូវប្រភពព័ត៌មានទាំងនេះ នូវទិន្នន័យដែលប្រើ ហើយការគណនាត្រូវផ្អែកតាមព័ត៌មានទាំងនេះ ស្របតាមបញ្ញត្តិនៃមាត្រា ១០ ។

៧- យោងកថាខណ្ឌ ១ (ខ) នៃមាត្រា ៦ "ការចំណាយទូទៅ" រួមមានថ្លៃចំណាយផ្ទាល់ (Direct Costs) និងថ្លៃចំណាយមិនផ្ទាល់ (Indirect Costs) នៃការផលិត និងការលក់ទំនិញសម្រាប់នាំចេញ ដែលមិនទាន់បានគិតបញ្ចូលក្នុងកថាខណ្ឌ ១ (ក) នៃមាត្រា ៦ ។

៨- ទោះបីជាទំនិញខ្លះស្ថិតក្នុង " កម្រិត ឬប្រភេទដូចគ្នា " ទៅនឹងទំនិញដទៃទៀតក៏ដោយ ការកំណត់តម្លៃត្រូវធ្វើមួយករណីម្ដងៗ ដោយផ្អែកលើកាលៈទេសៈជាក់ស្ដែងទាក់ទិននឹងចម្ងការនោះ ។ ក្នុងការកំណត់ប្រាក់ចំណេញ និងការចំណាយទូទៅតាមបញ្ញត្តិនៃមាត្រា ៦ គេត្រូវពិនិត្យមើលការលក់សម្រាប់នាំចេញទៅកាន់ប្រទេសនាំចូលនៃក្រុមនៃទំនិញដែលមានលំដាប់ ឬក្រុមជិតគ្នាបំផុត រួមបញ្ចូលទាំងទំនិញដែលត្រូវកំណត់តម្លៃ តាម

ព័ត៌មានចាំបាច់ដែលបានផ្តល់ ។ សម្រាប់គោលបំណងនៃមាត្រា ៦ "ទំនិញដែលមានប្រភេទដូចគ្នា" ត្រូវតែមកពីប្រទេសតែមួយដូចគ្នាទៅនឹងទំនិញដែលត្រូវបានកំណត់តម្លៃ ។

**មាត្រា ៧.-**

១- ប្រសិនបើតម្លៃគិតពន្ធគយនៃទំនិញនាំចូលមិនអាចកំណត់បានតាមបញ្ញត្តិនៃមាត្រា ១ ដល់មាត្រា ៦ តម្លៃគិតពន្ធគយនឹងត្រូវកំណត់ដោយប្រើវិធីសាស្ត្រសមហេតុផលស្របនឹងគោលការណ៍ និងបញ្ញត្តិទូទៅនៃកិច្ចព្រមព្រៀងនេះ និងមាត្រា ៧ នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម (GATT) ឆ្នាំ១៩៩៤ និងផ្អែកលើមូលដ្ឋាននៃទិន្នន័យដែលមាននៅក្នុងប្រទេសនាំចូល ។

២- គ្មានតម្លៃគិតពន្ធគយណាដែលត្រូវកំណត់តាមបញ្ញត្តិនៃមាត្រានេះដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម ៖

(ក). តម្លៃលក់ក្នុងប្រទេសនាំចូលនូវទំនិញដែលបានផលិតក្នុងប្រទេសនោះ ។

(ខ). ប្រព័ន្ធដែលផ្តល់ឲ្យការកំណត់តម្លៃគិតពន្ធគយទទួលយកនូវតម្លៃខ្ពស់ជាងក្នុងចំណោមជំរើសនៃ តម្លៃពីរ ។

(គ). ថ្លៃទំនិញនៅទីផ្សារក្នុងស្រុកនៃប្រទេសនាំចេញ ។

(ឃ). ថ្លៃផលិតកម្មក្រៅពីតម្លៃគណនាដែលបានកំណត់សម្រាប់ទំនិញដូចគ្នា ឬប្រហាក់ប្រហែលគ្នា ស្របទៅនឹងបញ្ញត្តិនៃមាត្រា ៦ ។

(ង). តម្លៃទំនិញសម្រាប់នាំចេញទៅកាន់ប្រទេសមួយក្រៅពីប្រទេសនាំចូល ។

(ច). តម្លៃគិតពន្ធគយអប្បបរមា ឬ

(ឆ). តម្លៃដែលកំណត់ស្រេចតែចិត្ត ឬដោយប្រឌិត ។

៣- គេត្រូវជូនដំណឹងជាលាយល័ក្ខណ៍អក្សរទៅអ្នកនាំចូលនូវព័ត៌មានស្តីពីតម្លៃគិតពន្ធគយ ដែលបានកំណត់តាមបញ្ញត្តិនៃមាត្រានេះ និងវិធីសាស្ត្រដែលបានប្រើសម្រាប់កំណត់តម្លៃគិតពន្ធគយនោះ ប្រសិនបើមានសំណើពីអ្នកនាំចូល ។

## កំណត់សំគាល់មាត្រា ៧

១- តាមលទ្ធភាពខ្ពស់បំផុតដែលអាចធ្វើទៅបាន តម្លៃគិតពន្ធគយដែលបាន កំណត់ក្នុងបញ្ញត្តិនៃមាត្រា ៧ ត្រូវកំណត់ដោយផ្អែកលើមូលដ្ឋាននៃការកំណត់តម្លៃគិត ពន្ធគយពីមុន ។

២- វិធីសាស្ត្រនៃការកំណត់តម្លៃដែលត្រូវប្រើតាមមាត្រា ៧ គួរតែជាវិធីសាស្ត្រ ដែលមានចែងនៅក្នុងមាត្រា ១ ដល់មាត្រា ៦ ប៉ុន្តែត្រូវមានការបត់បែនសមហេតុផលមួយ ក្នុងការប្រើប្រាស់នូវវិធីសាស្ត្រទាំងនេះ ដោយអនុលោមទៅតាមគោលបំណងនានា ក្នុង បញ្ញត្តិនៃមាត្រា ៧ នេះ ។

៣- ឧទាហរណ៍ខ្លះៗនៃភាពបត់បែនសមហេតុផលមានដូចខាងក្រោម ៖

(ក). **ទំនិញដូចគ្នា** ៖ តម្រូវការដែលថា ទំនិញដូចគ្នាត្រូវគួរតែត្រូវបាននាំចេញ នៅពេលដូចគ្នា ឬពេលប្រហាក់ប្រហែលគ្នាជាមួយនឹងទំនិញដែលត្រូវបានកំណត់តម្លៃ អាចត្រូវបានគេបកស្រាយថា ទំនិញនាំចូលដូចគ្នា ផលិតនៅក្នុងប្រទេសមួយក្រៅពី ប្រទេសនាំចេញនៃទំនិញដែលត្រូវកំណត់តម្លៃ អាចធ្វើជាមូលដ្ឋាននៃការកំណត់តម្លៃគិតព ន្ធគយ ។ តម្លៃគិតពន្ធគយនៃទំនិញនាំចូលដូចគ្នា ដែលបានកំណត់រួចហើយតាមបញ្ញត្តិនៃ មាត្រា ៥ និង បញ្ញត្តិនៃមាត្រា ៦ ត្រូវបានគេយកមកប្រើ ។

(ខ). **ទំនិញប្រហាក់ប្រហែលគ្នា** ៖ តម្រូវការដែលថា ទំនិញប្រហាក់ប្រហែល គ្នាគួរតែត្រូវបាននាំចេញនៅពេលដូចគ្នា ឬពេលប្រហាក់ប្រហែលគ្នាទៅនឹងទំនិញដែលត្រូវ កំណត់តម្លៃ អាចត្រូវគេបកស្រាយថា ទំនិញនាំចូលប្រហាក់ប្រហែលគ្នាបានផលិតក្នុង ប្រទេសណាមួយក្រៅពីប្រទេសនាំចេញនៃទំនិញដែលត្រូវកំណត់តម្លៃ អាចធ្វើជាមូលដ្ឋាន សម្រាប់ការកំណត់តម្លៃគិតពន្ធគយ ។ តម្លៃគិតពន្ធគយនៃទំនិញនាំចូលប្រហាក់ប្រហែល គ្នាដែលបានកំណត់រួចហើយតាមបញ្ញត្តិនៃមាត្រា ៥ និង បញ្ញត្តិនៃមាត្រា ៦ ត្រូវបានគេ យកមកប្រើ ។

(គ). វិធីសាស្ត្រអនុមាន ៖ តម្រូវការដែលថា ទំនិញត្រូវបានលក់ក្នុង " លក្ខខ័ណ្ឌ ដែលបាននាំចូល " ក្នុង កថាខ័ណ្ឌ ១ (ក) នៃមាត្រា ៥ អាចត្រូវបានគេបកស្រាយថា "រយៈពេល ៩០" ថ្ងៃ អាចត្រូវបានយកមកប្រើប្រាស់ដោយទន់ភ្លន់បាន ។

**មាត្រា ៨.-**

១- នៅក្នុងការកំណត់តម្លៃគិតពន្ធគយតាមបញ្ញត្តិនៃមាត្រា ១ គេត្រូវបូកបញ្ចូលទៅក្នុងថ្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដសម្រាប់ទំនិញនាំចូលនូវការចំណាយដូចតទៅនេះ ៖

(ក). ក្នុងករណីដែលវាជាបន្ទុករបស់អ្នកទិញ ប៉ុន្តែមិនទាន់បានបូកបញ្ចូលនៅក្នុងថ្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដចំពោះទំនិញ គេត្រូវបូកបញ្ចូល ៖

(I). កម្រៃសេវា និងកម្រៃជើងសារ លើកលែងតែកម្រៃសេវាពីការទិញ

(II). ថ្លៃនៃការផ្ទុកទំនិញដែលបានចំណាយលើទំនិញដែលត្រូវកំណត់តម្លៃគិតពន្ធគយ ។

(III). ថ្លៃវេចខ្ចប់ រួមទាំងកំលាំងពលកម្ម ឬសម្ភារៈផ្សេងៗ

(ខ). តម្លៃដែលបែងចែកតាមសមាមាត្រនៃទំនិញ និងសេវាផ្សេងៗដូចខាងក្រោមនេះ ដែលផ្តល់ដោយផ្ទាល់ ឬដោយប្រយោលដោយអ្នកទិញដោយមិនគិតថ្លៃ ឬដោយបញ្ចុះថ្លៃសម្រាប់ការប្រើប្រាស់ក្នុងផលិតកម្ម និងការលក់សម្រាប់នាំចេញនៃទំនិញនាំចូល ក្នុងករណីដែលតម្លៃនោះមិនទាន់បានបូកបញ្ចូលក្នុងថ្លៃដែលបានទូទាត់ឬ នឹងត្រូវទូទាត់ពិតប្រាកដ ៖

(i). សម្ភារៈ វត្ថុធាតុដើម ភាគបន្សំ ភាគ និងគ្រឿងផ្សំស្រដៀងគ្នាផ្សេងទៀតដែលត្រូវភ្ជាប់ជាមួយទំនិញនាំចូល

(ii). ឧបករណ៍ ពុម្ព ( Dies ) ពុម្ពចាក់ និងឧបករណ៍ផ្សេងទៀតដែលប្រើប្រាស់ក្នុងការផលិតទំនិញនាំចូល

(iii). វត្ថុធាតុដែលប្រើប្រាស់ក្នុងការផលិតទំនិញនាំចូល

(iv). ស្នាដៃវិស្វកម្ម ស្នាដៃអភិវឌ្ឍន៍ ស្នាដៃសិល្បៈ ស្នាដៃគំនូស ប្លង់ និងគំនូសវាសដែលបានធ្វើនៅកន្លែងផ្សេងក្រៅពីប្រទេសនាំចូល និងដែលចាំបាច់សម្រាប់ការផលិតទំនិញនាំចូល ។

(គ).កម្រៃសួយសារ និងកម្រៃអាជ្ញាប័ណ្ណទាក់ទងទៅនឹងទំនិញដែលត្រូវកំណត់តម្លៃ ហើយដែលអ្នកទិញត្រូវទូទាត់ដោយផ្ទាល់ ឬដោយប្រយោលទៅតាមល័ក្ខខ័ណ្ឌនៃការលក់ទំនិញដែលត្រូវកំណត់តម្លៃ ក្នុងករណីដែលកម្រៃសួយសារ និងកម្រៃនានា ដែលមិនទាន់បានបញ្ចូលទៅក្នុងថ្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដ ។

(ឃ). តម្លៃនៃផ្នែកណាមួយនៃចំណូលដែលបានពីការលក់បន្ត ការចែកចាយ ឬការប្រើប្រាស់ទំនិញនាំចូល ដែលត្រូវផ្តល់ដោយផ្ទាល់ ឬដោយប្រយោលទៅអ្នកលក់ ។

២- នៅក្នុងការរៀបចំនីតិបញ្ញត្តិរបស់ខ្លួន សមាជិកនីមួយៗត្រូវផ្តល់នូវ ការដាក់បញ្ចូល ឬកំដកចេញពីតម្លៃគិតពន្ធគយទាំងស្រុង ឬដោយផ្នែកនូវការចំណាយដូចខាងក្រោម ៖

(ក)- ថ្លៃដឹកជញ្ជូនទំនិញនាំចូលទៅដល់កំពង់ផែ ឬទីកន្លែងនាំចូល ។

(ខ)- ថ្លៃផ្ទុកទំនិញ ថ្លៃផ្ទេរទំនិញ និងថ្លៃលើកដាក់ផ្សេងៗដែលជាប់ពាក់ព័ន្ធទៅនឹងការដឹកជញ្ជូនទំនិញនាំចូលទៅកំពង់ផែ ឬទីកន្លែងនាំចូល ។

(គ) ថ្លៃធានារ៉ាប់រង ។

៣. ការបូកបន្ថែមទៅលើថ្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដ ត្រូវធ្វើឡើងតាមមាត្រានេះ តែក្នុងករណីមានមូលដ្ឋានទិន្នន័យច្បាស់លាស់ និងអាចវាស់វែងបាន ។

៤. មិនត្រូវបូកបន្ថែមទៅលើថ្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដក្នុងការកំណត់តម្លៃគិតពន្ធ គយ លើកលែងតែអ្វីដែលមានចែងនៅក្នុងមាត្រានេះ ។

## កំណត់សំគាល់មាត្រា ៨

## កថាខណ្ឌ ១ (ក) (i)

ពាក្យថា "កម្រៃសេវាពីការទិញ " មានន័យថា កម្រៃដែលបានទូទាត់ដោយអ្នកនាំចូលចំពោះភ្នាក់ងាររបស់ខ្លួន សម្រាប់សេវាតំណាងអ្នកនាំចូលនៅឯបរទេសក្នុងការទិញទំនិញដែលត្រូវកំណត់តម្លៃ ។

**កថាខណ្ឌ ១ (ខ) ( ii)**

១. មានកត្តាពីរដែលពាក់ព័ន្ធក្នុងការបែងចែកតាមសមាមាត្រនៃភាគផ្សំដូចមានចែងក្នុងកថាខណ្ឌ ១ (ខ)( ii) នៃមាត្រា ៨ ចំពោះទំនិញនាំចូល គឺ តម្លៃនៃភាគបន្សំរបស់វាផ្ទាល់ និងវិធីដែលតម្លៃត្រូវបានបែងចែកតាមសមាមាត្រចំពោះទំនិញនាំចូល ។ ការបែងចែកតាមសមាមាត្រនៃភាគបន្សំទាំងនោះគួរត្រូវបានធ្វើឡើងក្នុងលក្ខណៈសមហេតុផល និងត្រឹមត្រូវទៅតាមកាលៈទេសៈជាក់ស្តែង និងស្របតាមគោលការណ៍ គណនេយ្យទូទៅដែលអាចទទួលយកបាន (GAAP) ។

២. ពាក់ព័ន្ធទៅនឹងតម្លៃនៃភាគបន្សំទាំងនេះ ប្រសិនបើអ្នកនាំចូលបានទទួលនូវភាគបន្សំពីអ្នកលក់ដែលមិនជាប់ពាក់ព័ន្ធគ្នាក្នុងតម្លៃមួយ តម្លៃនេះគឺជាតម្លៃនៃភាគបន្សំនោះតែម្តង ។ ប្រសិនបើភាគបន្សំត្រូវបានផលិតឡើងដោយអ្នកនាំចូល ឬដោយបុគ្គលដែលពាក់ព័ន្ធនឹងអ្នកនាំចូល តម្លៃរបស់វាគឺជាថ្លៃនៃការផលិតនោះ ។ ប្រសិនបើភាគបន្សំទាំងនេះត្រូវបានប្រើប្រាស់ពីមុនមកដោយអ្នកនាំចូល ទោះបីជាភាគបន្សំទាំងនោះត្រូវបានទទួល ឬបង្កើតដោយអ្នកនាំចូលក៏ដោយ ថ្លៃដើមនៃការទទួល ឬថ្លៃដើមនៃការផលិត ត្រូវយកមកកាត់បន្ថយរំលោះ ដើម្បីឆ្លុះបញ្ចាំងនូវការប្រើប្រាស់របស់វាក្នុងគោលបំណងឈានទៅកំណត់តម្លៃនៃភាគបន្សំទាំងនោះ ។

៣. នៅពេលដែលភាគបន្សំនោះត្រូវបានកំណត់តម្លៃរួចហើយ ចាំបាច់ត្រូវបែងចែកនូវតម្លៃរបស់វាតាមសមាមាត្រចំពោះទំនិញនាំចូល ។ លទ្ធភាពនៃការបែងចែកថ្លៃតាមសមាមាត្រផ្សេងៗអាចកើតមានឡើង។ ឧទាហរណ៍ តម្លៃអាចត្រូវបានបែងចែកចំពោះការនាំចូលលើកទីមួយ ប្រសិនបើអ្នកនាំចូលមានបំណងបង់ពន្ធសរុបក្នុងពេលតែមួយតែម្តង ។ ឧទាហរណ៍មួយផ្សេងទៀតគឺ អ្នកនាំចូលអាចនឹងស្នើសុំឱ្យកំណត់តម្លៃ ដោយបែងចែកតាមសមមាត្រលើបរិមាណដែលផលិតរហូតមកដល់ពេលនាំចូលលើកទីមួយ ។ ឧទាហរណ៍បន្ថែមទៀតគឺ អ្នកនាំចូលអាចសំណូមពរឲ្យបែងចែកតាមសមាមាត្រនូវតម្លៃទៅលើផលិតផលសរុបដែលបានព្រៀងទុក ប្រសិនជាមានកិច្ចសន្យាច្បាស់លាស់សម្រាប់ផលិតកម្មនោះ ។ វិធីសាស្ត្រនៃការបែងចែកតាមសមាមាត្រនេះគឺផ្អែកទៅតាមឯកសារដែលបានផ្តល់ដោយអ្នកនាំចូល ។

៤. ជាការបញ្ជាក់ឲ្យបានច្បាស់នូវវិធីសាស្រ្តដូចបានរៀបរាប់ខាងលើ ឧទាហរណ៍ថា អ្នកនាំចូលផ្តល់ឲ្យផលិតករនូវពុម្ពចាក់ដើម្បីប្រើប្រាស់នៅក្នុងការផលិតទំនិញនាំចូល និងចុះកិច្ចសន្យាជាមួយអ្នកផលិតថានឹងទិញទំនិញចំនួន ១០.០០០ ឯកតា ។ នៅខណៈពេលដែលការនាំចូលលើកទីមួយចំនួន ១.០០០ ឯកតា បានមកដល់ ផលិតករបានផលិតរួចរាល់ចំនួន ៤.០០០ ឯកតា ផ្សេងទៀត ។ អ្នកនាំចូលអាចស្នើសុំរដ្ឋបាលគយឲ្យធ្វើការបែងចែកតាមសមាមាត្រនៃតម្លៃពុម្ពចាក់លើចំនួនផលិតផល ១.០០០ ឯកតា, ៤.០០០ ឯកតា ឬ ១០.០០០ ឯកតា ។

**កថាខណ្ឌ ១ (ខ) (iv)**

១. ការបូកបន្ថែមសម្រាប់ភាគបន្សំដែលបានកំណត់នៅក្នុងកថាខណ្ឌ ១ (ខ) (iv) នៃមាត្រា ៨ ត្រូវផ្អែកលើទិន្នន័យដែលអាចវាស់វែងបាន ។ ដើម្បីបន្ថយនូវបន្ទុកសម្រាប់ទាំងអ្នកនាំចូល និងរដ្ឋបាលគយក្នុងការកំណត់តម្លៃដើម្បីបូកបន្ថែមនោះទិន្នន័យដែលមាននៅក្នុងប្រព័ន្ធកំណត់ត្រាពាណិជ្ជកម្មរបស់អ្នកទិញ គួរតែត្រូវប្រើប្រាស់ឲ្យបានច្រើនតាមលទ្ធភាពដែលអាចធ្វើទៅបាន ។

២. សម្រាប់ភាគបន្សំទាំងឡាយដែលបានផ្តល់ដោយអ្នកទិញ និងដែលបានទិញ ឬជួលដោយអ្នកទិញ ការបូកបន្ថែមគឺជាថ្លៃនៃការទិញ ឬជួលនោះ ។ មិនត្រូវធ្វើការបូកបន្ថែមនូវភាគបន្សំណាដែលជាកម្មសិទ្ធិសាធារណៈនោះឡើយ ក្រៅពីថ្លៃនៃការទទួលយកច្បាប់ចម្លងនៃភាគបន្សំទាំងនោះឡើយ ។

៣. ភាពងាយស្រួលដែលអាចកើតមានក្នុងការគណនាតម្លៃ ដែលត្រូវបូកបន្ថែមនឹងត្រូវផ្អែកទៅលើ រចនាសម្ព័ន្ធក្រុមហ៊ុន និងការគ្រប់គ្រង ព្រមទាំងវិធីសាស្រ្តគណនេយ្យ ។

៤. ឧទាហរណ៍៖ អាចមានករណីដែលថា ក្រុមហ៊ុនដែលនាំចូលនូវផលិតផលផ្សេងៗពីបណ្តាប្រទេសមួយចំនួនរក្សាទុកឯកសារនៃស្នាដៃគំនូសប្លង់ នៅក្រៅប្រទេសនាំចូលដើម្បីបង្ហាញឲ្យបានត្រឹមត្រូវនូវការកំណត់តម្លៃទំនិញ ។ ក្នុងករណីនេះ ការកែតម្រូវដោយផ្ទាល់អាចធ្វើឡើងដោយយោងតាមបញ្ញត្តិនៃមាត្រា ៨ ។

៥. ក្នុងករណីផ្សេងទៀត ក្រុមហ៊ុនអាចចាត់ទុកថ្លៃនៃស្នាដៃគំនូសប្លង់ ដែលស្ថិតនៅក្រៅប្រទេសនាំចូលថាជាការចំណាយមិនផ្ទាល់ទូទៅ ដោយមិនបែងចែកទៅក្នុងថ្លៃនៃផលិតផលជាក់លាក់ណាមួយទេ ។ ក្នុងខណៈនេះ ការកែតម្រូវដ៏ត្រឹមត្រូវអាចត្រូវធ្វើឡើងដោយយោងតាមបញ្ញត្តិនៃមាត្រា ៨ ដោយធ្វើការបែងចែកតាមសមាមាត្រនូវថ្លៃគំនូសប្លង់ទៅតាមបរិមាណសរុបនៃផលិតផល ហើយបូកបន្ថែមទៅលើថ្លៃនៃទំនិញនាំចូលទៅតាមចំនួនឯកតា ។

៦. ការប្រែប្រួលក្នុងករណីខាងលើ ជាចាំបាច់ត្រូវការគិតគូរពីកត្តាផ្សេងៗ ដើម្បីពិចារណានៅក្នុងការកំណត់ពីរបៀបបែងចែកថ្លៃតាមសមាមាត្រឲ្យបានត្រឹមត្រូវ ។

៧. ក្នុងករណីដែលការផលិតត្រូវបានធ្វើឡើងនៅក្នុងប្រទេសជាច្រើន និងក្នុងកំឡុងពេលវេលាមួយរយៈ ការកែតម្រូវគួរធ្វើនៅក្នុងកម្រិតនៃតម្លៃដែលបានបន្ថែមពិតប្រាកដចំពោះភាគបន្សំទាំងនោះដែលធ្វើនៅក្រៅប្រទេសនាំចូល ។

## កថាខណ្ឌ ១ (គ)

១. កម្រៃសួយសារ និងកម្រៃអាជ្ញាប័ណ្ណដែលមានចែងនៅក្នុងកថាខណ្ឌ ១ (គ) នៃមាត្រា ៨ អាចត្រូវបញ្ចូល ក្នុងចំណោមការចំណាយដទៃទៀតនូវ ៖ ប្រកាសនីយប័ត្រ តក្កកម្ម ពាណិជ្ជសញ្ញា និងកម្មសិទ្ធបញ្ញា ។ ទោះជាយ៉ាងណាក៏ដោយ កម្រៃសម្រាប់សិទ្ធផលិតឡើងវិញនូវទំនិញនាំចូលនៅក្នុងប្រទេសនាំចូល មិនត្រូវបូកបន្ថែមទៅលើថ្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដសម្រាប់ទំនិញនាំចូលដើម្បីកំណត់តម្លៃគិតពន្ធគយទេ ។

២. ការទូទាត់ដែលធ្វើឡើងដោយអ្នកទិញសម្រាប់សិទ្ធិចែកចាយ ឬលក់បន្តនៃទំនិញនាំចូលមិនត្រូវបូកបន្ថែមទៅលើថ្លៃដែលបានទូទាត់ឬនឹងត្រូវទូទាត់ពិតប្រាកដចំពោះទំនិញនាំចូលឡើយ បើសិនការទូទាត់នោះមិនមែនជាល័ក្ខខ័ណ្ឌនៃការលក់សម្រាប់នាំចេញទៅប្រទេសនាំចូល ។

## កថាខណ្ឌ ៣

នៅពេលដែលមិនមានទិន្នន័យអាចវាស់វែងបានពាក់ព័ន្ធនឹងការបន្ថែម ដែលតម្រូវឲ្យធ្វើឡើងតាមបញ្ញត្តិនៃមាត្រា ៨ តម្លៃចម្លងការមិនអាចកំណត់បាន ដោយយោងតាមបញ្ញត្តិនៃ មាត្រា ១ ឡើយ ។ ជាការបំភ្លឺលើបញ្ហានេះ ឧទាហរណ៍ កម្រៃសួយសារត្រូវបានទូទាត់ដោយផ្អែកលើមូលដ្ឋានថ្លៃនៃការលក់ក្នុងប្រទេសនាំចូលនូវតម្លៃឯកតាជាលីត្រនៃផលិតផលពិសេសណាមួយ ដែលបាននាំចូលជាគីឡូក្រាម ហើយលាយវាឲ្យទៅជាល្បាយក្រោយការនាំចូល ។ ប្រសិនបើកម្រៃសួយសារផ្អែកមួយផ្នែកទៅលើទំនិញនាំចូល និងមួយផ្នែកលើកត្តាដទៃទៀតដែលគ្មានទាក់ទងអ្វីទាំងអស់ជាមួយនិងទំនិញនាំចូល (ដូចជានៅពេលដែលទំនិញនាំចូលលាយឡំជាមួយគ្រឿងផ្សំក្នុងស្រុក និងមិនអាចញែកចេញពីគ្នាបាន ឬពេលដែលកម្រៃសួយសារមិនអាចបំបែកពីគ្នាបានតាមកិច្ចព្រមព្រៀងហិរញ្ញវត្ថុពិសេសរវាងអ្នកទិញនិងអ្នកលក់ ការព្យាយាមបន្ថែមនូវកម្រៃសួយសារជាការមិនត្រឹមត្រូវទេ ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើកម្រៃសួយសារផ្អែកតែទៅលើទំនិញនាំចូល និងអាចកម្រិតចំនួនបានយ៉ាងងាយស្រួល ការបូកបន្ថែមកម្រៃសួយសារចំពោះតម្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់អាចធ្វើឡើងបាន ។

**មាត្រា ៩.-**

១. ក្នុងករណីដែលចាំបាច់ដែលតម្រូវឲ្យមាន "ការប្តូរប្រភេទរូបិយប័ណ្ណ" សម្រាប់កំណត់តម្លៃគិតពន្ធគយ អត្រាប្តូរប្រាក់ដែលត្រូវប្រើ ត្រូវចេញឲ្យបានទៀងទាត់ដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនាំចូល និងឆ្លុះបញ្ចាំងប្រកបដោយប្រសិទ្ធភាពតាមតែអាចធ្វើទៅបាន ស្របទៅតាមពេលវេលានៃការចេញផ្សាយឯកសារអត្រាប្តូរប្រាក់ នូវតម្លៃដែលកំពុងអនុវត្តនៃរូបិយប័ណ្ណបរទេសនៅក្នុងកិច្ចចម្លងការ ជារូបិយប័ណ្ណនៃប្រទេសនាំចូល ។

២. ការប្រើប្រាស់អត្រាប្តូរប្រាក់ គឺជាអត្រាដែលចូលជាធរមាននៅពេលនាំចេញ ឬនាំចូលដូចដែលបានផ្តល់ ដោយប្រទេសជាសមាជិកនីមួយៗ ។

### កំណត់សំគាល់មាត្រា ៩

សម្រាប់គោលបំណងនៃមាត្រា ៩ "នៅពេលនាំចូល" អាចរួមបញ្ចូលទាំងពេលធ្វើបែបបទគយផងដែរ ។

**មាត្រា ១០.-**

គ្រប់ព័ត៌មានសម្ងាត់ ឬដែលនឹងត្រូវផ្តល់ជាការសម្ងាត់ សម្រាប់គោលបំណង កំណត់តម្លៃគិតពន្ធគយត្រូវបានរក្សាជាការសម្ងាត់បំផុត ដោយអាជ្ញាធរមានការពាក់ព័ន្ធ ដែលមិនត្រូវបញ្ចេញឲ្យគេដឹងដោយគ្មានការអនុញ្ញាតច្បាស់លាស់ពីបុគ្គល ឬពីរដ្ឋាភិបាល ដែលផ្តល់ព័ត៌មាននេះ លើកលែងតែក្នុងករណីដែលមានការតម្រូវក្នុងនីតិវិធីរបស់តុលាការ ។

**មាត្រា ១១.-**

១. ច្បាប់នៃប្រទេសសមាជិកនីមួយៗត្រូវបានផ្តល់នូវសិទ្ធិតវ៉ាក្នុងការកំណត់តម្លៃគិតពន្ធគយ ដោយគ្មានការផាកពិន័យទាំងអស់ដល់អ្នកនាំចូល ឬបុគ្គលដទៃទៀតដែលមានការកិច្ចបង់ពន្ធ និងអាករ ។

២. សិទ្ធិដំបូងសម្រាប់តវ៉ា ដែលមិនមានការផាកពិន័យត្រូវបានអនុញ្ញាតឲ្យធ្វើនៅចំពោះមុខរដ្ឋបាលគយ ឬអង្គភាពឯករាជ្យមួយ ប៉ុន្តែច្បាប់សម្រាប់ប្រទេសសមាជិកនីមួយៗត្រូវចែងអំពីសិទ្ធិបណ្តឹងតវ៉ាដោយគ្មានការផាកពិន័យនៅស្ថាប័នតុលាការទេ ។

៣.សេចក្តីសំរេចជាផ្លូវការស្តីពីការតវ៉ា ត្រូវបានផ្តល់ជូនទៅឲ្យអ្នកដាក់ពាក្យតវ៉ា និងហេតុផលនៃសេចក្តីសំរេចទាំងនេះត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ។ អ្នកតវ៉ាត្រូវបានជូនដំណឹងពីសិទ្ធិទាំងឡាយសម្រាប់ការតវ៉ាបន្តទៀត ។

## កំណត់សំគាល់មាត្រា ១១

១. មាត្រា ១១ ផ្តល់ឲ្យអ្នកនាំចូលនូវសិទ្ធិតវ៉ាប្រឆាំងនឹងការកំណត់តម្លៃគិតពន្ធគយ ដែលធ្វើឡើងដោយរដ្ឋបាលគយសម្រាប់ទំនិញដែលត្រូវកំណត់តម្លៃ ។ ជាដំបូងការតវ៉ាអាចធ្វើទៅមន្ត្រីថ្នាក់ខ្ពស់ក្នុងរដ្ឋបាលគយ ប៉ុន្តែអ្នកនាំចូលគួរតែមានសិទ្ធិធ្វើបណ្តឹងតវ៉ាទៅស្ថាប័នតុលាការ ។

២. ដោយ "គ្មានការផាកពិន័យ" មានន័យថាអ្នកនាំចូលមិនត្រូវឬទទួលរងនូវការផាកពិន័យ ឬការគម្រាមផាកពិន័យអ្វីទាំងអស់ ចំពោះការអនុវត្តសិទ្ធិតវ៉ារបស់គេ ។ ការបង់លើការចំណាយផ្នែកតុលាការ និងកម្រៃមេធាវីមិនត្រូវបានចាត់ទុកថាជាការពិន័យឡើយ ។

៣. ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងមាត្រា ១១ មិនបានរារាំងអាជ្ញាធរនៃប្រទេសសមាជិកពីការតម្រូវឲ្យបង់ពន្ធ និងអាករ ពេញមុនការដាក់ពាក្យតវ៉ាឡើយ ។

**មាត្រា ១២.-**

ច្បាប់ បទប្បញ្ញត្តិ សាលក្រមតុលាការ និងលិខិតបទដ្ឋានផ្សេងៗនៃការអនុវត្តជាទូទៅ ដែលផ្តល់នូវប្រសិទ្ធភាពចំពោះកិច្ចព្រមព្រៀងនេះ ត្រូវបោះពុម្ពផ្សាយជាសាធារណៈ ស្របតាមមាត្រា ១០ នៃ GATT ១៩៩៤ ដោយប្រទេសនាំចូល ។

**មាត្រា ១៣.-**

ក្នុងការកំណត់តម្លៃគិតពន្ធគយនៃទំនិញនាំចូល ប្រសិនបើមានការចាំបាច់ តម្រូវឲ្យធ្វើការពន្យារពេលនៃការសម្រេចចុងក្រោយនៃតម្លៃគិតពន្ធគយ អ្នកនាំចូលអាចស្នើសុំបញ្ចេញទំនិញពីគយជាមុនបាន ក្នុងករណីអ្នកនាំចូលអាចតម្កល់និមុត្តិធានា តាមទម្រង់ផ្សេងៗ ដែលអាចទទួលយកបាន ហើយអាចធានាបាននូវបរិមាណខ្ពស់បំផុតនៃប្រាក់ពន្ធ និងអាករចំពោះទំនិញដែលត្រូវបង់ ។ ច្បាប់នៃប្រទេសជាសមាជិកនីមួយៗត្រូវមាននូវបញ្ញត្តិនានាស្តីពីករណីនេះ ។

**មាត្រា ១៤.-**

កំណត់សំគាល់ក្នុងឧបសម្ព័ន្ធទី I របស់កិច្ចព្រមព្រៀងនេះបង្កើតឡើងនូវផ្នែកដ៏សំខាន់នៃកិច្ចព្រមព្រៀង និងមាត្រានៃកិច្ចព្រមព្រៀងនេះត្រូវបានអាន និងអនុវត្តជាមួយនឹងកំណត់សំគាល់នៃមាត្រានីមួយៗនោះ ។ ឧបសម្ព័ន្ធ II និងឧបសម្ព័ន្ធ III ក៏បង្កើតឡើងនូវផ្នែកដ៏សំខាន់របស់កិច្ចព្រមព្រៀងនេះដែរ ។

**មាត្រា ១៥.-**

១. ក្នុងកិច្ចព្រមព្រៀងនេះ ៖

(ក)- "តម្លៃគិតពន្ធគយនៃទំនិញនាំចូល" មានន័យថាជាតម្លៃទំនិញសម្រាប់គោលបំណងនៃការបង់ពន្ធគយទៅតាមតម្លៃទំនិញនាំចូល (Ad-valorem duties) ។

(ខ)- " ប្រទេសនាំចូល" មានន័យថាប្រទេស ឬដែនរបស់គយនៃការនាំចូល

(គ)- "ដែលបានផលិត" រួមមាន ការចិញ្ចឹម ការដាំដុះ ការផលិត និងការយកចេញពីធរណី ។

២. ក្នុងកិច្ចព្រមព្រៀងនេះ ៖

(ក)- "ទំនិញដូចគ្នា" មានន័យថាទំនិញដែលមានលក្ខណៈដូចគ្នាលើគ្រប់ទិដ្ឋភាពទាំងអស់ រួមទាំងលក្ខណៈរូប គុណភាព និងកេរ្តិ៍ឈ្មោះ ។ ប៉ុន្តែភាពខុសគ្នាបន្តិចបន្តួចខាងរូបរាងមិនអាចចាត់ទុកថាទំនិញមិនដូចគ្នាតាមនិយមន័យនៃទំនិញដូចគ្នាខាងលើឡើយ ។

(ខ)- "ទំនិញប្រហាក់ប្រហែលគ្នា" មានន័យថាទំនិញ ទោះបីជាមិនដូចគ្នាលើគ្រប់ទិដ្ឋភាពក៏ដោយ មានលក្ខណៈដូចគ្នា និងមានវត្ថុធាតុផ្សំដូចគ្នាដែលអាចធ្វើឲ្យទំនិញនោះបំពេញតួនាទីដូចគ្នា និងអាចជំនួសគ្នាបានក្នុងវិស័យពាណិជ្ជកម្ម ។ គុណភាពទំនិញ កេរ្តិ៍ឈ្មោះ និងផ្លាកសញ្ញាដែលកំពុងប្រើ គឺជាកត្តាដើម្បីពិចារណាក្នុងការកំណត់ថា តើទំនិញនោះប្រហាក់ប្រហែលគ្នាឬទេ ។

(គ)- ពាក្យថា "ទំនិញដូចគ្នា" និង "ទំនិញប្រហាក់ប្រហែលគ្នា" មិនរាប់បញ្ចូលនូវករណី ដែលទំនិញភ្ជាប់ ឬផ្ទុះបញ្ចាំងនូវការងារវិស្វកម្ម ស្ថាបត្យកម្ម គំនូរ ប្លង់ និងគំនូសវាស ដែលគ្មានការកែតម្រូវត្រូវបានធ្វើឡើងយោងតាមកថាខណ្ឌ ១ (ខ) (៤) នៃមាត្រា ៨ ដោយសារចំណុចទាំងនេះត្រូវបានធ្វើឡើងនៅក្នុងប្រទេសនាំចូល ។

(ឃ)- ទំនិញដែលមិនត្រូវចាត់ទុកជា "ទំនិញដូចគ្នា" ឬ "ទំនិញប្រហាក់ប្រហែលគ្នា" បើទំនិញទាំងនោះមិនបានផលិតនៅក្នុងប្រទេសដូចគ្នាទៅនឹងទំនិញដែលត្រូវកំណត់តម្លៃ ។

(ង)- ទំនិញដែលបានផលិតដោយបុគ្គលផ្សេងគ្នាត្រូវបានយកមកពិចារណាដើម្បីចាត់ទុកថាជាទំនិញមិនដូចគ្នា ឬប្រហាក់ប្រហែលគ្នា តែក្នុងករណីដែលមិនមានទំនិញដែលផលិតដោយបុគ្គលដូចគ្នាទៅនឹងទំនិញដែលត្រូវកំណត់តម្លៃ ។

៣. ក្នុងកិច្ចព្រមព្រៀងនេះ " ទំនិញស្ថិតនៅក្នុងក្រុម ឬប្រភេទដូចគ្នា " មានន័យថាទំនិញដែលស្ថិតនៅក្នុងក្រុម ឬលំដាប់ដែលបានផលិតដោយឧស្សាហកម្ម ឬផ្នែកឧស្សាហកម្មជាក់លាក់ណាមួយ និងរួមបញ្ចូលទំនិញដូចគ្នា ឬប្រហាក់ប្រហែលគ្នា ។

៤. ក្នុងគោលបំណងនៃកិច្ចព្រមព្រៀងនេះ បុគ្គលដែលចាត់ទុកថាមានការពាក់ព័ន្ធ គឺ ៖

(ក)- អ្នកនោះជាបុគ្គលិក ឬនាយករបស់សហគ្រាសមួយ ។

(ខ)- អ្នកនោះជាដៃគូរនៅក្នុងពាណិជ្ជកម្មដែលទទួលស្គាល់ដោយច្បាប់ ។

(គ)- អ្នកនោះជានិយោជក ឬនិយោជិក ។

(ឃ)- ជាបុគ្គលកាន់កាប់ ឬជាអ្នកគ្រប់គ្រងដោយផ្ទាល់ ឬដោយប្រយោល ចំនួន ៥ ភាគរយ ឬលើសពីនេះ នូវសិទ្ធបោះឆ្នោតផ្សារហ៊ុន ឬភាគហ៊ុន ។

(ង)- ជាបុគ្គលម្នាក់គ្រប់គ្រងដោយផ្ទាល់ ឬដោយប្រយោលចំពោះបុគ្គលម្នាក់ទៀត ។

(ច)-បុគ្គលទាំងពីរនាក់ត្រូវបានគ្រប់គ្រងដោយផ្ទាល់ ឬដោយប្រយោលដោយជនទី ៣

(ឆ)- ទាំងអស់គ្នាគ្រប់គ្រងដោយផ្ទាល់ ឬដោយប្រយោលចំពោះជនទី ៣ ។

(ជ)- ពួកគេជាសមាជិកគ្រួសារតែមួយ ។

៥. បុគ្គលដែលពាក់ព័ន្ធក្នុងធុរៈកិច្ចជាមួយបុគ្គលម្នាក់ទៀត ក្នុងលក្ខណៈជាភ្នាក់ងារផ្តាច់មុខ ឬអ្នកចែកចាយផ្តាច់មុខ ឬអ្នកទទួលលក់ផ្តាច់មុខ ត្រូវចាត់ទុកថាមានការពាក់ព័ន្ធគ្នាសម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ ប្រសិនបើវាស្ថិតនៅក្នុងលក្ខណៈវិនិច្ឆ័យដែលចែងក្នុងកថាខណ្ឌ ៤ ។

## **កំណត់សំគាល់មាត្រា ១៥**
## **កថាខណ្ឌ ៤**

ក្នុងគោលបំណងនៃមាត្រា ១៥ ពាក្យថា " បុគ្គល " រួមបញ្ចូល "នីតិបុគ្គល" ផងដែរ ។

## **កថាខណ្ឌ ៤ (ខ)**

ក្នុងគោលបំណងនៃកិច្ចព្រមព្រៀងនេះ បុគ្គលម្នាក់អាចចាត់ទុកថាជាអ្នកគ្រប់គ្រងបុគ្គលម្នាក់ទៀត នៅពេលដែលបុគ្គលទី ១ នោះគឺជានីត្យានុកូល ឬអានុភាពនៅក្នុងតួនាទី ឬដឹកនាំទៅលើបុគ្គលទី២ ។

**មាត្រា ១៦.-**

អាស្រ័យដោយមានការស្នើសុំជាលាយលក្ខណ៍អក្សរ អ្នកនាំចូលត្រូវមានសិទ្ធិទទួលការពន្យល់ជាលាយលក្ខណ៍អក្សរពីរដ្ឋបាលគយនៃប្រទេសនាំចូល ពីរបៀបកំណត់តម្លៃតម្លៃគិតពន្ធគយលើទំនិញនាំចូល ។

**មាត្រា ១៧.-**

មិនមានបញ្ញត្តិណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបកស្រាយជាការរឹតត្បិត ឬជាការចោទជាបញ្ហានូវសិទ្ធិរបស់រដ្ឋបាលគយ ដើម្បីទាមទាររកនូវការពិត ឬទៅលើភាពត្រឹមត្រូវនៃឯកសារ ការអះអាង ឬការប្រកាសដែលធ្វើឡើងសម្រាប់គោលបំណងកំណត់តម្លៃគិតពន្ធគយឡើយ ។

## ផ្នែកទី II
## ការគ្រប់គ្រង ការពិគ្រោះយោបល់ និងការដោះស្រាយជម្លោះ

**មាត្រា ១៨.-**

**ស្ថាប័ន**

១. ត្រូវបានបង្កើតនូវគណៈកម្មាធិការកំណត់តម្លៃគិតពន្ធគយ (នៅក្នុងកិច្ចព្រមព្រៀងហៅថា "គណៈកម្មាធិការ") ដែលមានតំណាងមកពីគ្រប់ប្រទេសសមាជិក ។ គណៈកម្មាធិការត្រូវជ្រើសរើសប្រធានដោយខ្លួនឯង ហើយជាធម្មតាត្រូវជួបប្រជុំ ១ ដងក្នុងមួយឆ្នាំ ឬដូចដែលបានកំណត់ដោយបញ្ញត្តិពាក់ព័ន្ធផ្សេងទៀតនៅក្នុងកិច្ចព្រមព្រៀងនេះ ក្នុងគោលបំណងផ្តល់ដល់សមាជិកនូវកាលានុវត្តភាពគ្រប់គ្រាន់ ដើម្បីពិភាក្សាលើបញ្ហាដែលពាក់ព័ន្ធទៅនឹងប្រព័ន្ធកំណត់តម្លៃគិតពន្ធគយ ដោយសមាជិកណាមួយដែលមានការប៉ះពាល់នៃការអនុវត្តកិច្ចព្រមព្រៀង ឬការលើកតម្កើងនូវគោលបំណងនិងការទទួលខុសត្រូវដូចដែលបានរៀបចំដោយសមាជិកនីមួយៗ ។ លេខាធិការអគ្គការពាណិជ្ជកម្មពិភពលោក ត្រូវដើរតួនាទីជាលេខាធិការរបស់គណៈកម្មាធិការនេះ ។

២. គណៈកម្មាធិការបច្ចេកទេស លើការកំណត់តម្លៃគិតពន្ធគយ ត្រូវបានបង្កើតឡើង (យោងតាមកិច្ចព្រមព្រៀងនេះហៅថា "គណៈកម្មាធិការបច្ចេកទេស" ក្រោមអធិបតីភាពរបស់ក្រុមប្រឹក្សាសហប្រតិបត្តិការគយដែលហៅកាត់ថា " CCC " ) ដែលទទួលខុសត្រូវ

ដូចដែលបានបរិយាយនៅក្នុងឧបសម្ព័ន្ធ II នៃកិច្ចព្រមព្រៀង និងប្រតិបត្តិដោយស្របទៅតាមនីតិវិធីដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ។

**មាត្រា ១៩.-**

## ការពិគ្រោះយោបល់ និងការដោះស្រាយជម្លោះ

១.លើកលែងបញ្ញត្តិផ្ទុយពីនេះ អនុសារណៈនៃកិច្ចព្រមព្រៀងស្តីពីការដោះស្រាយជំលោះត្រូវអនុវត្តទៅតាមកិច្ចពិភាក្សា និងការដោះស្រាយជម្លោះដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ ។

២. ប្រសិនបើសមាជិកណាមួយយល់ថា សកម្មភាពរបស់សមាជិកណាមួយឬប្រទេសជាសមាជិកផ្សេងទៀតកំពុងធ្វើឲ្យបាត់បង់ ឬធ្វើឲ្យខូចខាតនូវផលប្រយោជន៍ ឬការសំរេចនូវគោលបំណងណាមួយនៃការអនុវត្តកិច្ចព្រមព្រៀងនេះ ប្រទេសជាសមាជិកនោះអាចស្នើសុំធ្វើការពិភាក្សាជាមួយប្រទេសម្ខាងទៀត ដោយឈរលើមូលដ្ឋានឈានទៅរកដំណោះស្រាយមួយដែលពេញចិត្តចំពោះភាគីទាំងសងខាង ។ ប្រទេសនីមួយៗត្រូវប្រកាន់យកនូវភាពអត់ធ្មត់ក្នុងការពិចារណាលើសំណើ ដែលបានលើកឡើងដោយប្រទេសជាសមាជិកផ្សេងទៀត ។

៣. យោងតាមការស្នើសុំ គណៈកម្មាធិការបច្ចេកទេសត្រូវផ្តល់នូវយោបល់ និងជំនួយដល់ប្រទេសជាសមាជិក ដែលជាប់ពាក់ព័ន្ធក្នុងការពិភាក្សា ។

៤. តាមសំណើនៃភាគីជម្លោះ ឬដោយតាមការផ្តើមគំនិតផ្ទាល់ខ្លួន ក្រុមការងារពិសេសមួយដែលបានបង្កើតឡើងសម្រាប់ត្រួតពិនិត្យជម្លោះដែលពាក់ព័ន្ធទៅនឹងបញ្ញត្តិនៃកិច្ចព្រមព្រៀង អាចស្នើទៅគណៈកម្មាធិការបច្ចេកទេសដើម្បីអនុវត្តការត្រួតពិនិត្យ នូវបញ្ហាទាំងឡាយដែលតម្រូវឲ្យមានការពិចារណាផ្នែកបច្ចេកទេស ។ ក្រុមការងារនេះត្រូវកំណត់នូវល័ក្ខខ័ណ្ឌយោងរបស់គណៈកម្មាធិការបច្ចេកទេស សម្រាប់ករណីជម្លោះជាក់ស្តែងនីមួយៗ និងកំណត់ពេលវេលាសម្រាប់ទទួលរបាយការណ៍ពីគណៈកម្មាធិការបច្ចេកទេស ។ ក្រុមការងារនេះត្រូវពិចារណានូវរបាយការណ៍របស់គណៈកម្មាធិការបច្ចេកទេស ។ ក្នុងករណីដែលគណៈកម្មាធិការបច្ចេកទេសគ្មានលទ្ធភាពសម្រុះសម្រួលលើ

ជម្លោះនេះបាន ក្នុងកថាខណ្ឌនេះក្រុម ការងារត្រូវផ្តល់ទៅភាគីជំលោះនូវឱកាសគ្រប់គ្រាន់ ដើម្បីបង្ហាញនូវគំនិតរបស់គេលើបញ្ហាជម្លោះនោះ ។

៥. ព័ត៌មានសម្ងាត់ដែលផ្តល់ចំពោះក្រុមការងារមិនត្រូវបានបង្ហាញដោយគ្មានការអនុញ្ញាតជាផ្លូវការពីបុគ្គល ឬអាជ្ញាធរដែលផ្តល់ព័ត៌មានទាំងនោះទេ ។ នៅពេលដែលព័ត៌មានទាំងនោះត្រូវបានស្នើសុំពីក្រុមការងារ ប៉ុន្តែមិនអនុញ្ញាតឲ្យធ្វើការបញ្ចេញនូវព័ត៌មានទាំងនោះ បុគ្គល ឬអាជ្ញាធរត្រូវផ្តល់នូវសេចក្តីសង្ខេបនៃព័ត៌មានដែលមិនតម្រូវរក្សាសម្ងាត់ទៅក្រុមការងារ ។

## ផ្នែកទី III
## ប្រព្រឹត្តកម្មពិសេស និង ផ្សេងៗគ្នា

**មាត្រា ២០.-**

១. សមាជិកនៃប្រទេសកំពុងអភិវឌ្ឍន៍ដែលមិនមែនជាភាគីនៃកិច្ចព្រមព្រៀងស្តីពីការអនុវត្តមាត្រា VII នៃ កិច្ចព្រមព្រៀងទូទៅស្តីពីតារាងពន្ធគយ និងពាណិជ្ជកម្ម ដែលបានអនុម័តនៅថ្ងៃទី ១២ ខែ មេសា ឆ្នាំ ១៩៧៩ អាចពន្យាពេលការអនុវត្តកិច្ចព្រមព្រៀងសម្រាប់រយៈពេលមិនលើសពី ៥ ឆ្នាំ ចាប់ពីថ្ងៃនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកសម្រាប់ប្រទេសជាសមាជិក ។ ហេតុដូច្នេះ សមាជិកនៃប្រទេសកំពុងអភិវឌ្ឍន៍ ដែលជ្រើសរើសយកការពន្យាពេលអនុវត្តកិច្ចព្រមព្រៀងត្រូវផ្តល់ព័ត៌មានទៅអគ្គលេខាអង្គការពាណិជ្ជកម្មពិភពលោកឲ្យបានឆាប់តាមដែលអាចធ្វើបាន ។

២. បន្ថែមចំពោះកថាខណ្ឌ ១ ប្រទេសកំពុងអភិវឌ្ឍន៍ដែលមិនមែនជាភាគីនៃកិច្ចព្រមព្រៀងស្តីពីមាត្រា VII នៃកិច្ចព្រមព្រៀងទូទៅនៃតារាងពន្ធគយ និងពាណិជ្ជកម្ម ដែលបានអនុម័តនៅថ្ងៃទី១២ ខែមេសា ឆ្នាំ ១៩៧៩ អាចពន្យារពេលការអនុវត្តកថាខណ្ឌ ២ (ខ) (iii) នៃមាត្រា ១ និងមាត្រា ៦ សម្រាប់រយៈពេលមិនលើសពី ៣ ឆ្នាំ បន្ទាប់ពីការអនុវត្តបញ្ញត្តិនានានៃកិច្ចព្រមព្រៀងនេះ ។ សមាជិកប្រទេសកំពុងអភិវឌ្ឍន៍ដែលធ្វើការជ្រើសរើសការពន្យារពេលសម្រាប់អនុវត្តបញ្ញត្តិនៃកថាខណ្ឌនេះ ត្រូវផ្តល់ព័ត៌មានទៅអគ្គលេខាអង្គការពាណិជ្ជកម្មពិភពលោកតាមដែលអាចធ្វើទៅបាន ។

៣. សមាជិកនៃប្រទេសអភិវឌ្ឍន៍ត្រូវផ្តល់នូវជំនួយបច្ចេកទេសដល់សមាជិកនៃប្រទេសកំពុងអភិវឌ្ឍន៍តាមការស្នើសុំ ដោយឈរលើមូលដ្ឋានកិច្ចព្រមព្រៀងទ្វេភាគី ។ ផ្អែកលើមូលដ្ឋាននេះ សមាជិកនៃប្រទេសកំពុងអភិវឌ្ឍន៍ត្រូវព្រាងនូវកម្មវិធីជំនួយបច្ចេកទេស ដែលរួមបញ្ចូលនូវបញ្ហាផ្សេងៗដូចជា ការបណ្តុះបណ្តាលបុគ្គលិក ជំនួយក្នុងការរៀបចំការអនុវត្តវិធាននានា ការចាប់យកប្រភពព័ត៌មានទាក់ទងទៅនឹងវិធីសាស្ត្រនៃការកំណត់តម្លៃគិតពន្ធគយ និងការណែនាំស្តីពីការអនុវត្តនូវបញ្ញត្តិនានានៃកិច្ចព្រមព្រៀងនេះ ។

## ភាគ VI
## អវសានប្បញ្ញត្តិ

**មាត្រា ២១.-**

### ការត្រៀមបំរុង

បញ្ញត្តិត្រៀមបំរុង ទាក់ទងនឹងបទប្បញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងនេះ មិនអាចធ្វើឡើងដោយគ្មានការយល់ព្រមពីសមាជិកដទៃទៀតឡើយ ។

**មាត្រា ២២.-**

### ច្បាប់ជាតិ

១.សមាជិកនីមួយៗត្រូវធានាមិនឲ្យយឺតជាងកាលបរិច្ឆេទនៃការអនុវត្តបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះដើម្បីឲ្យច្បាប់វិធាន និងនីតិវិធីរដ្ឋបាលនានារបស់ជាតិស្របតាមកិច្ចព្រមព្រៀងដែលបានចែង ។

២. សមាជិកនីមួយៗត្រូវជូនដំណឹងដល់គណៈកម្មាធិការនូវរាល់ការកែប្រែច្បាប់ និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធទៅនឹងកិច្ចព្រមព្រៀង នៅក្នុងការគ្រប់គ្រងអនុវត្តច្បាប់ និងបទប្បញ្ញត្តិទាំងនោះ ។

**មាត្រា ២៣.-**

### ការពិនិត្យឡើងវិញ

គណៈកម្មាធិការត្រូវពិនិត្យឡើងវិញប្រចាំឆ្នាំនូវការអនុវត្ត និងការប្រតិបត្តិកិច្ចព្រមព្រៀងដែលពិចារណាពីគោលបំណងទាំងនេះ ។ គណៈកម្មាធិការត្រូវជូនដំណឹងប្រចាំឆ្នាំទៅក្រុមប្រឹក្សាពាណិជ្ជកម្មពីការអភិវឌ្ឍន៍កំឡុងពេលត្រូវពិនិត្យឡើងវិញទាំងនេះ ។

**មាត្រា ២៤.-**

## លេខាធិការដ្ឋាន

កិច្ចព្រមព្រៀងនេះ ត្រូវរៀបចំដោយលេខាធិការដ្ឋាននៃអង្គការពាណិជ្ជកម្មពិភពលោក លើកលែងតែការទទួលខុសត្រូវជាពិសេសដែលត្រូវប្រគល់ជូនគណៈកម្មាធិការបច្ចេកទេស ត្រូវរៀបចំដោយលេខាធិការដ្ឋាននៃក្រុមប្រឹក្សាសហប្រតិបត្តិការគយ (C.C.C) ។

## ឧបសម្ព័ន្ធ I
## កំណាត់ពន្យល់

កំណាត់ពន្យល់ត្រូវបានដាក់ភ្ជាប់ជាមួយមាត្រានីមួយៗដែលពាក់ព័ន្ធ ។

## ឧបសម្ព័ន្ធ II
## គណៈកម្មាធិការបច្ចេកទេសស្តីពីការកំណត់តម្លៃគិតពន្ធគយ

១. ស្របទៅនឹងមាត្រា ១៨ នៃកិច្ចព្រមព្រៀងនេះ គណៈកម្មាធិការបច្ចេកទេស ត្រូវបានបង្កើតឡើងក្រោមអធិបតីភាពនៃក្រុមប្រឹក្សាសហប្រតិបត្តិការគយ (C.C.C) ដើម្បីជានាក្នុងកម្រិតបច្ចេកទេស នូវភាពឯកភាពគ្នាខាងការបកស្រាយនិងអនុវត្តកិច្ចព្រមព្រៀងនេះ ។

២. ការទទួលខុសត្រូវរបស់គណៈកម្មាធិការរួមមានដូចខាងក្រោម ៖

(ក)- ពិនិត្យពីបញ្ហាបច្ចេកទេសជាក់ស្តែង ដែលកើតមានឡើងក្នុងការងាររដ្ឋបាលប្រចាំថ្ងៃនៃប្រព័ន្ធកំណត់តម្លៃគិតពន្ធគយរបស់ប្រទេសជាសមាជិក និងផ្តល់នូវគំនិតជាការណែនាំស្តីពីដំណោះស្រាយពាក់ព័ន្ធ ដោយផ្អែកលើមូលដ្ឋានតថភាពដែលបានកើតឡើង ។

(ខ)- ធ្វើការសិក្សាតាមការស្នើសុំនូវច្បាប់ស្តីពីការកំណត់តម្លៃគិតពន្ធគយ នីតិវិធី និងការអនុវត្តដែលមានការពាក់ព័ន្ធទៅនឹងកិច្ចព្រមព្រៀង និងរៀបចំរបាយការណ៍ស្តីពី លទ្ធផលនៃការសិក្សាទាំងនេះ ។

(គ)- បង្កើត និងបែងចែករបាយការណ៍ប្រចាំឆ្នាំស្តីពីទិដ្ឋភាពបច្ចេកទេសនៃកិច្ចប្រតិបត្តិការ និងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ ។

(ឃ)- ផ្តល់នូវព័ត៌មានបែបនេះ និងការណែនាំស្តីពីបញ្ហានានាដែលពាក់ព័ន្ធទៅនឹងការកំណត់តម្លៃគិតពន្ធគយលើទំនិញនាំចូល ទៅតាមការស្នើសុំរបស់សមាជិក ឬគណៈកម្មាធិការ ។ ព័ត៌មាន និងការណែនាំទាំងនេះអាចមានទម្រង់ជាគំនិតណែនាំ (Advisory Opinion) ការធ្វើអត្ថាធិប្បាយ (Commentaries) និងកំណត់ពន្យល់ (Explanatory Notes) ។

(ង)- ផ្តល់តាមការស្នើសុំ នូវជំនួយបច្ចេកទេសចំពោះសមាជិកក្នុងន័យដើម្បីបង្កើនថែមទៀតនូវការទទួលយកជាអន្តរជាតិលើកិច្ចព្រមព្រៀងនេះ ។

(ច)- អនុវត្តការត្រួតពិនិត្យលើបញ្ហាពាក់ព័ន្ធដោយក្រុមការងារក្នុងមាត្រា ១៩ នៃកិច្ចព្រមព្រៀងនេះ ។

(ឆ)- ប្រតិបត្តិនូវការទទួលខុសត្រូវផ្សេងទៀតដូចដែលគណៈកម្មាធិការបានចាត់តាំង ។

## លក្ខណៈទូទៅ

៣. គណៈកម្មាធិការបច្ចេកទេស ត្រូវតែព្យាយាមបញ្ចប់នូវកិច្ចការរបស់ខ្លួនលើបញ្ហាជាក់ស្តែង ជាពិសេសអ្វីដែលបានស្នើដោយសមាជិកគណៈកម្មាធិការ ឬក្រុមការងារ នៅក្នុងរយៈពេលខ្លីសមរម្យណាមួយ ។ ដូចដែលមានចែងក្នុងកថាខណ្ឌ ៤ នៃមាត្រា ១៩ ក្រុមការងារត្រូវកំណត់រយៈពេលជាក់លាក់ ក្នុងការទទួលយករបាយការណ៍ពីគណៈកម្មាធិការបច្ចេកទេស ហើយគណៈកម្មាធិការបច្ចេកទេសផ្តល់នូវរបាយការណ៍តាមរយៈពេលដែលបានកំណត់នោះ ។

៤. លេខាធិការដ្ឋានក្រុមប្រឹក្សាសហប្រតិបត្តិការគយ (C.C.C) ត្រូវផ្តល់ជំនួយឲ្យបានសមស្របដល់គណៈកម្មាធិការបច្ចេកទេស ក្នុងសកម្មភាពការងាររបស់គេ ។

## តំណាង

៥. សមាជិកនីមួយៗ មានសិទ្ធបញ្ជូននូវតំណាងរបស់ខ្លួនទៅគណៈកម្មាធិការបច្ចេកទេស ។ សមាជិកនីមួយៗ អាចតែងតាំងប្រតិភូមួយ ឬច្រើនផ្លាស់គ្នាដើម្បីធ្វើជាតំណាងនៅគណៈកម្មាធិការបច្ចេកទេស ។ សមាជិកដែលមានតំណាងរបស់ខ្លួននៅគណៈកម្មាធិការបច្ចេកទេសយោងទៅតាមឧបសម្ព័ន្ធនេះត្រូវហៅថាជា: "សមាជិកគណៈ

កម្មាធិការបច្ចេកទេស" ។ តំណាងសមាជិកនីមួយៗនៃគណៈកម្មាធិការបច្ចេកទេសអាចត្រូវជួយដោយទីប្រឹក្សានានា ។ លេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោកអាចចូលរួមក្នុងកិច្ចប្រជុំទាំងនោះក្នុងឋានៈជាអ្នកសង្កេតការណ៍ ។

៦. សមាជិក C.C.C ដែលមិនមែនជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក អាចមានវត្តមានក្នុងកិច្ចប្រជុំនៃគណៈកម្មាធិការបច្ចេកទេស ដោយគណៈប្រតិភូមួយនាក់ ឬច្រើននាក់ផ្ទាល់គ្នា ។ តំណាងទាំងនោះអាចចូលរួមប្រជុំជាមួយគណៈកម្មាធិការបច្ចេកទេសក្នុងឋានៈជាអ្នកសង្កេតការណ៍ ។

៧. ចំពោះការសំរេចរបស់ប្រធានគណៈកម្មាធិការបច្ចេកទេស អគ្គលេខាធិការនៃ C.C.C (យោងនៅក្នុងឧបសម្ព័ន្ធជា " អគ្គលេខាធិការ " ) អាចអញ្ជើញតំណាងរដ្ឋាភិបាលដែលមិនមែនជាប្រទេសសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក ឬមិនមែនជាសមាជិកនៃ C.C.C និងតំណាងអង្គការអន្តរជាតិ និងអង្គការពាណិជ្ជកម្ម ដើម្បីចូលរួមកិច្ចប្រជុំគណៈកម្មាធិការបច្ចេកទេសក្នុងឋានៈជាអ្នកសង្កេតការណ៍ ។

៨. ការតែងតាំងគណៈប្រតិភូ ការផ្លាស់វេនគ្នា និងទីប្រឹក្សាដើម្បីចូលរួមប្រជុំនៅគណៈកម្មាធិការបច្ចេកទេសត្រូវបានធ្វើឡើងដោយអគ្គលេខាធិការ ។

## កិច្ចប្រជុំគណៈកម្មាធិការបច្ចេកទេស

៩. គណៈកម្មាធិការបច្ចេកទេសត្រូវជួបប្រជុំតាមការចាំបាច់ ប៉ុន្តែយ៉ាងតិចបំផុត ២ ដងក្នុងមួយឆ្នាំ ។ ថ្ងៃខែនៃកិច្ចប្រជុំនីមួយៗត្រូវបានកំណត់ដោយគណៈកម្មាធិការនៅមុនសម័យប្រជុំ ។ ថ្ងៃខែនៃកិច្ចប្រជុំអាចផ្លាស់ប្តូរប្រែប្រួលតាមការស្នើសុំនៃសមាជិកណាមួយរបស់គណៈកម្មាធិការបច្ចេកទេស ដែលព្រមព្រៀងនៅក្នុងសំលេងភាគច្រើននៃសមាជិករបស់គណៈកម្មាធិការបច្ចេកទេស ឬក្នុងករណីតម្រូវការចាំបាច់ត្រូវកោះប្រជុំជាបន្ទាន់តាមការស្នើសុំរបស់ប្រធាន ។ ថ្វីបើមានបញ្ញត្តិនៅក្នុងប្រយោគទី ១ នៃកថាខណ្ឌនេះ គណៈកម្មាធិការបច្ចេកទេសត្រូវជួបប្រជុំតាមការចាំបាច់ ដើម្បីពិចារណាលើបញ្ហា ដែលលើកឡើងដោយក្រុមការងារក្នុងបញ្ញត្តិនៃមាត្រា ១៩ របស់កិច្ចព្រមព្រៀងនេះ ។

១០. កិច្ចប្រជុំរបស់គណៈកម្មាធិការបច្ចេកទេសត្រូវប្រារព្ធធ្វើឡើងនៅទីស្នាក់ការកណ្តាលរបស់ C.C.C លើកលែងតែមានការសម្រេចផ្សេងទៀត ។

១១.	អគ្គលេខាធិការត្រូវជូនដំណឹងដល់សមាជិកទាំងអស់នៃគណៈកម្មាធិការបច្ចេកទេស និងផ្នែកពាក់ព័ន្ធដទៃទៀតដែលមានចែងនៅក្នុងកថាខណ្ឌទី ៦ និង ៧ យ៉ាងតិចចំនួន ៣០ ថ្ងៃមុនថ្ងៃបើកកិច្ចប្រជុំនីមួយៗ លើកលែងតែក្នុងករណីបន្ទាន់ ។

**របៀបវារៈ**

១២. របៀបវារៈបណ្តោះអាសន្នសម្រាប់សម័យប្រជុំនីមួយៗ ត្រូវបានរៀបចំឡើងដោយអគ្គលេខាធិការ និងចែកជូនដល់សមាជិកនៃគណៈកម្មាធិការបច្ចេកទេស និងផ្នែកពាក់ព័ន្ធដទៃទៀតមានចែងក្នុងកថាខណ្ឌ ៦ និងកថាខណ្ឌ ៧ យ៉ាងតិចចំនួន៣០ថ្ងៃ មុនថ្ងៃបើកសម័យប្រជុំ លើកលែងតែក្នុងករណីបន្ទាន់ ។ របៀបវារៈនេះ ត្រូវបញ្ចូលគ្រប់បញ្ហាទាំងអស់ ដែលការដាក់បញ្ចូលទាំងនេះត្រូវមានការយល់ព្រមពីគណៈកម្មាធិការបច្ចេកទេស ក្នុងរយៈពេលនៃសម័យប្រជុំលើកមុន ចំណុចទាំងអស់ដែលបានដាក់បញ្ចូលតាមការផ្តួចផ្តើមរបស់ប្រធានផ្ទាល់ និងគ្រប់ចំណុចដែលបានស្នើសុំដោយអគ្គលេខាធិការ ដោយគណៈកម្មាធិការ ឬដោយសមាជិកណាមួយនៃគណៈកម្មាធិការបច្ចេកទេស ។

១៣. គណៈកម្មាធិការបច្ចេកទេសត្រូវកំណត់នូវរបៀបវារៈក្នុងពិធីបើកសម័យប្រជុំនីមួយៗ ។ ក្នុងពេលសម័យប្រជុំ របៀបវារៈអាចត្រូវកែប្រែក្នុងពេលណាមួយដោយគណៈកម្មាធិការបច្ចេកទេស ។

**មន្ត្រី និងការដឹកនាំការងារ**

១៤. គណៈកម្មាធិការបច្ចេកទេសត្រូវជ្រើសរើសប្រធានពីបណ្តាប្រតិភូជាសមាជិក និងអនុប្រធានមួយនាក់ ឬច្រើននាក់ ។ ប្រធាន និងអនុប្រធានត្រូវធ្វើការសម្រាប់រយៈពេលមួយឆ្នាំ ។ ប្រធាន ឬអនុប្រធានដែលចូលនិវត្តមានសិទ្ធិធ្វើការជ្រើសតាំងជាថ្មី ។ អាណត្តិរបស់ប្រធាន ឬអនុប្រធានដែលមិនមែនជាតំណាងសមាជិកនៃគណៈកម្មាធិការបច្ចេកទេសត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ ។

១៥. ប្រសិនបើប្រធានអវត្តមានពីការប្រជុំណាមួយ ឬផ្នែកនៃកិច្ចប្រជុំណាមួយ អនុប្រធានត្រូវដឹកនាំកិច្ចប្រជុំជំនួស ។ ក្នុងករណីនេះ អនុប្រធានត្រូវមានសិទ្ធិអំណាច និងការកិច្ចដូចគ្នាទៅនឹងប្រធាន ។

១៦.　ប្រធាននៃកិច្ចប្រជុំត្រូវចូលរួមក្នុងកិច្ចដំណើរការរបស់គណៈកម្មាធិការបច្ចេកទេស តែមិនមែនជាតំណាងសមាជិកនៃគណៈកម្មាធិការបច្ចេកទេសទេ ។

១៧. បន្ថែមទៅលើអំណាចផ្សេងៗដែលបានប្រគល់ឲ្យប្រធានតាមច្បាប់ ប្រធានត្រូវប្រកាសបើក និងបិទកិច្ចប្រជុំ ការពិភាក្សាដោយផ្ទាល់ ផ្តល់សិទ្ធិក្នុងការនិយាយ និងអនុលោមទៅតាមច្បាប់ ត្រូវធ្វើការត្រួតពិនិត្យនូវកិច្ចដំណើរការប្រជុំ ។ ប្រធានមានសិទ្ធិជំពាបទៅវាគ្មិន ប្រសិនបើការសំដែងមតិរបស់វាគ្មិនមិនពាក់ព័ន្ធទៅនឹងកិច្ចប្រជុំ ។

១៨. ក្នុងកំឡុងពេលពិភាក្សាបញ្ហានីមួយៗ គណៈប្រតិភូអាចលើកឡើងនូវសំណើរបស់ខ្លួន ។ ក្នុងករណីនេះប្រធានត្រូវពិនិត្យជាបន្ទាន់ ។ ប្រសិនបើសេចក្តីសម្រេចរបស់ខ្លួនត្រូវបានជំទាស់ ប្រធានត្រូវដាក់ជូនទៅកិច្ចប្រជុំ ដើម្បីធ្វើការសំរេចចិត្ត និងត្រូវប្រកាន់យកប្រសិនបើមិនមានមតិជំទាស់ ។

១៩. អគ្គលេខាធិការ ឬមន្ត្រីនៃលេខាធិការដ្ឋាន C.C.C ដែលបានតែងតាំងដោយអគ្គលេខាធិការ ត្រូវអនុវត្តការងារលេខាធិការនៃកិច្ចប្រជុំរបស់គណៈកម្មាធិការបច្ចេកទេស។

## កូរ៉ុម និងការបោះឆ្នោត

២០. តំណាងនៃសំលេងភាគច្រើននៃសមាជិកគណៈកម្មាធិការបច្ចេកទេសបង្កើតបានជាកូរ៉ុម ។

២១.　សមាជិកនីមួយៗនៃគណៈកម្មាធិការបច្ចេកទេសមានសិទ្ធិបោះឆ្នោតមួយសំលេង ។ ការសម្រេចចិត្តរបស់ គណៈកម្មាធិការបច្ចេកទេសត្រូវធ្វើឡើងដោយសំលេងភាគច្រើន ដែលរួមបញ្ចូលយ៉ាងតិចពីរភាគបីនៃសមាជិកដែលមានវត្តមាន ។ ចំពោះលទ្ធផលនៃការបោះឆ្នោតលើបញ្ហាជាក់ស្តែងណាមួយ គណៈកម្មាធិការបច្ចេកទេសត្រូវធ្វើរបាយការណ៍ពេញលេញចំពោះគណៈកម្មាធិការ និងចំពោះ C.C.C លើបញ្ហាដែលបានចង្អុលបង្ហាញនូវគំនិតខុសគ្នាដែលបានបញ្ចេញទាក់ទងទៅនឹងការពិភាក្សា ។ ថ្វីបើមានចែងនូវបញ្ញត្តិខាងលើនៃកថាខណ្ឌនេះក៏ដោយ គណៈកម្មាធិការបច្ចេកទេសត្រូវធ្វើការសំរេចចិត្តលើបញ្ហា ដែលលើកឡើងដោយក្រុមការងារ តាមរបៀបព្រមព្រៀងគ្នា (Consensus) ។ ពេលដែលគ្មានកិច្ចព្រមព្រៀងត្រូវបានសម្រេចនៅក្នុងគណៈកម្មាធិការ

បច្ចេកទេសលើបញ្ហាដែលលើកឡើងដោយក្រុមការងារទេ គណៈកម្មាធិការបច្ចេកទេស ត្រូវផ្ដល់របាយការណ៍លម្អិតស្ដីពីបញ្ហា និងចន្លុលបង្ហាញពីគំនិតរបស់សមាជិក ។

**ភាសា និងកំណត់ត្រា**

២២. ភាសាជាផ្លូវការដែលត្រូវប្រើនៅក្នុងគណៈកម្មាធិការបច្ចេកទេសគឺភាសាអង់គ្លេស បារាំង និងអេស្ប៉ាញ ។ សន្ទរកថា និងសេចក្ដីថ្លែងការណ៍ត្រូវធ្វើឡើងជាបីភាសា ហើយត្រូវបកប្រែជាបន្ទាន់ទៅភាសាផ្លូវការផ្សេងទៀត លើកលែងតែគណៈប្រតិភូទាំងអស់យល់ព្រមបែងចែកជាមួយការបកប្រែ ។ សន្ទរកថា ឬសេចក្ដីថ្លែងការធ្វើដោយភាសាផ្សេងទៀតត្រូវបកប្រែទៅភាសាអង់គ្លេស បារាំង និង អេស្ប៉ាញ ដែលស្ថិតនៅក្នុងល័ក្ខខ័ណ្ឌដូចគ្នា ប៉ុន្តែក្នុងព្រឹត្តិការណ៍នេះ គណៈប្រតិភូដែលជាប់ពាក់ព័ន្ធត្រូវផ្ដល់ឲ្យនូវការបកប្រែទៅជាភាសាអង់គ្លេស បារាំង និង អេស្ប៉ាញ ។ មានតែភាសាអង់គ្លេស បារាំង ឬអេស្ប៉ាញទេ ត្រូវបានប្រើប្រាស់សម្រាប់ឯកសារផ្លូវការនៃគណៈកម្មាធិការបច្ចេកទេស ។ អនុស្សរណៈ និងលិខិតឆ្លើយឆ្លងសម្រាប់ការពិចារណានៃគណៈកម្មាធិការ ត្រូវធ្វើឡើងជាភាសាណាមួយនៃភាសាផ្លូវការទាំងបី ។

២៣. គណៈកម្មាធិការបច្ចេកទេសត្រូវធ្វើរបាយការណ៍នៃសម័យប្រជុំទាំងអស់ ហើយប្រសិនបើប្រធានគិតថាមានសារៈសំខាន់ កំណត់ហេតុ ឬរបាយការណ៍សង្ខេបនៃកិច្ចប្រជុំទាំងឡាយ ប្រធាន ឬអ្នកតែងតាំងជំនួស ត្រូវធ្វើរបាយការណ៍ពីការងារនៃគណៈកម្មាធិការបច្ចេកទេសនៅកិច្ចប្រជុំនីមួយៗ របស់គណៈកម្មាធិការ និងកិច្ចប្រជុំនីមួយៗរបស់ C.C.C ។

**ឧបសម្ព័ន្ធ III**

១. ការពន្យារពេល ៥ ឆ្នាំ នៃការអនុវត្តបញ្ញត្តិនានារបស់កិច្ចព្រមព្រៀងដោយសមាជិកប្រទេសកំពុងអភិវឌ្ឍន៍ ដែលបានចែងនៅក្នុងកថាខណ្ឌ ១ មាត្រា ២០ អាចមិនគ្រប់គ្រាន់សម្រាប់ប្រទេសជាសមាជិកកំពុងអភិវឌ្ឍន៍ខ្លះ ។ ក្នុងករណីនេះប្រទេសជាសមាជិកកំពុងអភិវឌ្ឍន៍ អាចស្នើសុំមុនពេលបញ្ចប់ការពន្យារពេល ដូចមានចែងក្នុងកថាខណ្ឌ ១ មាត្រា ២០ ដោយយល់ថា សមាជិកដទៃទៀតនឹងធ្វើការពិចារណានូវការ

យោគយល់ចំពោះសំណើ ក្នុងករណីដែលប្រទេសជាសមាជិកកំពុងអភិវឌ្ឍន៍នោះអាចបង្ហាញនូវហេតុផលសមរម្យបាន ។

២. ប្រទេសកំពុងអភិវឌ្ឍន៍ ដែលបច្ចុប្បន្ននេះការកំណត់តម្លៃទំនិញផ្អែកលើតម្លៃអប្បបរិមារជាមូលដ្ឋាន អាចមានគោលបំណងធ្វើការត្រៀមបំរុងដើម្បីអាចឲ្យខ្លួនអនុវត្តវិធានចាស់នោះក្នុងកម្រិតណាមួយ ក្នុងដំណាក់កាលអន្តរកាលក្រោមល័ក្ខខ័ណ្ឌដូចដែលបានព្រមព្រៀងដោយសមាជិកនានា ។

៣. ប្រទេសកំពុងអភិវឌ្ឍន៍ អាចពិចារណានូវការអនុវត្តត្រលប់នៃវិធីសាស្ត្រកំណត់តម្លៃគិតពន្ធគយ នៅពេលមានការស្នើសុំពីអ្នកនាំចូលស្របតាមមាត្រា ៤ នៃកិច្ចព្រមព្រៀង ដែលអាចផ្តល់នូវការលំបាកខ្វះ និងមានបំណងត្រៀមបម្រុងក្នុងការអនុវត្តមាត្រា ៤ ក្នុងល័ក្ខខ័ណ្ឌដូចតទៅ ៖

" រដ្ឋាភិបាលនៃ ...... រក្សានូវសិទ្ធិថា បញ្ញត្តិដែលពាក់ព័ន្ធនឹងមាត្រា ៤ នៃកិច្ចព្រមព្រៀងត្រូវបានអនុវត្តតែនៅពេលអាជ្ញាធរគយយល់ព្រមលើការស្នើសុំនូវការអនុវត្តត្រឡប់នៃមាត្រា ៥ និង ៦" ។

ប្រសិនបើប្រទេសកំពុងអភិវឌ្ឍន៍ធ្វើការត្រៀមបំរុងបែបនេះ សមាជិកដទៃត្រូវអនុញ្ញាតស្របតាមមាត្រា ២១ នៃកិច្ចព្រមព្រៀង ។

៤. ប្រទេសកំពុងអភិវឌ្ឍន៍មានបំណងធ្វើការត្រៀមបំរុងស្របទៅនឹងកថាខណ្ឌ ២ មាត្រា ៥ នៃកិច្ចព្រម ព្រៀងក្នុងល័ក្ខខ័ណ្ឌដូចតទៅ ៖

" រដ្ឋាភិបាលនៃ .......... មានសិទ្ធិដើម្បីអនុវត្តកថាខណ្ឌ ២ នៃមាត្រា ៥ នៃកិច្ចព្រមព្រៀងដែលត្រូវបានអនុវត្តស្របទៅនឹងបញ្ញាត្តិនៃកំណត់សំគាល់ដែលពាក់ព័ន្ធ ទោះបីជាអ្នកនាំចូលមិនមានការស្នើសុំក៏ដោយ" ។

ប្រសិនបើប្រទេសកំពុងអភិវឌ្ឍន៍ធ្វើការត្រៀមបំរុងបែបនេះ សមាជិកត្រូវអនុញ្ញាតស្របតាមមាត្រា ២១ នៃកិច្ចព្រមព្រៀង ។

៥. ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនអាចមានបញ្ហាក្នុងការអនុវត្តនូវមាត្រា ១ នៃកិច្ចព្រមព្រៀងនៅពេលដែលមានករណីនាំចូលមកក្នុងប្រទេសដោយភ្នាក់ងារផ្តាច់មុខ អ្នក

ចែកចាយផ្តាច់មុខ និងអ្នកទទួលសិទ្ធិលក់ផ្តាច់មុខ ។ ប្រសិនបើបញ្ហាបែបនេះកើតមានឡើងក្នុងប្រទេសជាសមាជិកកំពុងអភិវឌ្ឍន៍ ដែលការសិក្សាពីបញ្ហានេះត្រូវធ្វើឡើងតាមការស្នើសុំពីសមាជិកនោះ ជាមួយគំនិតក្នុងន័យដើម្បីស្វែងរកនូវដំណោះស្រាយសមស្របណាមួយ ។

៦. មាត្រា ១៧ ទទួលស្គាល់ថា ក្នុងការអនុវត្តកិច្ចព្រមព្រៀង រដ្ឋបាលគយអាចតម្រូវឲ្យធ្វើការបង្ហាញនូវភាពពិតប្រាកដ និងត្រឹមត្រូវនៃការអះអាង ឯកសារ ឬការប្រកាសដែលបានបង្ហាញសម្រាប់គោលបំណងនៃការកំណត់តម្លៃគិតពន្ធគយ ។ ដូច្នេះមាត្រានេះទទួលស្គាល់ថា ការទាមទាររបស់រដ្ឋបាលគយបែបនេះត្រូវធ្វើឡើងក្នុងគោលបំណងធ្វើការពិនិត្យផ្ទៀងផ្ទាត់ថា ជាតុផ្សំនានានៃតម្លៃដែលបានប្រកាស ឬបង្ហាញចំពោះគយ ក្នុងការកំណត់តម្លៃគិតពន្ធ ត្រូវមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវ ។ ដោយអនុលោមតាមច្បាប់ជាតិ និងនីតិវិធីនានា សមាជិកនីមួយៗមានសិទ្ធិទទួលនូវកិច្ចសហប្រតិបត្តិការដោយពេញលេញពីអ្នកនាំចូលក្នុងតម្រូវការរបស់រដ្ឋបាលគយដូចនេះ ។

៧. ថ្លៃដែលបានបង់ ឬនឹងត្រូវបង់ពិតប្រាកដរួមបញ្ចូលគ្រប់ការចំណាយទាំងអស់ដែលបានធ្វើឡើងក្នុងល័ក្ខខ័ណ្ឌនៃការលក់ទំនិញនាំចូល ដោយអ្នកទិញទៅអ្នកលក់ ឬដោយអ្នកទិញទៅភាគីទីបី ដើម្បីបំពេញនូវកាតព្វកិច្ចនៃអ្នកលក់ ។